ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

## ក្រសួងបរិស្ថាន

# ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

## ២០១៦- ២០១៨

ឆ្នាំ២០១៦

ក្រសួងបរិស្ថាន៖ ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ២០១៦ - ២០១៨
ធ្វើនៅខែមករា ឆ្នាំ២០១៦
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

រៀបចំដោយ៖ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
បោះពុម្ពដោយ៖ ក្រសួងបរិស្ថាន
គាំទ្រដោយ៖ សហភាពអឺរ៉ុប(EU) ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ(SIDA) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) តាមរយៈកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា(CCCA)

# អារម្ភកថា

ក្នុងនាមក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន ខ្ញុំសូមសំដែងការគោរពដ៏ខ្ពង់ខ្ពស់ និងកតវេទិតាដ៏ស្មោះស្ម័គ្រចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានគាំទ្រយ៉ាងពេញទំហឹង និងយកចិត្តទុកដាក់ខ្ពស់លើការងារប្រែប្រួលអាកាសធាតុ។ នៅចុងឆ្នាំ ២០១៣ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ នូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ ដែលមានចក្ខុវិស័យ និងគោលដៅសម្រាប់ឱ្យព្រះរាជាណាចក្រកម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយ ដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានបញ្ជាក់ថា ឯកសារយុទ្ធសាស្ត្រនេះ ជាជំហានដ៏សំខាន់ឆ្ពោះទៅរកការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងផែនការអភិវឌ្ឍន៍តាមវិស័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

បច្ចុប្បន្ននេះមាន ក្រសួង ស្ថាប័នរដ្ឋចំនួន១៤ បាននិងកំពុងរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យរបស់ខ្លួន ដើម្បីរួមចំណែកក្នុងកិច្ចប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទូទាំងប្រទេស និងដើម្បីអនុវត្តឱ្យបានជោគជ័យនៃផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។ ផ្នែកមួយនៃកិច្ចប្រឹងប្រែងនេះ ក្រសួងបរិស្ថានបានរៀបចំ **ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១៦-២០១៨** ដោយដាក់ចេញនូវគោលការណ៍ណែនាំសម្រាប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពក្រោមយុត្តាធិការរបស់ក្រសួង ដូច្នេះវិស័យបរិស្ថានអាចរួមចំណែកក្នុងវិធីសាស្ត្រ ដែលមានប្រសិទ្ធភាព សម្របសម្រួល និងជាយុទ្ធសាស្ត្រ ទៅដល់កិច្ចប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ វិសាលភាពនៃផែនការនេះ រួមបញ្ចូលនូវអាណត្តិរបស់ក្រសួងបរិស្ថាន និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយគ្របដណ្តប់លើផ្នែកជាយុទ្ធសាស្ត្រជាច្រើន រាប់បញ្ចូលទាំងការបញ្ជ្រាបការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការ និងរៀបចំថវិកានៅថ្នាក់ជាតិ និងក្រោមជាតិ ការគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ និងការពង្រឹងការគ្រប់គ្រងចំណេះដឹង និងប្រព័ន្ធព័ត៌មានបរិស្ថាន។

ឯកសារនេះត្រូវបានរៀបចំឡើង ដោយអនុលោមតាមការណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាច្រើនលើកនៅក្នុងក្រសួងបរិស្ថាន ក៏ដូចជាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ សំដៅធានាឱ្យមានភាពពេញលេញនៃឯកសារ និងមានសង្គតិភាពជាមួយយុទ្ធសាស្ត្រ និងគោលនយោបាយដែលមានស្រាប់ ព្រមទាំងបន្សីុជាមួយកម្មវិធីអាទិភាពរបស់ក្រសួង។ ឯកសារយោងសំខាន់ៗសម្រាប់រៀបចំឯកសារនេះមានដូចជា របាយការណ៍ជាតិវាយតម្លៃភាពងាយរងគ្រោះ របាយការណ៍ជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកទី១ និងទី២ សម្រាប់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងផែនការតាមវិស័យ ក៏ដូចជារបាយការណ៍សិក្សាស្រាវជ្រាវនានាអំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។

ការឯកភាពគ្នាជាជំហានដ៏សំខាន់ក្នុងពេលរៀបចំឯកសារផែនការនេះឡើង ក្នុងន័យធានាឱ្យមានភាពជាម្ចាស់និងការទទួលខុសត្រូវរបស់នាយកដ្ឋានពាក់ព័ន្ធ និងការចូលរួមដ៏ទូលំទូលាយពីអ្នកពាក់ព័ន្ធនានា នៅពេលអនុវត្ត។ ផែនការសកម្មភាពនេះ ជាយុទ្ធសាស្ត្រតម្រង់ទិសដ៏សំខាន់ សម្រាប់នាយកដ្ឋាន និងអង្គភាពចំណុះក្រសួង លើការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ហើយឯកសារនេះ នឹងក្លាយជាឧបករណ៍ដ៏សំខាន់សម្រាប់ការកៀរគរធនធានពីក្នុងនិងក្រៅប្រទេសសម្រាប់អនុវត្តឱ្យបានជោគជ័យវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថានរំពឹងថានឹងបង្កើតនូវអត្ថប្រយោជន៍ច្រើន មិនត្រឹមតែពង្រឹងគុណភាពបរិស្ថានឱ្យល្អប៉ុណ្ណោះទេ ថែមទាំងបង្កើនភាពធន់នឹងអាកាសធាតុរបស់ព្រះរាជាណាចក្រកម្ពុជាទាំងមូល តាមរយៈការផ្លាស់ប្តូរបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ ឱ្យក្លាយទៅជាកាលានុវត្តភាពសម្រាប់ធានាឱ្យមានអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមដោយចីរភាព។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះ មន្ត្រីក្រោមឱវាទក្រសួង អ្នកជំនាញការប្រែប្រួលអាកាសធាតុជាតិនិងអន្តរជាតិ កម្មវិធីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មរៀបចំផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ២០១៦-២០១៨ របស់ក្រសួងបរិស្ថាននេះឡើង។

ខ្ញុំមានសេចក្តីសោមនស្សរីករាយសូមប្រកាសដាក់ឱ្យប្រើប្រាស់ និងចាប់ផ្តើមអនុវត្តជាផ្លូវការក្នុងពេលនេះនូវ ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ២០១៦-២០១៨៕

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

# សេចក្តីថ្លែងអំណរគុណ

ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ២០១៦-២០១៨ ត្រូវបានរៀបចំឡើងក្រោមការសម្របសម្រួលរួមរបស់ក្រសួងបរិស្ថាន ដោយមានការចូលរួមយ៉ាងសកម្មពីនាយកដ្ឋានទាំងអស់របស់ក្រសួង និងជាមួយការណែនាំសំខាន់ៗ ពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ការចូលរួមរបស់អ្នកទាំងអស់គ្នាធ្វើឱ្យផែនការសកម្មភាពនេះមានលក្ខណៈជាយុទ្ធសាស្ត្រ មានសង្គតិភាព និងបន្សុី ជាមួយកម្មវិធីអាទិភាព ផែនការ និងគោលនយោបាយផ្សេងៗរបស់ក្រសួង និងជាមួយគោលដៅអភិវឌ្ឍន៍ជាតិ។ យោបល់ និងមតិទទួលបានពីបុគ្គលនិងភាគីពាក់ព័ន្ធជាច្រើន ផ្តល់ជាធាតុចូលមានលក្ខណៈជាយុទ្ធសាស្ត្រ សម្រាប់រៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ២០១៦-២០១៨។ ការគាំទ្រផ្នែកបច្ចេកទេសដ៏ទូលំទូលាយត្រូវបានផ្តល់ដោយអ្នកជំនាញការប្រែប្រួលអាកាសធាតុជាតិ និងអន្តរជាតិនៅពេលរៀបចំផែនការនេះ។

ក្រសួងបរិស្ថានសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពសម្រាប់ការណែនាំ ដល់ភាគីពាក់ព័ន្ធទាំងអស់សម្រាប់ការធាតុចូលល្អៗក្នុងពេលពិគ្រោះយោបល់ និងដល់នាយកដ្ឋានទាំងអស់របស់ក្រសួង ដែលបានខិតខំជួយពុំគិតការនឿយហត់នៅពេលរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ២០១៦-២០១៨ របស់ក្រសួងបរិស្ថាន។

ការរៀបចំផែនការសកម្មភាពនេះ មានការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍មួយចំនួនដូចជាសហភាពអឺរ៉ុប ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិតាមរយៈកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា៕

# មាតិកា

**អារម្ភកថា** ........ i

**សេចក្តីថ្លែងអំណរគុណ** ........ iii

**មាតិកា** ........ iv

**ពាក្យបំព្រួញ និងអក្សរកាត់** ........ vi

**សេចក្តីសង្ខេប** ........ x

1. **សេចក្តីផ្តើម** ........ 1

*សាវតា* ........ 1

*ស្ថានភាព* ........ 1

*កម្មវិធីអាទិភាពរបស់ក្រសួងបរិស្ថាន* ........ 2

2. **ផែនការសកម្មភាព** ........ 4

*វិសាលភាពនៃផែនការសកម្មភាពប្រែប្រួលអាកាសធាតុ* ........ 4

*តារាងផែនការសកម្មភាព* ........ 4

*អត្ថប្រយោជន៍រំពឹងទុកពីការអនុវត្តនេះ* ........ 6

3. **យន្តការគ្រប់គ្រង និងហិរញ្ញប្បទាន** ........ 6

*យន្តការគ្រប់គ្រង និងហិរញ្ញប្បទានដែលមានស្រាប់* ........ 6

*ប្រភពដែលមានសក្តានុពល និងទំហំនៃហិរញ្ញវត្ថុសម្រាប់សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ* ........ 8

4. **ការតាមដាន និងវាយតម្លៃ** ........ 9

5. **ច្បាប់ និងបរិធានច្បាប់ដើម្បីគាំទ្រដល់ការអនុវត្ត** ........ 11

6. **សេចក្តីសន្និដ្ឋាន** ........ 12

**ឧបសម្ព័ន្ធ** 1: **បញ្ជីសកម្មភាពទាក់ទងនឹងការប្រែប្រួលសកម្មភាព** ........ 13

**ឧបសម្ព័ន្ធ** 2: **សន្លឹកព័ត៌មានអំពីសកម្មភាព** ........ 23

*សកម្មភាព 1: បង្កើតមណ្ឌលបច្ចេកវិទ្យាបញ្ចេញកាបូនតិចធន់អាកាសធាតុដើម្បីសន្តិសុខស្បៀង ទឹក និងថាមពល* ........ 23

*សកម្មភាព 2: ធ្វើការវាយតម្លៃភាពងាយរងគ្រោះនៅថ្នាក់ជាតិ និងតាមវិស័យ* ........ 25

*សកម្មភាព 3: ធ្វើការវាយតម្លៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើជីវៈចម្រុះ* ........ 27

*សកម្មភាព 4: រៀបចំការសិក្សាបឋមដើម្បីបង្កើតគណនេយ្យមូលធនធម្មជាតិ* ........ 30
*សកម្មភាព 5: បង្កើតប្រព័ន្ធសារពើភណ្ឌ ឧស្ម័នផ្ទះកញ្ចក់ ជាតិ* ........ 32
*សកម្មភាព 6: សម្រួលដល់ការកាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ តាមរយៈគម្រោង និងកម្មវិធី* ........ 34
*សកម្មភាព 7: បង្កើតនិងតេស្ត អភិក្រម និងជម្រើស បញ្ចេញកាបូនតិចធន់អាកាសធាតុសម្រាប់ទីប្រជុំជន* ........ 37
*សកម្មភាព 8: បង្កើតប្រព័ន្ធគ្រប់គ្រងចំណេះដឹងស្តីពី CC & GG* ........ 39
*សកម្មភាព 9: ដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅគ្រប់លំដាប់ថ្នាក់* ........ 42
*សកម្មភាព 10: ការចូលរួម និងលើកកម្ពស់ការយល់ដឹងអំពី CC និង GG/ការប្រើប្រាស់និងផលិតកម្មដោយចីរភាព* ........ 44
*សកម្មភាព 11: លើកកម្ពស់ និងកែលម្អសមត្ថភាពបន្ស៊ាំរបស់សហគមន៍ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ* ... 47
*សកម្មភាព 12: ប្រកាសឱ្យប្រើប្រាស់ និងអនុវត្តប្រព័ន្ធ M&E នៅថ្នាក់ជាតិ និងតាមវិស័យ* ........ 49
*សកម្មភាព 13: ការកសាងសមត្ថភាពស្ថាប័នជាតិសម្របសម្រួលការអនុវត្តការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ* ... 52
*សកម្មភាព 14: គាំទ្រដល់ក្រសួងពាក់ព័ន្ធដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ និងថវិកា* .... 54
*សកម្មភាព 15: ពង្រឹងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តនានាសម្រាប់ការអភិវឌ្ឍបញ្ចេញការបូនតិចធន់នឹងអាកាសធាតុ* ... 56
*សកម្មភាព 16: បង្កើតក្របខ័ណ្ឌជាតិហិរញ្ញវត្ថុកាបូន* ........ 58
*សកម្មភាព 17: ការរៀបចំរបាយការណ៍សម្រាប់ UNFCCC* ........ 60
**ឧបសម្ព័ន្ធ 3: បញ្ជីច្បាប់និងលិខិតបទដ្ឋានក្រោមក្រសួងបរិស្ថាន** ........ 62

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AF | Adaptation Fund | មូលនិធិបន្សាំ |
| AFD | Agence Française de Développement | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| AIF | Alternative Investment Fund | មូលនិធិវិនិយោគជំនួស |
| ASEAN | Association of South East Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BURs | Biennial Update Reports | របាយការណ៍បច្ចុប្បន្នភាពប្រចាំពីរឆ្នាំ |
| CC | Climate Change | ការប្រែប្រួលអាកាសធាតុ |
| CCAP | Climate Change Action Plan | ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| CCCA | Cambodia Climate Change Alliance | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCSP | Cambodia Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា |
| DCC | Climate Change Department | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| CCSP | Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| CCTT | Climate Change Technical Team | ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ |
| CDC | Council for the Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDM | Clean Development Mechanism | យន្តការអភិវឌ្ឍន៍ស្អាត |
| CI | Conservation International | អង្គការអភិរក្សអន្តរជាតិ |
| CIF | Climate Investment Fund | មូលនិធិវិនិយោគអាកាសធាតុ |
| COP | Conference of the Parties | សន្និសីទភាគី |
| CPEIR | CC Public Expenditure & Institutional Review | ការពិនិត្យការចំណាយសាធារណៈនិងស្ថាប័នលើការងារប្រែប្រួលអាកាសធាតុ |
| CSIRO | Commonwealth Scientific and Industrial Research Organisation | អង្គការស្រាវជ្រាវវិទ្យាសាស្ត្រ និងឧស្សាហកម្មនៃអតីតរដ្ឋចំណុះចក្រភពអង់គ្លេស |
| DAPF | Department of Administration Planning and Finance | នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ |
| DCD | Department of Curriculum Development of MoEYS | នាយកដ្ឋានរៀបចំកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជននិងកីឡា |
| DGEKI | General Directorate of Environmental Knowledge and Information | អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន |
| DNA | Designated National Authority | ស្ថាប័នជាតិយន្តការអភិវឌ្ឍន៍ស្អាត |
| DST | Department of Science and Technology | នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា |
| EbA | Ecosystem-based Adaptation | ការបន្សាំដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ី |
| EIA | Environmental Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| EP&L | Environmental Profit and Loss | ផលចំណេញ និងការបង់ខាតខាងបរិស្ថាន |
| EU | European Union | សហភាពអឺរ៉ុប |
| FAO | Food and Agriculture Organization | អង្គការស្បៀង និងកសិកម្ម |
| FFEM | Fonds Français pour l'Environnement Mondial | មូលនិធិបារាំងដើម្បីបរិស្ថានពិភពលោក |
| FFI | Fauna & Flora International | អង្គការសត្វនិងរុក្ខជាតិអន្តរជាតិ |
| FWE | Food Water Energy | ស្បៀងអាហារ ទឹក ថាមពល |
| GCF | Green Climate Fund | មូលនិធិអាកាសធាតុបៃតង |
| GCPF | Global Climate Partnership Fund | មូលនិធិភាពជាដៃគូអាកាសធាតុពិភពលោក |

| | | |
|---|---|---|
| GDNCPA | General Department of Nature Conservation and Protection Administration | អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ |
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) |
| GED | Green Economy Department | នាយកដ្ឋានសេដ្ឋកិច្ចបៃតង |
| GEEREF | Global Energy Efficiency and Renewable Energy Fund | មូលនិធិប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញពិភពលោក |
| GEF | Global Environmental Facility | មូលនិធិបរិស្ថានពិភពលោក |
| GEF TF | Global Environmental Facility Trust Fund | មូលនិធិរតេកដើម្បីបរិស្ថានពិភពលោក |
| GG | Green Growth | ការអភិវឌ្ឍបៃតង |
| GGGI | Global Green Growth Institute | វិទ្យាស្ថានអភិវឌ្ឍន៍បៃតងពិភពលោក |
| GHG | Greenhouse Gas | ឧស្ម័នផ្ទះកញ្ចក់ |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit | ទីភ្នាក់ងារអាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិ |
| ICF | International Climate Fund | មូលនិធិអាកាសធាតុអន្តរជាតិ |
| ICT | Information and Communications Technology | បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង |
| IDB | Islamic Development Bank | ធនាគារអភិវឌ្ឍន៍អ៊ីស្លាម |
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍កសិកម្ម |
| IIED | International Institute for Environment and Development | វិទ្យាស្ថានអន្តរជាតិដើម្បីបរិស្ថាន និងអភិវឌ្ឍន៍ |
| IKI | International Climate Initiative | កិច្ចផ្តួចផ្តើមអាកាសធាតុអន្តរជាតិ |
| INDCs | Intended Nationally Determined Contributions | ឆន្ទៈជាតិដើម្បីការរួមវិភាគទាន |
| IPCC | Intergovernmental Panel on Climate Change | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| IUCN | International Union for Conservation of Nature | សហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ |
| IWMI | International Water Management Institute | វិទ្យាស្ថានគ្រប់គ្រងទឹកអន្តរជាតិ |
| JCM | Joint Crediting Mechanism | យន្តការឥណទានរួមគ្នា |
| KAP | Knowledge, Attitude and Practices | ចំណេះដឹង ឥរិយាបថ និងការអនុវត្ត |
| KMIS | Knowledge Management and Information System | ប្រព័ន្ធគ្រប់គ្រងចំណេះដឹង និងព័ត៌មាន |
| LAIF | Latin America Investment Facility | មូលនិធិវិនិយោគអាមេរិកឡាទីន |
| LDCF | Least Developed Countries Fund | មូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច |
| LULUCF | Land use, land-use change and forestry | ការប្រើប្រាស់ដី, ការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| M&E | Monitoring and evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIH | Ministry of Industry and Handicraft | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MLMUPC | Ministry of Land Management, Urban Planning and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ |
| MME | Ministry of Mines and Energy | ក្រសួងរ៉ែ និងថាមពល |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoInfo | Ministry of Information | ក្រសួងព័ត៌មាន |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoT | Ministry of Tourism | ក្រសួងទេសចរណ៍ |

| | | |
|---|---|---|
| MOU | Memorandum of Understanding | អនុស្សារណៈនៃការយោគយល់ |
| MOWA | Ministry of Women Affairs | ក្រសួងកិច្ចការនារី |
| MOWRAM | Ministry of Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម |
| MPTC | Ministry of Posts and Telecommunications | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| MRV | Measuring, Reporting and Verification | ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ |
| NAMA | Nationally Appropriate Mitigation Action | សកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលសមស្របថ្នាក់ជាតិ |
| NAP | National Adaptation Plans | ផែនការជាតិសម្រាប់ការបន្សាំ |
| NAPA | National Adaptation Program of Action | កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NBSAP | National Biodiversity Strategy and Action Plan | យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចម្រុះជាតិ |
| NC | National Communication | របាយការណ៍ជាតិ |
| NCA | Natural Capital Accounting | គណនេយ្យមូលធនធម្មជាតិ |
| NCCC | National Climate Change Committee | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| NCF | Nordic Climate Facility | មូលនិធិអាកាសធាតុន័រឌិក |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NEFCO | Nordic Environment Finance Corporation | សាជីវកម្មហិរញ្ញវត្ថុបរិស្ថានន័រឌិក |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NIE | National Implementing Entity | អង្គភាពជាតិទទួលខុសត្រូវការអនុវត្ត |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| NOx | Mono-nitrogen Oxides (NO and $NO_2$) | ម៉ូណូនិងឌីអាហ្សូតអុកស៊ីត ( NO និង $NO_2$) |
| NPI | Nordic Partnership Initiative | កិច្ចផ្តួចផ្តើមភាពជាដៃគូន័រឌិក |
| NSFSN | National Strategy on Food Security and Nutrition | យុទ្ធសាស្ត្រជាតិសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PDOE | Provincial Department of Environment | មន្ទីរបរិស្ថានខេត្ត |
| QA | Quality Assurance | ការធានាគុណភាព |
| QC | Quality Control | ការត្រួតពិនិត្យគុណភាព |
| REDD | Reducing Emissions from Deforestation and Forest Degradation | កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើនិងការរេចរឹលព្រៃឈើ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SDG | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ដោយចីរភាព |
| SDP | Sector Development Plan | ផែនការអភិវឌ្ឍន៍តាមវិស័យ |
| Sida | Swedish International Development Cooperation | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| SPCR | Strategic Program for Climate Resilience | ផែនការយុទ្ធសាស្ត្រដើម្បីភាពធន់នឹងអាកាសធាតុ |
| TA | Training Assessment | ការវាយតម្លៃការបណ្តុះបណ្តាល |
| TNC | Third National Communication | របាយការណ៍ជាតិលើកទីបី |
| TOR | Term of Reference | លក្ខខណ្ឌប្រតិបត្តិ |
| TWG | Technical Working Groups | ក្រុមការងារបច្ចេកទេស |
| UK | United Kingdom | ចក្រភពអង់គ្លេស |
| UKAID | Department for International Development | ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNFCCC | United Nations Framework Convention on Climate | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |

| | | |
|---|---|---|
| | Change | |
| UNEP | United Nations Environment Programme | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| UNWTO | World Tourism Organization | អង្គការទេសចរណ៍ពិភពលោក |
| USAID | United States Agency for International Development | ទីភ្នាក់ងារស.រ.អ ដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| USD | United States Dollar | ដុល្លាអាមេរិក |
| VA | Vulnerability Assessments | ការវាយតម្លៃភាពងាយរងគ្រោះ |
| WB | World Bank | ធនាគារពិភពលោក |
| WCS | Wildlife Conservation Society | សមាគមអភិរក្សសត្វព្រៃ |
| WMO | World Meteorological Organization | អង្គការឧតុនិយមពិភពលោក |
| WWF | World Wide Fund for Nature | មូលនិធិពិភពលោកដើម្បីអភិរក្សធម្មជាតិ |

# សេចក្ដីសង្ខេប

ក្រសួងបរិស្ថានបានរៀបចំ **ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ២០១៦-២០១៨** ដោយយោងតាមគោលការណ៍ណែនាំរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

ក្នុងនាមជាប្រទេសដែលងាយរងគ្រោះខ្លាំងទៅនឹងការប្រែប្រួលអាកាសធាតុ ការវិនិយោគលើវិធានការឆ្លើយតបដែលមានប្រសិទ្ធភាពចំពោះបញ្ហាប្រឈមបង្កដោយការប្រែប្រួលអាកាសធាតុ ជាកត្តាសំខាន់ដល់កិច្ចប្រឹងប្រែងអភិវឌ្ឍដោយចីរភាពនៅព្រះរាជណាចក្រកម្ពុជា។ ការព្យាករណ៍អាកាសធាតុបង្ហាញពីភាពមិនប្រាកដប្រជាកាន់តែខ្លាំងឡើងនៃរបបធាតុអាកាស និងការកើតឡើងកាន់តែញឹកញាប់និងខ្លាំងក្លា នៃព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីដូចជាទឹកជំនន់ និងភាពរាំងស្ងួត ដែលបង្ហាញពី ជាឧទាហរណ៍ ការកើនឡើងនៃសីតុណ្ហភាពមធ្យមរវាង ០,០១៣°C ទៅ ០,០៣៦°C ជាប្រចាំឆ្នាំ រហូតដល់ឆ្នាំ២០៩៩ ហើយនីវ៉ូទឹកសមុទ្រនឹងកើនពីចន្លោះ ០,១៨ម ទៅ០,៥៦ម ដល់ឆ្នាំ២០៩០ យោងលើសេណារីយ៉ូនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សកល។ ផលប៉ះពាល់បណ្ដាលមកពីប្រែប្រួលទាំងនេះមកលើប្រព័ន្ធសេដ្ឋកិច្ច សង្គម និងធម្មជាតិ នឹងកាន់តែធំឡើង ជាមួយសក្ដានុពលបង្អាក់ការខិតខំប្រឹងប្រែងការអភិវឌ្ឍជាតិដោយចីរភាពនាពេលអនាគត និងអាចធ្វើឱ្យបាត់បង់ការអភិវឌ្ឍទទួលបានកន្លងមក ដែលកម្ពុជាបានខិតខំយ៉ាងសស្រាក់សស្រាម។ ហេតុដូច្នេះ បរិមាណនៃការវិនិយោគដែលគួរឱ្យកត់សំគាល់មួយ នឹងត្រូវការដើម្បីអាចឱ្យឆ្លើយតបបានសមរម្យទៅនឹងបញ្ហាប្រឈមបណ្ដាលពីការប្រែប្រួលអាកាសធាតុ មកលើកិច្ចអភិវឌ្ឍន៍ប្រទេស។

ផែនការសកម្មនេះ ក្លាយជាផ្នែកនៃការឆ្លើយតបដ៏ប្រទាក់ក្រឡាគ្នាមួយ រួមចំណែកដល់ការអនុវត្តឱ្យបានជោគជ័យនៃ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ តាមរយៈសកម្មភាពយុទ្ធសាស្ត្រមួយចំនួន ផ្ដោតលើការគាំពារបរិស្ថាន ការអភិរក្សនិងប្រើប្រាស់ដោយចីរភាពនៃធនធានធម្មជាតិ ការអភិវឌ្ឍបៃតង ការអប់រំនិងផ្សព្វផ្សាយបរិស្ថាន និងអភិបាលកិច្ចប្រែប្រួលអាកាសធាតុ ដែលរាប់បញ្ចូលទាំងសកម្មភាពទាំងឡាយណា សម្រាប់កសាងសមត្ថភាពចាំបាច់ នៅក្នុងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ការខិតខំប្រឹងប្រែងទាំងនេះនឹងជួយឱ្យព្រះរាជណាចក្រកម្ពុជាអាចឆ្លើយតបនឹងបញ្ហាប្រឈមពីការប្រែប្រួលអាកាសធាតុ និងចាប់យកឱកាសនានា តាមរយៈការធ្វើឱ្យប្រសើរឡើងនៃការសម្របសម្រួល និងការអនុវត្តកាន់តែមានប្រសិទ្ធភាពនៃវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ក្រសួងបរិស្ថាន បានកំណត់សកម្មភាពចំនួន១៧ ឆ្លើយតបផ្ទាល់ទៅនឹង ទិសដៅជាយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ដែលត្រូវការថវិកាសារុបចំនួន២៨ ទៅ៣០លាន

ដុល្លាអាមេរិក សម្រាប់ការអនុវត្តរយៈពេល៣ឆ្នាំ។ ផែនការសកម្មភាពនេះត្រូវបានរៀបចំឡើង តាមរយៈការពិគ្រោះយោបល់ជាច្រើនលើក ដែលមានការចូលរួមពីនាយកដ្ឋានពាក់ព័ន្ធ និងបណ្តាលដៃគូអភិវឌ្ឍន៍ និងភាគីអ្នកពាក់ព័ន្ធនានា។

ផលជាចម្បងចេញពីការអនុវត្តផែនការសកម្មភាពនេះមានដូចជា ១)ការយល់ដឹងជាសាធារណៈ កាន់តែច្រើនអំពីបញ្ហាប្រែប្រួលអាកាសធាតុ ២)ការពង្រឹងសមត្ថភាពស្ថាប័ននិងការបញ្ជ្រាបប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការនៅថ្នាក់ជាតិនិងក្រោមជាតិ ៣)ការពង្រឹងភាពធន់របស់សហគមន៍ និង៤)ការរួមចំណែកកាន់តែធំឡើង ដល់ការប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជាមួយការកើនឡើងនៃបរិមាណឥណទានកាបូនទទួលបានមកពីគម្រោងកាត់បន្ថយកាបូននៅព្រះរាជាណាចក្រកម្ពុជា។ លទ្ធផលជាក់លាក់នឹងទទួលបានតាមរយៈការអនុវត្តវិធានការទាំង១៧នៅក្នុងផែនការសកម្មភាពនេះ មានដូចខាងក្រោម ៖

១. មជ្ឈមណ្ឌលបច្ចេកវិទ្យាសម្រាប់សន្តិសុខស្បៀង ទឹក និងថាមពល
២. ការវិភាគភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ
៣. វិធានការបន្សាំសម្រាប់តំបន់ការពារធម្មជាតិ
៤. ប្រព័ន្ធគណនេយ្យមូលធនធម្មជាតិ
៥. ប្រព័ន្ធសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់
៦. ឥណទានកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
៧. កម្មវិធីនិងផែនការអភិវឌ្ឍន៍ទីក្រុងដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
៨. ប្រព័ន្ធគ្រប់គ្រងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ
៩. មេរៀនអប់រំស្តីអំពីការប្រែប្រួលអាកាសធាតុ
១០. ការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុជាសាធារណៈ
១១. ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការនៅថ្នាក់ក្រោមជាតិ
១២. ប្រព័ន្ធត្រួតពិនិត្យនិងតាមដានអំពីការប្រែប្រួលអាកាសធាតុ
១៣. ការអភិវឌ្ឍសមត្ថភាពសម្រាប់យន្តការសម្របសម្រួលការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ
១៤. ការផ្តល់ឥណទានឥតសំណងសម្រាប់អនុវត្តវិធានការឆ្លើយតបនឹងអាកាសធាតុ
១៥. ក្របខ័ណ្ឌច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ
១៥. ក្របខ័ណ្ឌជាតិស្តីពីហិរញ្ញវត្ថុកាបូន
១៧. ការធ្វើរបាយការណ៍ដាក់ជូនអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

លទ្ធផលចេញពីការអនុវត្តវិធានការឆ្លើយតបទាំងអស់នេះ រំពឹងថា នឹងចូលរួមចំណែកយ៉ាងសំខាន់ទៅដល់ការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីជាជំនួយដល់ការអនុវត្តផែនការសកម្មភាពនេះ ឯកសារផ្សព្វផ្សាយនឹងត្រូវរៀបចំឡើងដើម្បីចែកជូនទៅដល់បណ្ដានាយកដ្ឋានក្នុងក្របខ័ណ្ឌក្រសួងបរិស្ថានក៏ដូចជាក្រសួងផ្សេងៗ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីជំរុញដល់ការកសាងភាពជាដៃគូ និងពង្រឹងការអនុវត្តផែនការនេះ។ ដើម្បីធានាភាពជាម្ចាស់នៃសកម្ម ក្រុមការងារនឹងបន្តការងារជាមួយនាយកដ្ឋានផែនការនិងថវិកា និងនាយកដ្ឋានពាក់ព័ន្ធទាំងអស់ដើម្បីបញ្ចូលសកម្មភាពដែលបានកំណត់ចូលទៅក្នុង ផែនការថវិកាយុទ្ធសាស្ត្រ និងផែនការវិនិយោគសាធារណៈរបស់ក្រសួង។ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុនេះ ក្នុងករណីចាំបាច់ នឹងធ្វើបច្ចុប្បន្នភាពយោងលើការរកឃើញ ពីក្របខ័ណ្ឌត្រួតពិនិត្យតាមដាននិងវាយតម្លៃដែលគ្រោងនឹងបង្កើតក្នុងផែនការនេះដែរ ដោយរំពឹងថានឹងធ្វើនៅឆ្នាំ២០១៩ ដើម្បីឱ្យស្របទៅនឹងអាណត្តិរាជរដ្ឋាភិបាលឆ្នាំ២០១៩-២០២៣។

# 1. សេចក្តីផ្តើម

*សាវតា*

តាំងពីយូរមកហើយ រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយការប្រឈមនានាដែលបង្កដោយការប្រែប្រួលអាកាសធាតុ។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅឆ្នាំ 1995 និងពិធីសារក្យូតូនៅឆ្នាំ 2002។ ក្រសួងបរិស្ថានដើរតួជាស្ថាប័នបង្គោលរបស់កម្ពុជា សម្រាប់អនុសញ្ញា UNFCCC និងពិធីសារក្យូតូ ដោយដើរតួចំបងនៅក្នុងការរៀបចំ និងសម្របសម្រួលការឆ្លើយតបរបស់កម្ពុជាទៅនឹងការប្រែប្រួលអាកាសធាតុ។ វិស័យនានាដទៃទៀតជាអាទិ៍ ក្រសួងសំខាន់ៗនៃរាជរដ្ឋាភិបាលកម្ពុជា ក៏រួមចំណែកជាសំខាន់ផងដែរទៅក្នុងកិច្ចប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំគោលនយោបាយ និងការអនុវត្តគម្រោង និងកម្មវិធីនានាដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

នៅឆ្នាំ 2013 រាជរដ្ឋាភិបាលបានប្រកាសនិងដាក់អោយប្រើប្រាស់ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងប្រែប្រួលអាកាសធាតុកម្ពុជា 2014-2023 (CCCSP) ដែលផ្តល់ជាក្របខ័ណ្ឌរួមមួយសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ នៅថ្នាក់ជាតិ និងនៅតាមវិស័យ។ ជាលទ្ធផល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ 2014-2018 (NSDP) បានចាត់ទុកការប្រែប្រួលអាកាសធាតុជាបញ្ហាអន្តរវិស័យ ដែលធ្វើឱ្យការបញ្ជ្រាបការប្រែប្រួលអាកាសធាតុជាផ្នែករួមមួយនៃកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ តាមការណែនាំពី CCCSP ក្រសួងបច្ចេកទេសពាក់ព័ន្ធនានាបានរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើម្បីដាក់ឱ្យអនុវត្តCCCSP សម្រាប់វិស័យរៀងៗខ្លួន ដូច្នេះជាការរួមចំណែកទៅក្នុងកិច្ចប្រឹងប្រែងដែលមានការសម្របសម្រួលគ្នាមួយ សម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។

ក្រសួងបរិស្ថានបានរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(CCAP)នេះ តាមគោលការណ៍ណែនាំពីទីស្តីការគណៈរដ្ឋមន្ត្រីនិងការគាំទ្រពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(NCSD) និងការគាំទ្របច្ចេកទេសពីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)។ ដំណើរការរៀបចំ CCAP រួមបញ្ចូលការពិគ្រោះយោបល់ជាមួយនាយកដ្ឋានបច្ចេកទេសទាំងអស់ និងជាមួយដៃគូអភិវឌ្ឍន៍នានា ការប្រើប្រាស់ព័ត៌មាន និងរបកគំហើញពីការស្រាវជ្រាវ និងការវាយតម្លៃនានាដែលផ្តោតលើបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ការបន្សីខាងបច្ចេកទេសនិងគោលនយោបាយ ជាមួយផែនការប្រចាំឆ្នាំរបស់ក្រសួងបរិស្ថាន ឯកសារគោលនយោបាយ និងផែនការពាក់ព័ន្ធនានា សម្រាប់វិស័យនេះ ក៏ដូចជា គោលដៅអភិវឌ្ឍន៍ជាតិ គឺស្នូលនៃដំណើរការរៀបចំ CCAPផងដែរ។

ផែនការ CCPA បច្ចុប្បន្ននេះ កំណត់សកម្មភាពជាក់លាក់ និងធនធានដែលចាំបាច់សម្រាប់ដាក់ឱ្យអនុវត្តវិធានការរបស់ក្រសួងបរិស្ថានឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ឆ្នាំ 2016-2018។ ទិសដៅរួមដែលមានចែង មិនត្រឹមតែអំពីអភិបាលកិច្ចការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែអំពីបញ្ហាពាក់ព័ន្ធដទៃទៀតមួយចំនួនផងដែរ ដែលរួមទាំង កិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍដោយចីរភាព ការអភិវឌ្ឍបៃតង និងអប់រំនិងផ្សព្វផ្សាយអំពីបរិស្ថាន ក៏ដូចជា ការពាក់ព័ន្ធនឹងការចរចាអន្តរជាតិអំពីការប្រែប្រួលអកាសធាតុ និងកាប្តេជ្ញានៅក្រោមអនុសញ្ញា UNFCCCផងដែរ។

*ស្ថានភាព*

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចគាំពារបរិស្ថាន និងការប្រែប្រួលអាកាសធាតុ នៅក្នុងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា។ ផែនការ NSDP ចែងច្បាស់ថា ការគ្រប់គ្រងបរិស្ថាននិងការប្រែប្រួលអាកាសធាតុ បានក្លាយជាការប្រឈមមួយសម្រាប់និរន្តរភាពនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមកម្ពុជា ដោយសារតែសម្ពាធពីកំណើនប្រជាជន នគរូបនីយកម្ម ការពង្រីកកសិកម្មនិងប្រពលវប្បកម្មកសិកម្ម ក៏ដូចជា ការដឹកជញ្ជូន ថាមពល និងវិស័យដទៃទៀតផងដែរ។ បញ្ហាបរិស្ថានជាច្រើន មានលក្ខណៈអន្តរវិស័យ ដូច្នេះទាមទារឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ក្នុងចំណោមស្ថាប័នរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធទាំងអស់ផងដែរ។

បញ្ហាបរិស្ថាន ការបាត់បង់ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុកំពុងរារាំងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព។ យោងតាម CCCSP អាកាសធាតុនៅកម្ពុជាបានចាប់ផ្តើមប្រែប្រួលរួចមកហើយ ក្នុងនោះការធ្វើនិទស្សន៍បានចង្អុលបង្ហាញពីការប្រែប្រួលជាច្រើននៃរបបអាកាសធាតុទៅអនាគត។ ឧទាហរណ៍ ការនិទស្សន៍នានាបង្ហាញអំពីកំណើនសីតុណ្ហភាពមធ្យមប្រចាំខែរវាង 0,013°C និង 0,036°C ក្នុងមួយឆ្នាំៗ រហូតដល់ឆ្នាំ 2099 និងកំណើនកម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ។ ការព្យាករណ៍ទាំងនេះបង្ហាញពីកិច្ចប្រឹងប្រែងខុសៗគ្នានៅទូទាំងប្រទេសកម្ពុជា ជាមួយការរំពឹងថានឹងមានកំណើនការធ្លាក់ភ្លៀងរវាងខែមិថុនា និងសីហា នៅភាគនិរតីនៃផ្ទៃប្រទេស ទន្ទឹមនឹងការថយចុះកម្ពស់ទឹកភ្លៀងដែលរំពឹងថានឹងកើតមាននៅភាគឦសានផងដែរ។ ការធ្វើនិទស្សន៍នានាក៏បង្ហាញពីការប៉ះពាល់មកលើតំបន់ឆ្នេរ ជាមួយកំណើននីវ៉ូទឹកសមុទ្ររវាង 0,18ម ដល់ 0,56ម រហូតដល់ឆ្នាំ 2090 ផងដែរ ដោយអាស្រ័យលើសេណារីយ៉ូនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ឧទាហរណ៍ ឆ្នេរសមុទ្រកម្ពុជាប្រវែង 435គ.ម ងាយរងគ្រោះដោយសារកំណើនកម្ពស់ទឹកសមុទ្រ ជាមួយការបាត់បង់ដែលត្រូវបានរំពឹងថានឹងមានប្រមាណ 25.000ហ.ត នៃដែនដីឆ្នេរសមុទ្រ ដោយសារតែការជន់លិចជាប្រចាំនៅក្នុងរយៈពេល 90 ឆ្នាំខាងមុខ។ នៅក្រោមសេណារីយ៉ូកំណើននីវ៉ូទឹកសមុទ្រ 0,56 ម ជាមួយផលប៉ះពាល់ធ្ងន់ធ្ងរមកលើវិស័យទេសចរណ៍។

ការប្រែប្រួលអាកាសធាតុនៅកម្ពុជាក៏មានការពាក់ព័ន្ធជាច្រើនខាងបរិស្ថាន និងសេដ្ឋកិច្ចផងដែរ។ ព្យុះទីផុងត្រូវបានរំពឹងថានឹងកើតមានកាន់តែញឹកញាប់ និងបង្កការខូចខាតកាន់តែច្រើនឡើងចំពោះលំនៅឋានក្នុងតំបន់ឆ្នេរ។ លើសពីនេះ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើជីវៈចម្រុះនៅកម្ពុជាក៏នៅពុំទាន់បានកំណត់នៅឡើយ ប៉ុន្តែទំនងជានាំឱ្យមានការប្រែប្រួលជាច្រើនចំពោះសុខភាពនៃប្រព័ន្ធអេកូឡូស៊ី និងចំពោះសហគមន៍នៅតាមជនបទ ដែលពឹងផ្អែកលើធនធានធម្មជាតិសម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន។ ការប្រែប្រួលរបបទឹកត្រូវ ត្រូវបានរំពឹងថានឹងបង្កការប៉ះពាល់ធ្ងន់ធ្ងរមកលើប្រព័ន្ធផលិតកម្មស្បៀង ដូចជា វិស័យកសិកម្ម និងជលផល ក្នុងនោះតំបន់ទំនាបកណ្តាល ដែលរួមទាំង បឹងទន្លេសាបនឹងជួបប្រទះការប្រែប្រួលកាន់តែខ្លាំងក្លាផងដែរ។

***កម្មវិធីអាទិភាពរបស់ក្រសួងបរិស្ថាន***

ជាមួយអាណត្តិសម្របសម្រួលវិធានការរបស់ជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងនៅក្នុងបរិបទនៃកិច្ចប្រឹងប្រែងកែទម្រង់ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជាដែលកំពុងអនុវត្ត ថ្មីៗនេះក្រសួងបរិស្ថានបានធ្វើការកែប្រែរចនាសម្ព័ន្ធដើម្បីឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាពទៅនឹងការប្រឈមនាពេលបច្ចុប្បន្នចំពោះកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាព។ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ 55 ខែឧសភា ឆ្នាំ2015 ស្តីពីការចាត់តាំងនិងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន និងព្រះរាជក្រឹត្យលេខ 403 ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

ជាមួយការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលជាអង្គភាពពហុវិស័យមួយជាមួយអាណត្តិសម្របសម្រួលវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការបង្កើតអគ្គលេខាធិការដ្ឋានរបស់ខ្លួននៅក្នុងក្រសួងបរិស្ថាន ក្រសួងនេះបន្តដើរតួនាទីគន្លឹះនៅក្នុងការសម្របសម្រួលវិធានការរបស់ជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ នាយកដ្ឋានប្រែប្រួលអាកាសធាតុ ដែលជាផ្នែកមួយនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពសម្រាប់បញ្ហាប្រែប្រួលអាកាសធាតុ បានដឹកនាំកិច្ចប្រឹងប្រែងខាងបច្ចេកទេស ដែលទាក់ទងនឹងការរៀបចំ CCCSP ក៏ដូចជា ផែនការ CCAP នេះ ដែលជួយវិស័យនានាផងដែរក្នុងការរៀបចំ និងការអនុវត្ត CCAP។

រចនាសម្ព័ន្ធបច្ចុប្បន្នរបស់ MoE ត្រូវបានបន្សុីគ្នាជាមួយអាទិភាពសំខាន់ៗដែលបានកំណត់សម្រាប់វិស័យនេះ ពោលគឺ 1) កិច្ចគាំពារបរិស្ថាន 2) ការគ្រប់គ្រងតំបន់ការពារធម្មជាតិ 3) ការអភិវឌ្ឍដោយចីរភាព (ដែលរួមទាំង ការអប់រំ និងព័ត៌មានបរិស្ថាន) និង 4) អភិបាលកិច្ចល្អ។ ឥឡូវនេះ វិស័យទាំងនេះឆ្លើយតបទៅនឹងកម្មវិធីអាទិភាពទាំងបួននៃផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងបរិស្ថានឆ្នាំ 2016-2018។ កម្មវិធីទាំងបួននេះ និងអនុកម្មវិធីទាំងអស់ មានបង្ហាញជូននៅក្នុងប្រអប់ 1។

ប្រអប់ 1: កម្មវិធីអាទិភាព និងអនុកម្មវិធីរបស់ក្រសួងបរិស្ថាន

**កម្មវិធីអាទិភាព 1:** កិច្ចគាំពារបរិស្ថាន

1.1. ការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់ សំឡេង និងរំញ័រ
1.2. ការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកសាធារណៈ
1.3. ការគ្រប់គ្រងសារធាតុគ្រោះថ្នាក់បរិស្ថាន
1.4. ការត្រួតពិនិត្យលើការប្រតិបត្តិការគ្រប់គ្រងសំណល់រឹង ទីប្រជុំជន រាជធានី ខេត្ត
1.5. ការពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋាន ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន
1.6. វិភាគ និងតេស្តសំណល់ និងសារធាតុបំពុលផ្សេងៗ
1.7. អង្កេត ពិនិត្យវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
1.8. សេវាគាំទ្រកិច្ចគាំពារបរិស្ថាន

**កម្មវិធីអាទិភាព 2:** ការគ្រប់គ្រងតំបន់ការពារធម្មជាតិ

2.1. ការអភិរក្សធនធាន និងបេតិកភណ្ឌធម្មជាតិក្នុងតំបន់ការពារធម្មជាតិ
2.2. ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
2.3. ការគ្រប់គ្រងតំបន់ដីសើម-ទឹកសាប តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់ឆ្នេរ និងតំបន់សមុទ្រ
2.4. សេវាគាំទ្រការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ

**កម្មវិធីអាទិភាព 3:** ការគ្រប់គ្រងការអភិវឌ្ឍដោយចីរភាព (ដែលរួមទាំង ការអប់រំបរិស្ថាន និងព័ត៌មានបរិស្ថាន)

3.1. ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងលើកកម្ពស់ការអនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
3.2. ជំរុញការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
3.3. ការគ្រប់គ្រងជីវៈចម្រុះ
3.4. លើកកម្ពស់ចំណេះដឹង និងព័ត៌មានបរិស្ថាន

**កម្មវិធីអាទិភាព 4:** ការពង្រឹងអភិបាលកិច្ចល្អ

4.1. បង្កើនប្រសិទ្ធភាពនៃដំណើរការរដ្ឋបាល និងការផ្តល់សេវាសាធារណៈ
4.2. ការគ្រប់គ្រង និងបណ្តុះបណ្តាល ធនធានមនុស្ស
4.3. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
4.4. ការងារផែនការ ថវិកា កិច្ចការអន្តរជាតិ វិមជ្ឈការ និងសហវិមជ្ឈការ
4.5. ការបញ្ជ្រាបយេនឌ័រ យុវជន និងកុមារក្នុងវិស័យបរិស្ថាន
4.6. ការងារអធិការកិច្ច និងសវនកម្ម

## 2. ផែនការសកម្មភាព

### *វិសាលភាពនៃផែនការសកម្មភាពប្រែប្រួលអាកាសធាតុ*

ដើម្បីលើកកម្ពស់ការអនុវត្តទិសដៅជាយុទ្ធសាស្ត្រនៃផែនការ CCCSP 2014-2023 ក្រសួងបរិស្ថានបានរៀបចំផែនការសកម្មភាពប្រែប្រួលអាកាសធាតុសម្រាប់ឆ្នាំ 2016-2018 ដោយបន្សីគ្នាជាមួយអាណត្តិរបស់ក្រសួង និងអគ្គលេខាធិការដ្ឋាន NCSD។ ផែនការសកម្មភាពឆ្លើយតបនឹងប្រែប្រួលអាកាសធាតុ(CCAP) ចែងពីសកម្មភាពអាទិភាពសំខាន់ៗសម្រាប់អគ្គនាយកដ្ឋានបីនៃក្រសួងបរិស្ថានពោលគឺ អគ្គនាយកដ្ឋានព័ត៌មាននិងអប់រំបរិស្ថាន អគ្គនាយកដ្ឋានគាំពារបរិស្ថាន និងរដ្ឋបាលការពារអភិរក្សធម្មជាតិ តាមរយៈអគ្គនាយកដ្ឋានទាំងនេះ ផែនការនេះអាចគាំទ្រដល់ការអនុវត្ត CCCSP។ ផែនការនេះក៏ចែងច្បាស់ដែរនូវការណែនាំអំពីសកម្មភាពជាអាទិភាពសំខាន់ៗសម្រាប់អគ្គលេខាធិការដ្ឋាន NCSD សម្រាប់នាយកដ្ឋានប្រែប្រួលអាកាសធាតុ ក៏ដូចជា នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នាយកដ្ឋានសេដ្ឋកិច្ចបៃតង និងនាយកដ្ឋានជីវៈចម្រុះផងដែរ។

ការពិភាក្សាផ្ទៃក្នុងអំពីវិភាគទានជាយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថាននៅក្នុងការអនុវត្ត CCCSP បានចាប់ផ្ដើមនៅឆ្នាំ 2013 ហើយបានបន្តនៅក្នុងរយៈពេលភាគច្រើននៃឆ្នាំ2014។ អគ្គនាយកដ្ឋានទាំងអស់បានរួមចំណែកយ៉ាងសកម្មនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនេះ ដែលដឹកនាំដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដែលនៅពេលនោះមានអាណត្តិសម្របសម្រួលការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ជាលទ្ធផល តារាងវែងមួយអំពីសកម្មភាពនានាដែលក្រសួងបរិស្ថានអាចយកទៅអនុវត្ត មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ 1។

នៅឆ្នាំ 2015 បន្ទាប់ពីកំណែទម្រង់ស្ថាប័នរបស់ក្រសួងបរិស្ថាន និង NCCC ដែលនាំឱ្យមានកំណែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួងនេះ និងការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) នៅខែឧសភា ការងារជាបន្តរបស់ក្រសួងគឺរៀបចំ CCAP ដើម្បីធានាថា ផែនការនេះមានលក្ខណៈស្របគ្នាជាមួយទាំងរចនាសម្ព័ន្ធថ្មីនៃស្ថាប័ននេះសម្រាប់ការប្រែប្រួលអាកាសធាតុ និងបរិស្ថាន និងជាមួយ CCCSP (2018-2023)ផងដែរ។

តារាងខ្លីមួយអំពីសកម្មភាពសំខាន់ៗដើម្បីរួមបញ្ចូល CCAP របស់ក្រសួងបរិស្ថានសម្រាប់អំឡុងឆ្នាំ 2016-2018 ត្រូវបានរៀបចំឡើង ដោយពិចារណាផងដែរពីការពិភាក្សានានាកន្លងមក អាណត្តិបច្ចុប្បន្នរបស់ក្រសួងបរិស្ថាន និង NCSD និងអាទិភាពនានាដែលមានបង្ហាញនៅក្នុងផែនការថវិកាយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថានសម្រាប់ឆ្នាំ 2016-2018 និងមានបង្ហាញនៅក្នុងជំពូកបន្ទាប់នៃតារាង 1 (តារាងផែនការសកម្មភាព)។

### *តារាងផែនការសកម្មភាព*

តារាងទី 1 មានសកម្មភាពអាទិភាពសរុបចំនួន 17 ដែលក្រសួងបរិស្ថានត្រូវអនុវត្តនៅក្នុងអំឡុងឆ្នាំ 2016-2018 ដែលតំណាងឱ្យវិភាគទានរបស់ក្រសួងបរិស្ថានទៅក្នុងដំណាក់កាលដំបូងនៃការអនុវត្ត CCCSP។ តារាងនេះបង្ហាញវិភាគទាននៃសកម្មភាពទាំងនេះទៅក្នុងគោលបំណងយុទ្ធសាស្ត្រខុសៗគ្នានៃ CCCSP ដែលបង្ហាញផងដែរពីថ្លៃប៉ាន់ស្មានការចំណាយ និងនាយកដ្ឋានដែលទទួលខុសត្រូវលើការអនុវត្តសកម្មភាពទាំងនោះ។

នៅក្នុងការកំណត់អត្តសញ្ញាណសកម្មភាពនានាដែលរួមបញ្ចូលនៅក្នុង CCAP លើកទីមួយនេះ កម្មវិធី និងគម្រោងនានាដែលមានស្រាប់ ដែលបានបង្កើតឡើងដើម្បីពង្រឹងសមត្ថភាពស្ថាប័នសម្រាប់អនុវត្តការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក៏ត្រូវបានគិតបញ្ចូលផងដែរ និងក្នុងករណីសមស្រប គម្រោង និងកម្មវិធីទាំងនោះត្រូវបានរួមបញ្ចូលទៅក្នុងផែនការសកម្មភាពដែលមានស្រាប់

ដូច្នេះបានផ្អែកលើកិច្ចប្រឹងប្រែង និងភាពជាដៃគូនានាដែលមានស្រាប់។ សកម្មភាពទាំងនេះខ្លះត្រូវបានរំពឹងថានឹងត្រូវបន្តហួសឆ្នាំ 2018 ហើយការបន្តពិនិត្យតាមដាន និងវាយតម្លៃដែលគ្រោងធ្វើឡើងនៅពាក់កណ្តាលឆ្នាំ 2018 នឹងកំណត់ជាការសម្រេចចុងក្រោយ។

សម្រាប់សកម្មភាពនីមួយៗនៅក្នុងចំណោមសកម្មភាពទាំង 17 នៃ CCAP សន្លឹកព័ត៌មានអំពីសកម្មភាព( ឧបសម្ព័ន្ធ 2) មានផ្តល់ជូននូវ ព័ត៌មានបន្ថែម ដែលរួមទាំង ហេតុផល ជាតុចេញដែលរំពឹងទុក សូចនាករ និងលក្ខខណ្ឌនានាដើម្បីទទួលជោគជ័យ ការចាត់ចែងស្ថាប័នសម្រាប់ការអនុវត្ត ថ្លៃចំណាយ និងប្រភពមូលនិធិដែលអាចមាន ក៏ដូចជា មូលនិធិដែលបានកៀរគររួចមកហើយពីថវិកាជាតិ និងពីប្រភពខាងក្រៅ។ ថ្លៃប៉ាន់ស្មានកាន់តែសុក្រិត និងព័ត៌មានបន្ថែមអំពីប្រភពមូលនិធិដែលមានសក្តានុពល និងកម្រិតហិរញ្ញប្បទាន ក៏ដូចជាសេចក្តីពិស្តាអំពីបច្ចេកទេស នឹងត្រូវធ្វើបច្ចុប្បន្នភាពនៅមុនការអនុវត្តសកម្មភាពនីមួយៗ ឬនៅក្នុងអំឡុងពេលនៃការរៀបចំសំណើសម្រាប់ការកៀរគរធនធាន។

**តារាងទី 1: សកម្មភាពសំខាន់ៗឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ឆ្នាំ 2016-2018**

| ល.រ | សកម្មភាព | ទាយកដ្ឋាន ទទួលខុសត្រូវ | ថវិកាប៉ាន់ស្មាន | | | |
|---|---|---|---|---|---|---|
| | | | *2016* | *2017* | *2018* | *សរុប* |
| **ទិសដៅជាយុទ្ធសាស្ត្រ 1: លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល (FWE)** | | | | | | |
| 1. | បង្កើតមណ្ឌលបច្ចេកវិទ្យាបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុដើម្បីសន្តិសុខស្បៀង ទឹក និងថាមពល | DST | | | | 635.000 |
| **ទិសដៅជាយុទ្ធសាស្ត្រ 2: កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាពនៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ** | | | | | | |
| 2. | ធ្វើការវាយតម្លៃភាពងាយរងគ្រោះនៅថ្នាក់ជាតិ និងតាមវិស័យ | DCC | | | | មិនទាន់កំណត់ |
| **ទិសដៅជាយុទ្ធសាស្ត្រ 3: លើកកម្ពស់ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌** | | | | | | |
| 3. | ធ្វើការវាយតម្លៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើជីវៈចម្រុះ និងសាកល្បងជម្រើសនានានៃការគ្រប់គ្រងដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | GDNCPA | | | | 2.300.000 |
| 4. | រៀបចំការសិក្សាបឋមដើម្បីបង្កើតគណនេយ្យមូលធនធម្មជាតិ | DGE | | | | 120.000 |
| **ទិសដៅជាយុទ្ធសាស្ត្រ 4: លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព** | | | | | | |
| 5. | បង្កើតប្រព័ន្ធសារពើភណ្ឌ ឧស្ម័នផ្ទះកញ្ចក់ ជាតិ និងរៀបចំធាតុចូលសម្រាប់ BURs | DCC | | | | 450.000 |
| 6. | សម្រួលដល់ការកាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ តាមរយៈគម្រោង និងកម្មវិធីយន្តការផ្តល់ហិរញ្ញវត្ថុកាបូន | DCC | | | | 385.000 |
| 7. | បង្កើត និងសាកល្បងអភិក្រម និងជម្រើសបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុសម្រាប់ទីប្រជុំជន | DGE | | | | 3.800.000 |
| **ទិសដៅជាយុទ្ធសាស្ត្រ 5: កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹង សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ** | | | | | | |
| 8. | បង្កើតប្រព័ន្ធគ្រប់គ្រងចំណេះដឹងអំពី ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង | DCC | | | | 615.000 |
| 9. | ដាក់បញ្ចូល CC និងបញ្ហាបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅគ្រប់លំដាប់ថ្នាក់ | DCC | | | | 450.000 |
| 10. | ការចូលរួម និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ និងអភិវឌ្ឍន៍បៃតងរួមទាំងការប្រើប្រាស់និងផលិតកម្មដោយចីរភាព ឱ្យដល់ | DCC; DGE | | | | 600.000 |

| | | | | | | |
|---|---|---|---|---|---|---|
| | ក្រុមគោលដៅផ្សេងៗ | | | | | |
| **ទិសដៅជាយុទ្ធសាស្ត្រ 6: លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សុំានឹងការប្រែប្រួលអាកាសធាតុដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត** | | | | | | |
| 11. | លើកកម្ពស់ និងកែលម្អសមត្ថភាពបន្សាំរបស់សហគមន៍ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | DCC | | | | 2.500.000 |
| **ទិសដៅជាយុទ្ធសាស្ត្រ 7: ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួលសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ** | | | | | | |
| 12. | ប្រកាសឱ្យប្រើប្រាស់ និងអនុវត្តប្រព័ន្ធ M&E នៅថ្នាក់ជាតិ និងតាមវិស័យ | DCC; DAPF | | | | 215.000 |
| 13. | ការកសាងសមត្ថភាពស្ថាប័នជាតិ សម្របសម្រួលការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | DCC | | | | 5.000.000 |
| 14. | គាំទ្រដល់ក្រសួងពាក់ព័ន្ធដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងការលើកគម្រោងថវិកា | DCC | | | | 8.000.000 |
| 15. | ពង្រឹងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តនានាសម្រាប់ការអភិវឌ្ឍដែលបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុ | DCC | | | | 100.000 |
| 16. | បង្កើតក្របខ័ណ្ឌជាតិហិរញ្ញវត្ថុកាបូន | DCC | | | | 1.000.000 |
| **ទិសដៅជាយុទ្ធសាស្ត្រ 8: ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងពិភពលោក** | | | | | | |
| 17. | ការរៀបចំរបាយការណ៍សម្រាប់ UNFCCC ទៅក្នុងក្របខ័ណ្ឌស្ថាប័ន | DCC | | | | 1.500.000 |
| **តម្លៃប៉ាន់ស្មានសរុប** | | | | 27,7 លាន (*សកម្មភាព 2 មិនទាន់កំណត់ថ្លៃចំណាយ) | | |

*អត្ថប្រយោជន៍រំពឹងទុកពីការអនុវត្តនេះ*

ផែនការ CCAP នឹងពង្រឹងតួនាទីសម្របសម្រួលរបស់ក្រុមប្រឹក្សា NCSD ជាស្ថាប័នអន្តរក្រសួង ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ។ ផែនការ CCAP ក៏នឹងបង្កើតឱ្យមានការអនុវត្តដែលផ្អែកលើភស្តុតាងផងដែរ សម្រាប់អន្តរាគមន៍ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅអនាគត តាមរយៈការអប់រំបរិស្ថាន កិច្ចគាំពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ។

## 3. យន្តការគ្រប់គ្រង និងហិរញ្ញប្បទាន

*យន្តការគ្រប់គ្រង និងហិរញ្ញប្បទានដែលមានស្រាប់*

### ក. រចនាសម្ព័ន្ធគ្រប់គ្រង

រូបទី 1 និង 2 ខាងក្រោមបង្ហាញពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

រូបទី១៖ រចនាសម្ព័ន្ធរបស់ក្រសួងបរិស្ថាន




រូបទី២៖ រចនាសម្ព័ន្ធរបស់ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព



### ខ. ការលើកថវិការបស់ក្រសួងបរិស្ថាន

ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ បានអនុម័តថវិកាចំនួន 17.360.000.000 រៀល សម្រាប់ក្រសួងបរិស្ថាន សម្រាប់ឆ្នាំ 2013 និងហិរញ្ញវត្ថុបន្ថែមចំនួន 849.300.000 រៀល ដែលបានស្នើនៅក្រោមជំពូកថវិកា 64 ដូច្នេះក្រសួងមានថវិកាអនុម័តសរុបចំនួន 18.209.300.000 រៀល។ ការផ្ទេរជាក់ស្តែងគឺ 17.221.401.000 រៀល ដែលត្រូវជា 94,57% នៃថវិកាគ្រោងសម្រាប់ឆ្នាំនោះ។

នៅក្នុងអំឡុងពេលនោះ ក្រសួងបរិស្ថានបានគ្រប់គ្រងគម្រោងមួយចំនួនដែលទទួលមូលនិធិពីប្រភពខាងក្រៅ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ក្នុងទឹកប្រាក់សរុបប្រមាណ 4,5 លានដុល្លាអាមេរិក។

ហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ មានប្រមាណមួយភាគបីនៃធនធានសរុបដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលភាគច្រើនតាមរយៈកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (3,4 លានដុល្លា ដែលបានចំណាយនៅក្នុងឆ្នាំ 2013)។

គួរកត់សំគាល់ផងដែរថា រហូតដល់ឆ្នាំ 2015 ក្រសួងបរិស្ថានមិនអាចធ្វើការគណនាចំនួនជាក់ស្តែងដែលក្រសួងបានចំណាយលើការងារប្រែប្រួលអាកាសធាតុឡើយ ដោយសារពុំមានផែនការសកម្មភាពប្រែប្រួលអាកាសធាតុច្បាស់លាស់សម្រាប់ក្រសួងបរិស្ថាន និងពុំមានថវិកាតាមកម្មវិធី។ ក្រសួងបរិស្ថានចាត់ចែងឱ្យមានការលើកថវិកាសម្រាប់កម្មវិធី ដែលចាប់ផ្តើមនៅឆ្នាំ 2016 ដែលរាប់បញ្ចូលអនុកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុ (593 លានរៀល) និងកម្មវិធីមួយទៀតស្តីពីសេដ្ឋកិច្ចបៃតង (1.453 លានរៀល)។

### គ. យន្តការកៀរគរហិរញ្ញវត្ថុ

ក្រៅពីថវិកាជាតិ ក្រសួងបរិស្ថានបានបង្កើតភាពជាដៃគូជាមួយម្ចាស់ជំនួយមួយចំនួនលើបញ្ហាប្រែប្រួលអាកាសធាតុ។ ក្រុមការងារមួយត្រូវបានបង្កើតនៅក្រោមក្រសួងបរិស្ថាន និងដឹកនាំដោយនាយខុទ្ទកាល័យ ដើម្បីអភិវឌ្ឍន៍ភាពជាដៃគូក្រសួងបរិស្ថាន-ម្ចាស់ជំនួយជាបន្ថែមទៀត។

*ប្រភពដែលមានសក្តានុពល និងទំហំនៃហិរញ្ញវត្ថុសម្រាប់សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ*

ផែនការ CCAP បច្ចុប្បន្ននេះ ត្រូវបានប៉ាន់ស្មានអំពីតម្រូវការរវាង 28 និង 30 លានដុល្លាអាមេរិក សម្រាប់អំឡុងពេលបីឆ្នាំ។

មួយភាគធំនៃមូលនិធិនេះសម្រាប់ផែនការ CCAP នឹងត្រូវបានទទួលហិរញ្ញវត្ថុតាមរយៈដៃគូអភិវឌ្ឍន៍បច្ចុប្បន្ននៃក្រសួងបរិស្ថាន។ គំរូសហប្រតិបត្តិការពហុម្ចាស់ជំនួយ ជាអាទិ៍ SIDA, UNDP និង EU កំពុងគាំទ្រដល់សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ជាមួយមូលនិធិសរុបបច្ចុប្បន្ននេះដែលមានចំនួន 12,8 លានដុល្លាអាមេរិក សម្រាប់ឆ្នាំ 2014-19។ មូលនិធិពិភពលោក/មូលនិធិដែលផ្តោតលើការប្រែប្រួលអាកាសធាតុ ពោលគឺ CIF, GEF, LCDF, AF, FCPFនិងUN-REDD កំពុងគាំទ្រគម្រោងនានានៅក្នុងក្រសួងបរិស្ថាន ដូចជា CIF ផ្តល់ហិរញ្ញប្បទានដល់ក្រសួងបរិស្ថាន តាមរយៈ ADB លើគម្រោង SPCR។ មូលនិធិពិភពលោក/មូលនិធិដែលផ្តោតលើការប្រែប្រួលអាកាសធាតុ ត្រូវបានរំពឹងថានឹងដើរតួកាន់តែសំខាន់នៅពេលដែលទំហំនៃមូលនិធិគាំទ្រកាន់តែមានធំជាងមុន។ លើសពីនេះ ដៃគូទ្វេភាគីសំខាន់ៗដែលគាំទ្រដល់ក្រសួងបរិស្ថានលើការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរួមមាន៖ អាល្លឺម៉ង់ (តាមរយៈ GIZ), USAID, JICA, KOICA, UKAID, និង SIDA។

*ចំណុចចាប់ផ្តើមសម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការគ្រប់គ្រង និងហិរញ្ញប្បទាន*

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ជាពិសេស នាយកដ្ឋានប្រែប្រួលអាកាសធាតុ នឹងគាំទ្រដល់នាយកដ្ឋានផែនការ និងនាយកដ្ឋានបច្ចេកទេសនានា ដើម្បីធានាថា សកម្មភាពនានាត្រូវបានបន្សុីគ្នាជាមួយផែនការការងាររបស់ក្រសួងនេះ។ ការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ផែនការ CCAP មានអធិប្បាយនៅក្នុងជំពូកបន្ទាប់។

ក្រុមអ្នករៀបចំផែនការ CCAP នឹងធ្វើការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីកសាងភាពម្ចាស់ការលើសកម្មភាពទាំងនេះបន្ថែមទៀត។ សកម្មភាពនីមួយៗនឹងមានចែងពិស្តារនៅក្នុងសកម្មភាព ឬ កម្មវិធីការងារសម្រាប់ការិយាល័យនានានៅក្រោមនាយកដ្ឋានពាក់ព័ន្ធ និងរួមបញ្ចូលនៅក្នុងផែនការការងារប្រចាំឆ្នាំសម្រាប់នាយកដ្ឋានពាក់ព័ន្ធ និងបន្ទាប់មកបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងបរិស្ថាន។

ឱកាសភាពមូលនិធិសម្រាប់ការអនុវត្តនឹងត្រូវលើកយកមកពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍។

## 4. ការតាមដាន និងវាយតម្លៃ

ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ផែនការ CCAP នេះ ត្រូវបានបន្សុីគ្នាជាមួយក្រុមខ័ណ្ឌ M&E សម្រាប់ការប្រែប្រួលអាកាសធាតុកម្ពុជា និងជាមួយផែនការ NSDP (ដោយរួមបញ្ចូលសូចនាករទាំងបួនស្តីពីការប្រែប្រួលអាកាសធាតុ)។ ក្របខ័ណ្ឌនេះគ្របដណ្តប់សូចនាករសំខាន់ចំនួនបួនបែប ដែលនឹងត្រូវវាស់វែងជារៀងរាល់ឆ្នាំ៖

1. **ការអនុវត្ត CCAP** – តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការ CCAP របស់ក្រសួងបរិស្ថាន
2. **ការត្រៀមលក្ខណៈខាងស្ថាប័ន** – តាមដានវឌ្ឍនភាពលើការកែលម្អសមត្ថភាពស្ថាប័ន ដែលរួមទាំង សមត្ថភាពក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយជារួម និងបរិធានរៀបចំផែនការរបស់ក្រសួងបរិស្ថាន
3. **សូចនាករលទ្ធផល** - តាមដានវឌ្ឍនភាពក្នុងការសម្រេចបានលទ្ធផលរំពឹងទុកនៅក្នុងផ្នែកជាយុទ្ធសាស្ត្រទាំង 17
4. **សូចនាករឥទ្ធិពល** - តាមដានឥទ្ធិពលជារួមក្នុងគោលដៅអភិវឌ្ឍន៍សម្រាប់ប្រទេសទាំងមូល ( ផ្សារភ្ជាប់នឹងសូចនាករNSDP)

គួរកត់សំគាល់ថា ទោះបីមានលក្ខណៈត្រួតគ្នាខ្លះៗជាមួយផ្នែកក្របខ័ណ្ឌM&E នៃសូចនាករអំពីការត្រៀមលក្ខណៈខាងស្ថាប័ន និងសូចនាករលទ្ធផលក៏ដោយ សូចនាករការអនុវត្ត CCAP ផ្តល់ជាសេចក្តីសង្ខេបរួមមួយអំពីជោគជ័យរបស់ក្រសួងបរិស្ថាននៅក្នុងការអនុវត្ត CCAP និងក៏ជួយសម្រួលឱ្យមានការប្រៀបធៀបផងដែរជាមួយការអនុវត្ត CCAP នៅក្នុងចំណោមវិស័យនានា។

សូចនាករទាំងមូលដែលជាផ្នែកមួយនៃក្របខ័ណ្ឌ M&E នៃផែនការ CCAP មានបង្ហាញជូនក្នុងតារាងទី 2 ខាងក្រោម។

**តារាងទី 2: ក្របខ័ណ្ឌសូចនាករសម្រាប់ប្រព័ន្ធ M&E នៃ CCAP របស់ក្រសួងបរិស្ថាន**

| ប្រព័ន្ធ M&E លើ CCAP នៃក្រសួងបរិស្ថាន | |
|---|---|
| សូចនាករ | ឯកត្តា |
| **1. ការអនុវត្ត CCAP** | |
| មូលនិធិសរុបដែលបានកៀរគរ/ថវិកាសរុបសម្រាប់ CCAP | % |
| សកម្មភាពដែលមានមូលនិធិគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការចំណាយ | ចំនួន |
| កម្រិតនៃការរួមបញ្ចូលសកម្មភាពពី CCAP ទៅក្នុង PIPs | ចំនួន |
| កម្រិតនៃការពាក់ព័ន្ធរបស់ MoE នៅក្នុងការអនុវត្ត CCAP | ចំនួន |
| **2. ការត្រៀមលក្ខណៈខាងស្ថាប័ន** | |
| ស្ថានភាពនៃការរៀបចំគោលនយោបាយបរិស្ថាន និងការរៀបចំផែនការ | % (វិធីសាស្ត្រកាំជណ្តើរ) |

| | | |
|---|---|---|
| | ការសម្របសម្រួលវិធានការឆ្លើយតបនឹង CC និងការអនុវត្ត CCAP | % (វិធីសាស្ត្រកាំជណ្ដើរ) |
| | ស្ថានភាពនៃការគ្រប់គ្រងព័ត៌មានអំពីអាកាសធាតុ | % (វិធីសាស្ត្រកាំជណ្ដើរ) |
| | ការរួមបញ្ចូលការឆ្លើយតបនឹងអាកាសធាតុទៅក្នុងហិរញ្ញប្បទាន | % (វិធីសាស្ត្រកាំជណ្ដើរ) |
| **3. សូចនាករលទ្ធផល** | | |
| **សកម្មភាព 1** | បច្ចេកវិទ្យាសម្រាប់សន្តិសុខ FEW ត្រូវបានអនុវត្តសាកល្បង | ចំនួន |
| **សកម្មភាព 2** | វិសាលភាពគ្របដណ្ដប់ និងវត្តមាននៃការវាយតម្លៃភាពងាយរងគ្រោះ | % (វិធីសាស្ត្រកាំជណ្ដើរ) |
| **សកម្មភាព 3** | ផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ ជាមួយវិធានការបន្សាំ | ចំនួន |
| **សកម្មភាព 4** | ការសន្ទនាអំពីប្រព័ន្ធគណនេយ្យមូលធនធម្មជាតិ | ចំនួន |
| **សកម្មភាព 5** | ការចូលរួមនៃក្រុមការងារបច្ចេកទេសនៅក្នុងសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ | ចំនួន |
| **សកម្មភាព 6** | ដំណើរការនៃមូលនិធិកាត់បន្ថយការបញ្ចេញឧស្ម័ន | % (វិធីសាស្ត្រកាំជណ្ដើរ) |
| **សកម្មភាព 7** | ទីប្រជុំជនដែលមានផែនការអភិវឌ្ឍន៍ទីក្រុង និងកម្មវិធីសម្រាប់ដោះស្រាយ CC | ចំនួន |
| **សកម្មភាព 8** | ការពេញចិត្តចំពោះភតថលចំណេះដឹងអំពី CC របស់ក្រសួងបរិស្ថាន | ចំនួន |
| **សកម្មភាព 9** | គ្រូបង្រៀនបានទទួលការបណ្ដុះបណ្ដាលអំពីកម្មវិធីសិក្សាដែលបានស្នើសម្រាប់បច្ចុប្បន្នភាពអំពីការប្រែប្រួលអាកាសធាតុ | ចំនួន |
| **សកម្មភាព 10** | កិច្ចផ្ដួចផ្ដើមយល់ដឹងអំពី CC បានអនុវត្តរួមគ្នាដោយ MoE និងអ្នកពាក់ព័ន្ធនានា | ចំនួន |
| **សកម្មភាព 11** | ថវិកាពីមូលនិធិឃុំ/សង្កាត់ត្រូវបានបែងចែកសម្រាប់អន្តរាគមន៍ឆ្លើយតបនឹងបញ្ហាអាកាសធាតុនៅក្នុង CIPs | % |
| **សកម្មភាព 12** | ដំណើរការនៃប្រព័ន្ធ M&E អំពី CC | % (វិធីសាស្ត្រកាំជណ្ដើរ) |
| **សកម្មភាព 13** | សមត្ថភាព និងដំណើរការនៃយន្តការជាតិសម្រាប់សម្របសម្រួល CC: អគ្គលេខាធិការដ្ឋាន NCSD, CCTT, TWGs | % (វិធីសាស្ត្រកាំជណ្ដើរ) |
| **សកម្មភាព 14** | ក្រសួងនានាបានរាយការណ៍អំពីការអនុវត្ត CCAP នៅក្នុងសិក្ខាសាលាសិក្សាប្រចាំឆ្នាំនៅថ្នាក់ជាតិរបស់ MoE ស្ដីពី M&E | ចំនួន |
| **សកម្មភាព 15** | ក្រសួងនានាដែលពាក់ព័ន្ធក្នុងការពិនិត្យលិខិតបទដ្ឋានគតិយុត្តិតាមវិស័យ ដោយផ្ដោតលើបញ្ហា CC | ចំនួន |
| **សកម្មភាព 16** | សំណើគម្រោង/កម្មវិធីដែលបានស្នើសុំហិរញ្ញប្បទានអាកាសធាតុនៅក្រោមនីតិវិធីថ្មីសម្រាប់ CF | ចំនួន |
| **សកម្មភាព 17** | ដំណើរការនៃក្រុមធ្វើរបាយការណ៍អំពីអាកាសធាតុ | % (វិធីសាស្ត្រកាំជណ្ដើរ) |
| **4. សូចនាករឥទ្ធិពល** | | |
| **1** | ការយល់ដឹងជាសាធារណៈអំពីបញ្ហា CC | ការអង្កេត KAP |
| **2** | ការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ចំនួន |
| **3** | សន្ទស្សន៍ភាពងាយរងគ្រោះ | - |
| **4** | ឥណទានកាបូនដែលបានផ្ដល់សម្រាប់គម្រោងទូទាត់កាបូន | ចំនួន |

សូចនាករលទ្ធផលបន្ថែមសម្រាប់ការតាមដានវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពជាក់លាក់មានចែងនៅក្នុងសន្លឹកព័ត៌មានអំពីសកម្មភាពដូចមានក្នុងឧបសម្ព័ន្ធ 2។

ការរៀបចំក្របខ័ណ្ឌ M&E អំពី CC របស់ MoE ដែលរួមទាំង លក្ខខណ្ឌគោល និងចំណុចដៅនានា នឹងត្រូវរៀបចំរួចរាល់នៅដើមឆ្នាំ 2016 ដែលជាដំណាក់កាលរៀបចំផែនការ CCAP។

ការវាយតម្លៃចុងក្រោយនឹងត្រូវធ្វើឡើងនៅពាក់កណ្ដាលឆ្នាំ 2018 ដើម្បីផ្ដល់ជាព័ត៌មានសម្រាប់ការរៀបចំ CCAPនៅជុំបន្ទាប់។ ការតាមដាន និងវាយតម្លៃផែនការ CCAP នឹងត្រូវធ្វើឡើងដោយផ្នែក M&E នៃក្រសួងបរិស្ថាន។ ផ្នែកនេះនឹងត្រូវបង្កើតឡើងជាផ្នែកមួយនៃសកម្មភាព 12 នៃផែនការសកម្មភាពនេះ នៅដំណាក់កាលដំបូងនឹងត្រូវមានការិយាល័យនៅក្នុង DCC (អគ្គលេខាធិការដ្ឋាន NCSD សម្រាប់កិច្ចការ CC) និងរួមបញ្ចូលបុគ្គលិកមកពី DCC និង DPB ដែលអនុវត្តមុខងារពិនិត្យតាមដាន និងការរៀបចំរបាយការណ៍អំពី CC និងនៅថ្នាក់ជាតិ។

ទាក់ទងនឹងផែនការ CCAP របស់ក្រសួងបរិស្ថាន ផ្នែក M&E នឹងមានភារៈទទួលខុសត្រូវលើការតាមដាន និងរាយការណ៍ជាទៀងទាត់អំពីការអនុវត្តរបស់ខ្លួន (យ៉ាងហោចណាស់របាយការណ៍អំពី M&E ម្ដងក្នុងមួយឆ្នាំ) ក៏ដូចជា ការចែករំលែកព័ត៌មានជាមួយ MoE ក្រសួងពាក់ព័ន្ធសំខាន់ៗនិងអ្នកពាក់ព័ន្ធដទៃទៀត។ ការទទួលខុសត្រូវទាំងនោះក៏រួមបញ្ចូលការលើកកម្ពស់ការពិភាក្សាជាបរិយាប័ន្ន ដើម្បីស្រង់យកមេរៀនពីការអនុវត្ត CCAPs ពីក្រសួងបរិស្ថាន និងពីវិស័យដទៃទៀតផងដែរ (យ៉ាងហោចណាស់សិក្ខាសាលារៀនសូត្រមួយលើកក្នុងមួយឆ្នាំ)។ ការងាររបស់ពួកគេនឹងអាចឱ្យមានការបន្តសិក្សា និងការកែតម្រូវសកម្មភាពរបស់ខ្លួនបានទាន់ពេលវេលា ដែលអាចជួយឱ្យមានការឆ្លើយតបកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន។

## 5. ច្បាប់ និងបរិធានច្បាប់ដើម្បីគាំទ្រដល់ការអនុវត្ត

ដើម្បីបំពេញអាណត្តិរបស់ក្រសួងបរិស្ថាន បរិធានច្បាប់មួយចំនួនត្រូវបានរៀបចំឡើង ដើម្បីធានាឱ្យមានការគ្រប់គ្រងធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីសំខាន់ៗដោយប្រសិទ្ធភាព ដូចជា បឹងទន្លេសាប ប្រព័ន្ធតំបន់ឆ្នេរ និងសមុទ្រ ក៏ដូចជា សុខភាពបរិស្ថាន និងសុខភាពមនុស្ស ការគ្រប់គ្រងសំណល់ដោយប្រសិទ្ធភាព និងការសម្របសម្រួល និងការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ ឧបសម្ព័ន្ធ 3 មានតារាងស្ដីពីច្បាប់ និងបរិធានច្បាប់នៅក្រោមយុត្តាធិការនៃក្រសួងបរិស្ថាន។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការជាប់ជាប្រចាំ ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងក្របខ័ណ្ឌនិយ័តកម្ម ដោយបន្សុីគ្នាជាមួយការណែនាំច្បាស់លាស់ដែលមានចែងនៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដូចគ្នានេះដែរ ទិសដៅដែលមានចែងក្នុង NSDP 2014-2018 ផ្ដល់សិទ្ធិអំណាចដល់ក្រសួងបរិស្ថានក្នុងការ "រៀបចំក្របខ័ណ្ឌច្បាប់ប្រែប្រួលអាកាសធាតុ ដែលនឹងរួមបញ្ចូលការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធស្ថាប័ន ការចាត់ចែងហិរញ្ញប្បទាន និងបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យនានា"។

របាយការណ៍ស្ដីពីការពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់ការប្រែប្រួលអាកាសធាតុ (2013) បានពិនិត្យមើលក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនានាដែលមានស្រាប់ ដែលពាក់ព័ន្ធជាមួយវិធានរបស់កម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ដែលរួមទាំង៖

- ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (អនុម័តកាលពីដំបូងនៅឆ្នាំ 1996)
- អនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុល ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន(2005) ការគ្រប់គ្រងសំណល់រឹង(1999) ការត្រួតពិនិត្យការបំពុលទឹក និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានាផ្សេងទៀត (ដូចជា ជីវៈចម្រុះ និងការអភិរក្ស ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្ដីពីជីវសុវត្ថិភាព 2008)
- អនុក្រិត្យស្ដីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ដែលបានអនុម័តជាលើកដំបូងនៅឆ្នាំ 1999 និងដែលបច្ចុប្បន្នកំពុងស្ថិតក្នុងការពិនិត្យកែសម្រួល ជាមួយច្បាប់ស្ដីពី EIA ឬ ក្រមបរិស្ថានជារួម ដែលនឹងត្រូវអនុម័ត។

ការសិក្សានេះបានលើកស្នើចំណុចចាប់ផ្តើមនានានៅក្នុងរយៈពេលខ្លី ដូចអ្វីដែលបានកំណត់រកឃើញនៅក្នុងក្រសួងបរិស្ថាន ក៏ដូចជា ចំណុចចាប់ផ្តើមនានាបន្ថែមទៀតនៅក្នុងវិស័យដទៃទៀតនៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងក្របខ័ណ្ឌច្បាប់របស់កម្ពុជាផងដែរ។ នៅក្នុងរយៈពេលវែង ការរៀបចំច្បាប់ក្របខ័ណ្ឌស្តីពីការប្រែប្រួលអាកាសធាតុក៏ត្រូវបានស្នើឡើងផងដែរ។

# 6. សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាពប្រែប្រួលអាកាសធាតុ ផ្តល់ជាការណែនាំរួមមួយដល់ក្រសួងបរិស្ថាន អំពីការអនុវត្តអន្តរាគមន៍ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលនឹងរួមចំណែកដោយផ្ទាល់ចំពោះសមិទ្ធផលនៃគោលដៅ CCCSP។ ទិសដៅនេះក៏ចែងផងដែរអំពីសកម្មភាពជាអាទិភាពនានា ដែលក្រសួងបរិស្ថានត្រូវអនុវត្ត ក្នុងនាមជាអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជាស្ថាប័នបង្គោលជាតិនៃអនុសញ្ញា UNFCCC។

ក្នុងឋានៈជាអគ្គលេខាធិការដ្ឋាននៃ NCSD ក្រសួងបរិស្ថានដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសមត្ថភាពរបស់ប្រទេសនៅគ្រប់លំដាប់ថ្នាក់ដើម្បីឱ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រឈមនានាដែលបង្កដោយការប្រែប្រួលអាកាសធាតុ ការជួយនៅក្នុងការសម្របសម្រួលគ្រប់អន្តរាគមន៍ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលត្រូវអនុវត្តដោយវិស័យនានា ក៏ដូចជា នៅក្នុងការពិនិត្យតាមដាន និងវាយតម្លៃ និងការអនុវត្ត CCCSP ផងដែរ ដែលរួមចំណែកក្នុងការបង្កើនចំណេះដឹងអំពីការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់កម្ពុជាដើម្បីផ្តល់ជាព័ត៌មានកាន់តែប្រសើរថែមទៀតសម្រាប់សកម្មភាពនានាទៅអនាគត។

សកម្មភាពនានាដែលស្នើឡើងនៅក្នុងផែនការ CCAP បច្ចុប្បន្ននេះ នឹងត្រូវអនុវត្ត តាមរយៈកិច្ចប្រឹងប្រែងរួមមួយរបស់នាយកដ្ឋានបច្ចេកទេសនានារបស់ក្រសួងបរិស្ថាន ដែលរួមគ្នាជាមួយ NCSD និងមន្ទីរបរិស្ថានរាជធានី និងខេត្ត ក្រោមកិច្ចសហការជាមួយក្រសួងនិង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងអ្នកពាក់ព័ន្ធនានា ដែលនឹងអាចឱ្យកម្ពុជា ពង្រីកវិធានការបន្សាំនឹងអាកាសធាតុ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន និងឈានទៅរកសង្គមមួយដែលកាន់តែមានភាពធន់នឹងអាកាសធាតុ និងបញ្ចេញកាបូនតិច។

ការធានាឱ្យមានការផ្តល់លទ្ធផលប្រកបដោយនិរន្តរភាពពីការអនុវត្តផែនការសកម្មភាពនេះ នឹងទាមទារឱ្យមានភាពម្ចាស់ការពីគ្រប់ភាគីទាំងអស់ដែលអនុវត្តផែនការនេះ ក៏ដូចជា ការផ្តល់មូលនិធិ និងធនធានដទៃទៀតឱ្យទាន់ពេលវេលាផងដែរ។ ដូច្នេះ ប្រការសំខាន់គឺក្រសួងបរិស្ថាន ត្រូវធ្វើការរួមបញ្ចូលជាលក្ខណៈប្រព័ន្ធនូវអន្តរាគមន៍នានាដែលគ្រោងនៅក្រោម CCAP ទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ និងផែនការវិនិយោគសាធារណៈរបស់ខ្លួន និងបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីកៀរគរធនធានបន្ថែម។

ក្រសួងបរិស្ថាននឹងធានាថា លទ្ធផលនានាពីការវិភាគប្រចាំឆ្នាំលើការអនុវត្តផែនការ CCAP ដោយក្រសួងបរិស្ថាន ក៏ដូចជា លទ្ធផលពីការរៀបចំផែនការ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ត្រូវបានផ្សព្វផ្សាយនៅក្នុងសន្និបាតប្រចាំឆ្នាំរបស់ក្រសួងបរិស្ថាននៅចុងឆ្នាំនីមួយៗ ដែលឆ្លុះបញ្ចាំងអំពីមេរៀនដែលទទួលបាន និងការកែសម្រួលទិសដៅតាមការចាំបាច់។

ផែនការសកម្មភាពបច្ចុប្បន្ននេះនឹងត្រូវដាក់សម្រាប់ការវាយតម្លៃនៅចុងវគ្គដំបូងនៃការអនុវត្តរបស់ខ្លួន ក្នុងឆ្នាំ 2018 ដើម្បីជូនជាព័ត៌មានសម្រាប់ការរៀបចំ CCAP ដែលនឹងចែងសម្រាប់ឆ្នាំ 2019-2023 ដើម្បីបន្សីជាមួយអាណត្តិរបស់រដ្ឋាភិបាល។ ក្រសួងបរិស្ថានជឿជាក់ថា ទិសដៅដែលបានចែងនៅក្នុងផែនការសកម្មភាពប្រែប្រួលអាកាសធាតុរបស់ខ្លួនសម្រាប់ឆ្នាំ 2016 ដល់ 2018 នឹងអាចឱ្យមានការឆ្លើយតបទាន់ពេលវេលា និងដោយប្រសិទ្ធភាពពីវិស័យបរិស្ថាន ដែលរួមចំណែកជាសំខាន់ដល់សមិទ្ធផលនៃគោលបំណងជាយុទ្ធសាស្ត្រដែលមានចែងនៅក្នុង CCCSP 2014-2023។ ផែនការ CCAP នឹងត្រូវចែករម្លែកទូលំទូលាយជាមួយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងបរិស្ថាន ដើម្បីធានាភាពម្ចាស់ការ និងការផ្សព្វផ្សាយទូលំទូលាយ ដើម្បីសម្រួលដល់ការកសាងភាពជាដៃគូ ដើម្បីពង្រឹងការអនុវត្តរបស់ខ្លួន និងដើម្បីជំរុញបន្ថែមទៀតនូវកិច្ចប្រឹងប្រែងដែលនឹងជួយកម្ពុជាឈានទៅរកការអភិវឌ្ឍដែលកាន់តែមានភាពធន់នឹងអាកាសធាតុ និងបញ្ចេញកាបូនតិច។

# ឧបសម្ព័ន្ធ 1: បញ្ជីសកម្មភាពទាក់ទងនឹងការប្រែប្រួលសកម្មភាព

| យុទ្ធសាស្ត្រអាទិភាព និងចង្កោមសកម្មភាព | | អង្គភាពប្រតិបត្តិ | អង្គភាពសហការអនុវត្តន៍ | តម្រូវការផែណទានសរុប (១.000ដុល្លារ) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
| | | | | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ |
| **យុទ្ធសាស្ត្រអាទិភាពទី១៖** កិច្ចគាំពារបរិស្ថាន | | | | | | | | | | | | | |
| ១.១ | ការគ្រប់គ្រងសំណល់រឹង-រាវ តាមរាជធានី ទីក្រុង និងទីប្រជុំជនតាមវិធានការចម្រុះ និងការគ្រប់គ្រងសំណល់សត្វ។ | ន/ដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន | | ១០ | | ១២៤០ | | ១៧៥ | | ១៦៥ | | ១១០ | |
| ១.១.១ | រៀបចំលិខិតបទដ្ឋានគតិយុត្តិ និងយុទ្ធសាស្ត្រថវិកាសម្រាប់ការគ្រប់គ្រងសំណល់ រឹង-រាវ តាមរាជធានីទីក្រុង និងទីប្រជុំជន។ | ន/ដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន | មន្ទីរបរិស្ថាន/អាជ្ញាធរដែនដី | ០ | | ១៣០ | | ៣០ | | ៣០ | | ៣០ | |
| ១.១.២ | រៀបចំ និងអនុវត្តផែនការសកម្មភាព៥ឆ្នាំ២០១៥-២០២០ សម្រាប់គម្រោងអាទិភាពស្តីពីការគ្រប់ គ្រងសំណល់ រឹង-រាវ តាមរាជធានី ទីក្រុង និងទីប្រជុំជនតាមវិធានការចម្រុះ និងការគ្រប់គ្រងសំណល់សត្វ។ | ន/ដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន | មន្ទីរបរិស្ថានខេត្ត | ០ | | ១០ | | ១០ | | | | | |
| ១.២ | បញ្ជូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ | ន/ដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | | ៥៤,៤ | | ៦៩,៦ | | ៧០,៦ | | ៩៩,៦ | | ៧១,៦ | |
| ១.២.១ | រៀបចំលិខិតបទដ្ឋានគតិយុត្តិស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ | ន/ដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | មន្ទីរបរិស្ថាន | ២០ | | ៣០ | | ២០ | | ២០ | | | |
| ១.២.២ | រៀបចំ និងអនុវត្តផែនការសកម្មភាព៥ឆ្នាំ២០១៥-២០២០ សម្រាប់គម្រោងអាទិភាពស្តីពី ការវាយ តម្លៃហេតុប៉ះពាល់បរិស្ថាន | ន/ដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | មន្ទីរបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ | ១៣ | | ១២ | | ១២ | | ១២ | | ១២ | |
| **យុទ្ធសាស្ត្រអាទិភាពទី២៖** ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍដោយចីរភាព | | | | | | | | | | | | | |
| ២.១ | បញ្ជូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការ គ្រប់គ្រងតំបន់ការពារធម្មជាតិ | អគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | | ១០ | | ២.៤៦៥ | | ២.៤៦៤ | | ២.៤៦៦ | | ២.៤៥៤ | |
| ២.១.១ | រៀបចំ និងអនុវត្តផែនការសកម្មភាព៥ឆ្នាំ២០១៥-២០២០ សម្រាប់គម្រោងអាទិភាពស្តីពីការគ្រប់គ្រងតំបន់ការពារធម្ម | ន/ដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ | នាយកដ្ឋានផែនការនិងកិច្ចការច្បាប់ | ០ | | ១៥ | | ១៥ | | ១៥ | | ១៥ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ជាតិ | | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| ២.១.៣ | កំណត់ទីតាំងដែលមានសក្តានុពល និងតម្រូវការសម្រាប់បង្កើតបន្ថែមនូវតំបន់ការពារធម្មជាតិមានរូបភាពជា តំបន់ដីសើម និងជីវៈចម្រុះ ទប់ទល់និងបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ | នាយកដ្ឋានតំបន់ដីសើម និងតំបន់ឆ្នេរ | ន/ដ្ឋានវាយតម្លៃធនធានធម្មជាតិ<br>ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ០ | | ២០ | | ២០ | | ២០ | | ២០ | |
| ២.១.៣ | កំណត់ទីតាំងដែលមានសក្តានុពល និងតម្រូវការសម្រាប់បង្កើតបន្ថែមនូវតំបន់ការពារធម្មជាតិមានរូបភាពជាឧទ្យានទប់ទល់និងបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានឧទ្យានជាតិ | ន/ដ្ឋានវាយតម្លៃធនធានធម្មជាតិ<br>ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ១០ | | ១១ | | ១០ | | ១២ | | ០ | |
| ២.១.៤ | រៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដោយបញ្ចូលសមត្ថភាពបន្សុំារបស់ប្រជាសហគមន៍ បណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានស្រាវជ្រាវ និងអភិសហគមន៍ តំបន់ការពារធម្មជាតិ | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ០ | | ២.៤១៩ | | ២.៤១៩ | | ២.៤១៩ | | ២.៤១៩ | |
| **២.២** | **អនុវត្តន៍វិធានការគ្រប់គ្រង និងការពារតំបន់ការពារធម្មជាតិបន្សុំាការប្រែប្រួលអាកាសធាតុ** | | | **០** | | **៦០** | | **៦០** | | **៦០** | | **៦០** | |
| ២.២.១ | កំណត់ប្រភេទជីវចម្រុះ ដែលងាយរងការប្រែប្រួល និងងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ និងជម្រើសជាអាទិភាពសម្រាប់ការគ្រប់គ្រងនាពេលអនាគត និងបន្ថែមក្នុងយុទ្ធសាស្ត្របន្សុំាដែលមានស្រាប់ | ន/ដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវចម្រុះ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ០ | | ១០ | | ១០ | | ១០ | | ១០ | |
| ២.២.២ | ធ្វើឱ្យប្រសើរឡើងនូវភាពបន្សុំារបស់សហគមន៍តំបន់ការពារធម្មជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ | នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍសហគមន៍ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ០ | | ៣៩,៥០ | | ៣៩,៥០ | | ៣៩,៥០ | | ៣៩,៥០ | |
| ២.២.៣ | ធ្វើឱ្យប្រសើរឡើងនូវកិច្ចការពារសង្គមសម្រាប់សហគមន៍តំបន់ការពារធម្មជាតិ។ | នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍសហគមន៍ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ០ | | ១០,៥០ | | ១០,៥០ | | ១០,៥០ | | ១០,៥០ | |
| **២.៣** | **អនុវត្តន៍វិធានការទប់ស្កាត់ និងស្តារឡើងវិញដើម្បីបង្កើនភាពបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ** | | | **០** | | **២៥** | | **២៥** | | **២៥** | | **២៥** | |
| ២.៣.១ | ជំរុញការស្តារឡើងវិញតាមបែបធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិធ្វើជាមធ្យោបាយក្នុងការបង្កើនភាពបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវចម្រុះ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ០ | | ១៥ | | ១៥ | | ១៥ | | ១៥ | |
| ២.៣.២ | កំណត់ប្រភេទពូជរាតត្បាតដែលមាននឹងការរីកត្អរបស់វានៅពេលដែលមានការប្រែប្រួលអាកាសធាតុ។ អភិវឌ្ឍន៍ | ន/ដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវចម្រុះ | លេខាធិការដ្ឋានជីវសុវត្ថិភាព | ០ | | ១០ | | ១០ | | ១០ | | ១០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បច្ចេកទេសឱ្យបានសមស្របសម្រាប់ការកំណត់អត្តសញ្ញាណ ការត្រួតពិនិត្យ និងការគ្រប់គ្រង។ | | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| **២.៤** | **ជំរុញ និងធ្វើឱ្យប្រសើរឡើងដល់សមត្ថភាពបន្សាំរបស់សហគមន៍ និងស្ថាប័នប្រព័ន្ធធម្មជាតិឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។** | | | **៥៦** | | **៥០** | | **៥០** | | **៦០** | | **០** | |
| ២.៤.១ | គ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ និងធ្វើឱ្យប្រសើរឡើងនូវតំបន់ការពារជីវចម្រុះនានា។ | ន/ដ្ឋានឧទ្យានជាតិ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ៥៦ | | ៥០ | | ៥០ | | ៦០ | | ០ | |
| **២.៥** | **ផ្តល់ចំណេះដឹងវិទ្យាសាស្ត្រអំពីការប្រែប្រួលអាកាសធាតុដល់ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍** | | | **៣០** | | **៣៤** | | **៣២** | | **៣២** | | **០** | |
| ២.៥.១ | សិក្សាស្រាវជ្រាវពីសារតាបរិស្ថាននៃឧទ្យានជាតិ ដែនជម្រកសត្វព្រៃតំបន់ដីសើម ទីជម្រាល តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់ឆ្នេរ និងតំបន់ការពារបេតិកភ័ណ្ឌ។ | ន/ដ្ឋានឧទ្យានជាតិ | ន/ដ្ឋានវាយតម្លៃធនធានធម្មជាតិ | ៣០ | | ៣៤ | | ៣២ | | ៣២ | | ០ | |
| **យុទ្ធសាស្ត្រអាទិភាពទី៣៖**<br>**ការអភិវឌ្ឍបៃតងជាតិ និងការប្រែប្រួលអាកាសធាតុ** | | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | | | | | | | | | | | |
| **៣.១** | **ការគាំពារកិច្ចការរដ្ឋបាលទូទៅ** | | | **០** | | **៤០២** | | **៤០២** | | **៤០២** | | **៤០២** | |
| ៣.១.១ | បន្ទុកបុគ្គលិក។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | | ០ | | ៣១៤ | | ៣១៤ | | ៣១៤ | | ៣១៤ | |
| ៣.១.២ | បន្ទុកក្រៅបុគ្គលិក។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | | ០ | | ៨៨ | | ៨៨ | | ៨៨ | | ៨៨ | |
| **៣.២** | **ការអភិវឌ្ឍបរិស្ថានបៃតង និងធនធានធម្មជាតិ** | | | **០** | | **១៩២** | | **១៩២** | | **១៩២** | | **១៩២** | |
| ៣.២.១ | កសាងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង។ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ និងន/ដ្ឋានផែនការនិងកិច្ចការច្បាប់ | ០ | | ១៥ | | ១៥ | | ១៥ | | ១៥ | |
| ៣.២.២ | ផ្សព្វផ្សាយគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងបរិស្ថានបៃតង និងធនធានធម្មជាតិ។ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១៨ | | ១៨ | | ១៨ | | ១៨ | |
| ៣.២.៣ | បណ្តុះបណ្តាលបច្ចេកទេសអភិវឌ្ឍបៃតង និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ២៨ | | ២៨ | | ២៨ | | ២៨ | |
| ៣.២.៤ | រៀបចំសន្និសីទ វេទិកា សិក្ខាសាលា និងកិច្ចប្រជុំនានាពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង។ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១០៣ | | ១០៣ | | ១០៣ | | ១០៣ | |
| ៣.២.៥ | សិក្សា និងស្រាវជ្រាវសក្តានុពល និងប្រសិទ្ធិភាពនៃការអនុ | អគ្គលេខាធិការដ្ឋានជាតិ | ន/ដ្ឋានប្រែប្រួល អាកាស | ០ | | ១៧ | | ១៧ | | ១៧ | | ១៧ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វត្តអភិវឌ្ឍន៍បៃតង។ | អភិវឌ្ឍន៍បៃតង | ជាតុ | | | | | | | | | | |
| ៣.២.៦ | តាមដាន និងវាយតម្លៃការអនុវត្តបច្ចេកទេសអភិវឌ្ឍបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១១ | | ១១ | | ១១ | | ១១ | |
| **៣.៣** | **ការអភិវឌ្ឍសេដ្ឋកិច្ច និងវិនិយោគបៃតង** | | | **០** | | **៨១** | | **៨១** | | **៨១** | | **៨១** | |
| ៣.៣.១ | រៀបចំគោលការណែនាំពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងវិនិយោគបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១៧ | | ១៧ | | ១៧ | | ១៧ | |
| ៣.៣.២ | ផ្សព្វផ្សាយគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១១ | | ១១ | | ១១ | | ១១ | |
| ៣.៣.៣ | បណ្តុះបណ្តាលបច្ចេកទេសអភិវឌ្ឍបៃតង និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ២៨ | | ២៨ | | ២៨ | | ២៨ | |
| ៣.៣.៤ | រៀបចំកិច្ចប្រជុំ និងវាទិកាពិគ្រោះយោបល់នានាពាក់ព័ន្ធ នឹងការអភិវឌ្ឍបៃតងជាមួយវិស័យឯកជន | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ៨ | | ៨ | | ៨ | | ៨ | |
| ៣.៣.៥ | សិក្សាវាយតម្លៃប្រសិទ្ធិភាពនៃការប្រតិបត្តិសេដ្ឋកិច្ច និងវិនិយោគបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ៦ | | ៦ | | ៦ | | ៦ | |
| ៣.៣.៦ | តាមដាន និងវាយតម្លៃការអភិវឌ្ឍសេដ្ឋកិច្ច និងវិនិយោគបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១១ | | ១១ | | ១១ | | ១១ | |
| **៣.៤** | **ការអភិវឌ្ឍបញ្ចេញកាបូនតិច** | | | **០** | **៤.៥០៦** | **៥២,៥** | **១២.០៦៤** | **៥២,៥** | **១២.០៥៤** | **៥២,៥** | **៧.៥៥៨** | **៥២,៥** | **៧.៥៥៨** |
| ៣.៤.១ | កែលម្អសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ។ (គម្រោង៖ រៀបចំប្រព័ន្ធសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិនៅកម្ពុជា) | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | ១០០ | ២ | ១០០ | ២ | ៩០ | ២ | | ២ | |
| ៣.៤.២ | សិក្សា និងវាយតម្លៃលើសក្តានុពលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | | ២ | | ២ | | ២ | | ២ | |
| ៣.៤.៣ | រៀបចំរបាយការណ៍ពីរឆ្នាំម្តង (Biennial Update Report)។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | ៤.៤០៦ | ១០ | ៤.៤០៦ | ១០ | ៤.៤០៦ | ១០ | | ១០ | |
| ៣.៤.៤ | រៀបចំ និងកែសម្រួលជាប្រចាំនូវ សកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់សមស្របថ្នាក់ជាតិ(NAMA)។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | | ២០ | | ២០ | | ២០ | | ២០ | |
| ៣.៤.៥ | បញ្ជ្រាបវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងផែនការថ្នាក់ជាតិ ក្រោមជាតិ និងតាមវិស័យ។ (គម្រោង៖ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមរយៈការជំរុញការប្រើប្រាស់ឡជីវម៉ាសពាណិជ្ជកម្ម) | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | | ១៥ | ២.៤៣៣ | ១៥ | ២.៤៣៣ | ១៥ | ២.៤៣៣ | ១៥ | ២.៤៣៣ |
| ៣.៤.៦ | បង្កើត និងដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីថ្នាក់ជាតិ និងយន្តការគ្រប់គ្រងឥណទានកាបូន សម្រាប់សកម្មភាពកាត់ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | | ១,៥០ | | ១,៥០ | | ១,៥០ | | ១,៥០ | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ | | | | | | | | | | |
| ៣.៤.៧ | សម្របសម្រួលការអនុវត្តវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យពាក់ព័ន្ធ។ (គម្រោង៖ កសាងប្រព័ន្ធបន្សាំនៅតំបន់ទីក្រុងតាមរយៈការបន្សាំស្ថានប្រព័ន្ធក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច) | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១ | ៥.១២៥ | ១ | ៥.១២៥ | ១ | ៥.១២៥ | ១ | ៥.១២៥ |
| ៣.៤.៨ | តាមដាន និងវាយតម្លៃការអនុវត្តវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១ | | ១ | | ១ | | ១ | |
| **៣.៥** | **បន្សាំនឹងការប្រែប្រួលអាកាសធាតុ** | | | **០** | **៣.៧៨៣** | **៤២** | **៤.៥៣៣** | **៤២** | **៤.៥៣៣** | **៤២** | **៤.៥៣៣** | **៤២** | **៤.៥៣៣** |
| ៣.៥.១ | សិក្សាវាយតម្លៃភាពងាយរងគ្រោះ និងជម្រើសបន្សាំ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ២ | | ២ | | ២ | | ២ | |
| ៣.៥.២ | សហការក្នុងការវាយតម្លៃលើការបាត់បង់ និងខូចខាតបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ (loss and damage)។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១ | | ១ | | ១ | | ១ | |
| ៣.៥.៣ | រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងម៉ូដែលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ២ | | ២ | | ២ | | ២ | |
| ៣.៥.៤ | សម្របសម្រួលការរៀបចំ និងអនុវត្តផែនការបន្សាំជាតិ (NAP)។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ២០ | | ២០ | | ២០ | | ២០ | |
| ៣.៥.៥ | បញ្ជ្រាបវិធានការបន្សាំទៅក្នុងផែនការថ្នាក់ជាតិ ក្រោមជាតិ និងតាមវិស័យ (គម្រោង៖ ការពង្រឹងភាពបន្សាំរបស់ប្រជាជនទីជនបទ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិចំពោះហានិភ័យ និងការប្រែប្រួលអាកាសធាតុ) | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | ៣៧៨៣ | ១៥ | ៣៧៨៣ | ១៥ | ៣៧៨៣ | ១៥ | ៣៧៨៣ | ១៥ | ៣៧៨៣ |
| ៣.៥.៦ | សម្របសម្រួល និងចូលរួមអនុវត្តវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | ០ | ១ | ៧៥០ | ១ | ៧៥០ | ១ | ៧៥០ | ១ | ៧៥០ |
| ៣.៥.៧ | តាមដាន និងវាយតម្លៃការអនុវត្តវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១ | | ១ | | ១ | | ១ | |
| **៣.៦** | **ការសម្របសម្រួល និងអភិវឌ្ឍន៍សមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** | | | **១៦០** | **៧៤០** | **៣០៣** | **២.៤៩២** | **៣០៣** | **៣.៣៥០** | **៣០៣** | **៣.២០៣** | **៣០៣** | **២.៣០០** |
| ៣.៦.១ | សហការជាមួយស្ថាប័នអប់រំ ក្នុងការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សា។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ២០ | | ២០ | | ២០ | | ២០ | |
| ៣.៦.២ | ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធការងារប្រែប្រួលអាកាសធាតុ រួមទាំងការបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងចំណេះដឹង។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| ៣.៦.៣ | កសាងសមត្ថភាពមន្ត្រីអង្គភាពប្រែប្រួលអាកាស ធាតុ នៅ | ន/ដ្ឋានប្រែប្រួល អាកាស | អគ្គលេខាធិការដ្ឋានជាតិ | ០ | | ៣០ | | ៣០ | | ៣០ | | ៣០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | តាមក្រសួង/ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | ជាតុ | អភិវឌ្ឍន៍បៃតង | | | | | | | | | | |
| ៣.៦.៤ | សម្របសម្រួល និងចូលរួមរៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងផែនការពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១០ | | ១០ | | ១០ | | ១០ | |
| ៣.៦.៥ | ពង្រឹងក្របខ័ណ្ឌស្ថាប័នជាតិ និងការសម្របសម្រួលអន្តរស្ថាប័នទទួលបន្ទុកការងារប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១០ | | ១០ | | ១០ | | ១០ | |
| ៣.៦.៦ | វាយតម្លៃនិងជំរុញការអនុវត្តបច្ចេកវិទ្យាសមស្រប។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ២០ | | ២០ | | ២០ | | ២០ | |
| ៣.៦.៧ | ដឹកនាំការអនុវត្តកាតព្វកិច្ចក្រោមអនុសញ្ញាប្រែប្រួលអាកាសធាតុ រួមទាំងការរៀបចំរបាយការណ៍ជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ៥ | | ៥ | | ៥ | | ៥ | |
| ៣.៦.៨ | កសាងសមត្ថភាព និងពង្រឹងប្រពន្ធ័គាំទ្រថ្នាក់ជាតិ ដល់ការអនុវត្ត និងការសម្របសម្រួលសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុរួមចំណែកដល់ការអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាពនិងពឹងផ្អែកលើចំណេះដឹងជាគោល។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ក្រសួងពាក់ពន្ធ អង្គការជាតិ អន្តរជាតិ និងសហគមន៍មូលដ្ឋាន | ១៦០ | ៧៤០ | ១៦០ | ២៩៩២ | ១៦០ | ៣៣៥០ | ១៦០ | ៣២០៣ | ១៦០ | ២៣០០ |
| ៣.៦.៩ | រៀបចំ និងដាក់ឱ្យដំណើរការនូវក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ៧ | | ៧ | | ៧ | | ៧ | |
| ៣.៦.១០ | បង្កើត និងដាក់ឱ្យដំណើរការនូវក្របខ័ណ្ឌជាតិសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១ | | ១ | | ១ | | ១ | |
| ៣.៦.១១ | ចូលរួមរៀបចំវេទិកាបរិស្ថានជាតិប្រចាំឆ្នាំ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១០០ | | ១០០ | | ១០០ | | ១០០ | |
| ៣.៦.១២ | ចូលរួមក្នុងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងថ្នាក់អន្តរជាតិលើការងារប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ៦០ | | ៦០ | | ៦០ | | ៦០ | |
| **យុទ្ធសាស្ត្រអាទិភាពទី៤៖** ការអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | | | | | | | | | | |
| ៤.១ | **ការអប់រំបរិស្ថានក្នុងប្រព័ន្ធ** | | | ១០០ | | ២០០ | | ២០០ | | ២០០ | | ២០០ | |
| ៤.១.១ | បញ្ជ្រាបការងារអប់រំនិងខ្លឹមសារ/បញ្ហាបរិស្ថាន (បញ្ញតិបរិស្ថានទូទៅ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ បញ្ហាបំពុល ...ល។) ទៅក្នុងកម្មវិធីសិក្សាគ្រប់ភូមិសិក្សា(ចាប់ពី | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ, ន/ដ្ឋានជីវៈចម្រុះ/នាយកដ្ឋាន C | ២០ | | ៥០ | | ៥០ | | ៥០ | | ៥០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថ្នាក់មត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សា)។ | | | | | | | | | | | | |
| ៤.១.២ | សម្របសម្រួលនិងចលនាអនុវត្តសាលាមេត្រីបរិស្ថានគ្រប់ភូមិសិក្សានៅតាមរាជធានី-ខេត្ត រួមបញ្ចូលទាំងការរៀបចំក្លឹបបរិស្ថាននតាមសាលារៀន។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | ២០ | | ៥០ | | ៥០ | | ៥០ | | ៥០ | |
| ៤.១.៣ | រៀបចំផលិត និងបោះពុម្ពផ្សាយឯកសារ-ឧបទេសអប់រំបរិស្ថាន (ឯកសារបោះពុម្ពផ្សាយ ឯកសារសោត-ទស្សន៍ និងសម្ភារៈឧបទេស) សម្រាប់គាំទ្រដល់ការងារអប់រំបរិស្ថានក្នុងប្រព័ន្ធ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | នាយកដ្ឋានពាក់ព័ន្ធនានា | ២០ | | ៣០ | | ៣០ | | ៣០ | | ៣០ | |
| ៤.១.៤ | រៀបចំវគ្គបណ្តុះបណ្តុះបរិស្ថាន (បញ្ញតិបរិស្ថានទូទៅ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ បញ្ហាបំពុល ...ល។) ដល់គ្រូឧទេសនៅសាលាគរុកោសល្យ និងវិក្រឹតិការ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ, ន/ដ្ឋានជីវៈចម្រុះ/នាយកដ្ឋាន C | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| ៤.១.៥ | រៀបចំវគ្គបណ្តុះបណ្តុះបរិស្ថាន (បញ្ញតិបរិស្ថានទូទៅ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ បញ្ហាបំពុល ...ល។) ដល់គ្រូឧទេស នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ, ន/ដ្ឋានជីវៈចម្រុះ/នាយកដ្ឋាន C | ២០ | | ៣០ | | ៣០ | | ៣០ | | ៣០ | |
| **៤.២** | **ការងារអប់រំបរិស្ថានក្រៅប្រព័ន្ធ** | | | **១២០** | | **១៤០** | | **១៤០** | | **១៤០** | | **១៦០** | |
| ៤.២.១ | រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងពីបញ្ហាការប្រែប្រួលអាកាសនិងវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមសហគមន៍ ឬសាលារៀន...ល។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ២០ | | ២០ | | ២០ | | ២០ | | ៣០ | |
| ៤.២.២ | ផលិតឯកសារ (ទស្សនាវដ្តីកូនសៀវភៅបរិស្ថាន ...ល។) សម្រាប់ចុះអប់រំនិងលើកកម្ពស់ការយល់ដឹងពីបរិស្ថានដល់សិស្ស-និស្សិតនិងសាធារណជន | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | ២០ | | ២០ | | ២០ | | ២០ | | ៣០ | |
| ៤.២.៣ | រៀបចំវេទិកាយុវជនប្រកួតពិភាក្សាបញ្ហាបរិស្ថានប្រចាំឆ្នាំ (រួមបញ្ចូលបញ្ញត្តិ និងដំណោះស្រាយលើបញ្ហាប្រែប្រួលអាកាសធាតុ)។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ៦០ | | ៦០ | | ៦០ | | ៦០ | | ៦០ | |
| ៤.២.៤ | លើកកម្ពស់ការយល់ដឹងរបស់មហាជនស្តីពីការប្រើប្រាស់និងផលិតកម្មប្រកបដោយចីរភាពដើម្បីគាំទ្រដល់ផលិតផលបៃតង។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| **៤.៣** | **ការបណ្តុះបណ្តាលនិងកសាងចំណេះដឹងបរិស្ថាន** | | | **៨០** | | **១៥០** | | **១៥០** | | **១៥០** | | **១៥០** | |
| ៤.៣.១ | កសាងនិងពង្រឹងសមត្ថភាពមន្ត្រីបរិស្ថានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីជំនាញគ្រប់គ្រងបរិស្ថាន រួមបញ្ចូលទាំងការបណ្តុះបណ្តាលពីរបៀបវាយតម្លៃហានិភ័យ ភាពងាយរង | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គ្រោះ និងភាពបន្សាំ និងធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ ។ | | | | | | | | | | | | |
| ៤.៣.២ | រៀបចំកម្មវិធីសិក្សា និងរបៀបវារៈសម្រាប់ការបណ្តុះបណ្តាលបរិស្ថានដោយរួមបញ្ចូលទាំងបញ្ញត្តិស្តីពីការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| ៤.៣.៣ | រៀបចំវេទិកាបណ្តុះបណ្តាល ឬការសិក្សាពីចម្ងាយ (distance learning) តាមរយៈអត្ថបទ មេរៀន ឬខ្សែវីដេអូ online ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | ២០ | | ៣០ | | ៣០ | | ៣០ | | ៣០ | |
| ៤.៣.៤ | បណ្តុះបណ្តាលពីរបៀបធ្វើលទ្ធកម្មបៃតងដល់មន្ត្រី រាជការជាពិសេសមន្ត្រីបរិស្ថាន (ឧទ្យានជាតិ ដែន ជម្រកសត្វព្រៃ តំបន់ដីសើម ទីជម្រាល តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង និងតំបន់ការពារបេតិកភណ្ឌ និងមន្ត្រីត្រួតពិនិត្យការបំពុលបរិស្ថាន)។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាននិងន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| **៤.៤** | **ការផ្សព្វផ្សាយនិងសហប្រតិបត្តិការ** | | | **២០** | | **១៣០** | | **១៣០** | | **១៧០** | | **១៩០** | |
| ៤.៤.១ | សហការជាមួយគ្រឹះស្ថានអប់រំនានាដើម្បីផ្តល់អាហារូបករណ៍ និងផ្តល់ឱកាស ដល់អ្នកស្ម័គ្រចិត្តដើម្បីសិក្សាស្រាវជ្រាវ និងបម្រើការងារផ្នែកប្រែប្រួលអាកាសធាតុដើម្បីគាំទ្រដល់សេចក្តីត្រូវការជាអាទិភាពខ្ពស់ របស់ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ដីសើម ទីជម្រាល តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់ការពារបេតិកភណ្ឌ និងផ្នែកត្រួតពិនិត្យការបំពុលបរិស្ថាន។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន និងន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ០ | | ៥០ | | ៥០ | | ៥០ | | ៥០ | |
| ៤.៤.២ | ពង្រឹងអានុភាពការងារការប្រែប្រួលអាកាសធាតុតាមរយៈយុវជនអាសាស្ម័គ្រ និងបណ្តាញយុវជនអសារស្ម័គ្រលើការងារបរិស្ថានរួមមានកិច្ចការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប រួមទាំងបញ្ហាឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ...ល។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ២០ | | ៤០ | | ៤០ | | ៦០ | | ៨០ | |
| ៤.៤.៣ | លើកទឹកចិត្ត និងផ្តល់ឱកាសដល់ក្រុមយុវជនដែលមានចំណាប់អារម្មណ៍ឱ្យចូលរួមក្នុងសកម្មភាពការងារប្រែប្រួលអាកាសធាតុនានា រួមទាំងវិធានការកាត់បន្ថយ វិធានការបន្សាំ និងវិធានការធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | ០ | | ៤០ | | ៤០ | | ៦០ | | ៦០ | |
| | **យុទ្ធសាស្ត្រអាទិភាពទី៥៖** | | | | | | | | | | | | |

| ទំនើបនីយកម្មស្ថាប័ន | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **៥.១** | **កំណត់ក្របខណ្ឌការងាររបស់លេខាធិការដ្ឋានគណៈកម្មការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុសម្រាប់សម្របសម្រួលការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ** | **លេខាធិការដ្ឋាន គ.ជ.គ.ប.អ.** | | **0** | | **១៣៥** | | **១២៣** | | **៨៨** | | **១០៨** | |
| ៥.១.១ | សម្របសម្រួលការរៀបចំការងារអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុប្រកបដោយ ប្រសិទ្ធិភាពខ្ពស់ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | 0 | | ១០ | | ១០ | | 0 | | 0 | |
| ៥.១.២ | ផ្តួចផ្តើម និងពង្រឹងការងារគ្រប់គ្រងផ្នែករដ្ឋបាលក្នុងដំណើរការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | 0 | | ១៥ | | ១៥ | | ១៥ | | ១៥ | |
| ៥.១.៣ | សម្របសម្រួល និងជួយដល់ភាគីអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ ក្នុងការលើកគម្រោងស្នើសុំថវិកា | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | 0 | | ២០ | | ២០ | | ១៥ | | ១៥ | |
| ៥.១.៤ | ទំនាក់ទំនងជាមួយអ្នកផ្តល់ជំនួយសម្រាប់ រកធនធានដើម្បីអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ភាគីទាំងអស់ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | 0 | | ៨ | | ៨ | | ៨ | | ៨ | |
| ៥.១.៥ | ទំនាក់ទំនង និងតាមដានការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ភាគីទាំងអស់ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | 0 | | ២០ | | ២០ | | ២០ | | ២០ | |
| ៥.១.៦ | រៀបចំលម្អិតយុទ្ធសាស្ត្រ និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុសម្រាប់ថ្នាក់ក្រោមជាតិដើម្បីងាយស្រួលក្នុងការអនុវត្ត។ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | 0 | | ៣០ | | ២០ | | 0 | | 0 | |
| ៥.១.៧ | ជំរុញ និងបញ្ចូលផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការបរិស្ថានជាតិ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានផែនការ និងកិច្ចការច្បាប់ | 0 | | ២០ | | 0 | | 0 | | 0 | |
| ៥.១.៨ | ធ្វើរបាយការណ៍ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានផែនការ និងកិច្ចការច្បាប់ | 0 | | ៣០ | | ៣០ | | ៣០ | | ៥០ | |
| **៥.២** | **គ្រប់គ្រងទិន្នន័យជាតិការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង** | | | **0** | | **៤៣០** | | **៣៨០** | | **១៥០** | | **១៥០** | |
| ៥.២.១ | កំណត់វិសាលភាព និងកសាងប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់គ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង | លេខាធិការដ្ឋាន គ.ជ.គ.ប.អ | ន/ដ្ឋានប្រែប្រួលអាកាសធាតុ អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ៣០០ | | ២៥០ | | ៥០ | | ៥០ | |
| ៥.២.២ | បញ្ចូលខ្លឹមសារការប្រែប្រួលអាកាសធាតុទៅក្នុងយុទ្ធសាស្ត្រការផ្សព្វផ្សាយតាមវិស័យរបស់ជាតិ។ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | 0 | | ១០ | | ១០ | | ១០ | | ១០ | |
| ៥.២.៣ | សមាហរណកម្មលទ្ធផលនៃការអនុវត្តផែនការសកម្មភាព | លេខាធិការដ្ឋាន | ន/ដ្ឋានប្រែប្រួល អាកាស | 0 | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រែប្រួលអាកាសធាតុទៅក្នុងប្រពន្ធ័ទិន្នន័យមូលដ្ឋានរបស់ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង | គ.ជ.គ.ប.អ | ជាតុ | | | | | | | | | | |
| ៥.២.៤ | ផ្សព្វផ្សាយលទ្ធផលក្នុងការអនុវត្តផែនការសកម្មភាពប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងប្រពន្ធ័ទិន្នន័យមូលដ្ឋានរបស់ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតងក្នុងក្របខ័ណ្ឌជាតិជូនដល់សាធារណជន | លេខាធិការដ្ឋាន គ.ជ.គ.ប.អ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាននិងនាយកដ្ឋានពាក់ព័ន្ធ | ០ | | ៣០ | | ៣០ | | ៣០ | | ៣០ | |
| ៥.២.៥ | ពង្រឹងសមត្ថភាពមន្ត្រីនៃលេខាធិការដ្ឋានគណៈកម្មការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុក្នុងការអភិវឌ្ឍព័ត៌មានវិទ្យាសាស្ត្រ ការគ្រប់គ្រង ប្រពន្ធ័ទិន្នន័យមូលដ្ឋាន ការបញ្ចេញនិងបំណាកស្រាយព័ត៌មានជូនសាធារណៈជន | លេខាធិការដ្ឋាន គ.ជ.គ.ប.អ | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | ០ | | ៩០ | | ៩០ | | ៦០ | | ៦០ | |

# ឧបសម្ព័ន្ធ 2: សន្លឹកព័ត៌មានអំពីសកម្មភាព

*សកម្មភាព 1: បង្កើតមណ្ឌលបច្ចេកវិទ្យាបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុដើម្បីសន្តិសុខស្បៀង ទឹក និងថាមពល*

| | |
|---|---|
| សកម្មភាព 1 | **បង្កើតមណ្ឌលបច្ចេកវិទ្យាបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុដើម្បីសន្តិសុខស្បៀង ទឹក និងថាមពល** |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 1: លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល (FWE)** |
| ហេតុផល | ការប្រែប្រួលជាសកលនៃរបបអាកាសធាតុ កំពុងបង្កផលប៉ះពាល់មកលើកម្ពុជាតាមរូបភាពជាច្រើន ដោយរបបធាតុអាកាសកាន់តែលែងអាចព្យាករណ៍បាន និងការព្យាករណ៍បង្ហាញពីកំណើនភាពញឹកញាប់ និងទំហំនៃព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត។ ការប្រែប្រួលទាំងនេះអាចបង្កផលប៉ះពាល់ជំធេងមកលើផលិតកម្មស្បៀង និងថាមពល ក៏ដូចជា វត្តមានទឹក ក្នុងនោះក្រុមអ្នកងាយរងគ្រោះ ទទួលការខូចខាតខ្លាំងជាងគេ។ ដោយមានប្រជាជនប្រមាណ 80% ពឹងផ្អែកលើកសិកម្មសម្រាប់ការចិញ្ចឹមក្រពះ វិស័យកសិកម្មនៅតែពឹងផ្អែកជាសំខាន់លើទឹកភ្លៀង ហើយវិស័យថាមពលវារីអគ្គិសនី តំណាងឱ្យភាគចំណែកយ៉ាងច្រើន នៃថាមពលដែលផលិតក្នុងស្រុក កិច្ចប្រឹងប្រែងរបស់កម្ពុជាដើម្បីបង្កើនសន្តិសុខស្បៀង ទឹកនិងថាមពល មានសារៈសំខាន់ជាខ្លាំងចំពោះសមត្ថភាពរបស់ខ្លួនក្នុងការទប់ទល់នឹងការប្រឈមនានាដែលបង្កដោយការប្រែប្រួលរបបនៃអាកាសធាតុ និងជលសាស្ត្រដែលត្រូវបានព្យាករណ៍ថានឹងកើតឡើង។<br><br>កិច្ចប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាសន្តិសុខស្បៀង ទឹកនិងថាមពល តាមរូបភាពជាច្រើន (ជាពិសេស ទាក់ទងនឹងវត្តមាន និងលទ្ធភាពទទួលបាន) តាមរយៈការវិនិយោគលើបច្ចេកវិទ្យាច្នៃប្រឌិតថ្មី និងវិធីសាស្ត្រនៃការគ្រប់គ្រង មានសារៈសំខាន់ជាខ្លាំងចំពោះការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រទេសកម្ពុជានៅចំពោះមុខការប្រែប្រួលអាកាសធាតុ និងអាចនាំឱ្យមានវិភាគទានជាវិជ្ជមានចំពោះសុខភាពមនុស្ស ការអប់រំ និងក្នុងការកសាងភាពធន់របស់សហគមន៍ចំពោះការប្រែប្រួលអាកាសធាតុ។<br><br>បន្ថែមលើការរួមចំណែកដោយផ្ទាល់ ចំពោះការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (NSFSN 2014-2018) និងគោលបំណងដទៃទៀតនៃគោលនយោបាយថាមពល និងទឹក សកម្មភាពនេះអាចដើរតួយ៉ាងសំខាន់នៅក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍កម្ពុជាដោយចីរភាព នៅក្នុងលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ សង្គម និងសេដ្ឋកិច្ច។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☐ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☑ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | មណ្ឌលបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិចដើម្បីសន្តិសុខស្បៀង ទឹក និងថាមពល (FEW) នឹងផ្តោតលើសកម្មភាពនានាដូចតទៅ៖<br>• កំណត់អត្តសញ្ញាណ/ផ្សព្វផ្សាយអំពីឱកាស និងឧបសគ្គសម្រាប់ការទទួលយកបច្ចេកវិទ្យាសមស្របដែលបញ្ចេញកាបូនតិចនិងធន់នឹងអាកាសធាតុ និងឱកាសខាងទីផ្សារសម្រាប់ពាណិជ្ជកម្មនិងការវិនិយោគបៃតង ដែលផ្តោតជាពិសេសលើការលើកកម្ពស់សន្តិសុខស្បៀង ទឹក និងថាមពល។<br>• ការបង្កើតជំនួយឥតសំណងសម្រាប់សាកល្បងដំណោះស្រាយ ដែលអាចពង្រីកបាននិង |

| | |
|---|---|
| | ចំណាយទាបដែលផ្តោតដោយផ្ទាល់លើការលើកកម្ពស់សន្តិសុខFWE របស់ក្រុមអ្នកងាយរងគ្រោះ<br>• វិភាគអំពីការប្រើប្រាស់( និងលទ្ធភាពក្នុងការប្រើប្រាស់ )បច្ចេកវិទ្យាដែលបញ្ចេញកាបូនតិចសម្រាប់សន្តិសុខ FEW នៅកម្ពុជា ដោយរាយការណ៍អំពីមេរៀនដែលទទួលបាន។<br>លទ្ធផល និងអត្ថប្រយោជន៍រំពឹងទុកៈ<br>• ចំណេះដឹងអំពីបច្ចេកវិទ្យាសមស្របដែលនាំឱ្យមានការទទួលយក និងការអនុវត្តកាន់តែច្រើនឡើង ជាមួយការលើកកម្ពស់សន្តិសុខ FWE<br>• ផលចំណេញដទៃទៀតដែលរំពឹងទុក ទាក់ទងនឹងការកាត់បន្ថយការបញ្ចេញ កែលម្អគុណភាពទឹក សុខភាព និងអត្ថប្រយោជន៍សង្គម បរិស្ថាន និងសេដ្ឋកិច្ច<br>• ការងារដែលអនុវត្តមានសក្តានុពលក្នុងការផ្តល់ព័ត៌មាន សម្រាប់ការរៀបចំគោលនយោបាយ ដែលរួមទាំងអំពីទឹក ថាមពល ការប្រើប្រាស់ដី និងគោលនយោបាយកសិកម្ម ដែលនឹងរួមចំណែកជាបន្ថែមទៅក្នុងការបង្កើនផលចំណេញខាងការអភិវឌ្ឍ |
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | ប្រសិទ្ធភាពនៃការចំណាយនៃសកម្មភាពនេះអាចខុសគ្នា អាស្រ័យលើបច្ចេកវិទ្យាដែលបានកំណត់យក និងសាកល្បង ដោយត្រូវមានការវាយតម្លៃជាផ្នែកមួយនៃការសិក្សាលទ្ធភាពបច្ចេកទេស សេដ្ឋកិច្ច និងបរិស្ថាន ដែលជាលក្ខខណ្ឌរបស់មណ្ឌលនេះ។ លក្ខខណ្ឌដទៃទៀតគឺត្រូវមានការជ្រើសយកនិងសាកល្បងតែដំណោះស្រាយខាងបច្ចេកវិទ្យាណាដែលចំណាយទាបនិងអាចផ្សព្វផ្សាយបាន ដោយផ្តោតលើការកែលម្អ FEW ដោយបានបង្ហាញច្បាស់ពីប្រសិទ្ធភាពនៃការចំណាយតែប៉ុណ្ណោះ។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | មណ្ឌលចំណេះដឹងត្រូវតែមានធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស និងជំនាញគ្រប់គ្រាន់ដើម្បីជានាសម្រេចឱ្យបានគោលបំណងនានានៃកម្មវិធីនេះ។<br>ប្រការសំខាន់ផងដែរគឺថា ទន្ទឹមនឹងស្វែងយល់ពីជម្រើសបច្ចេកវិទ្យានានាសម្រាប់សន្តិសុខ FEW ដើម្បី កម្ពុជា ក៏ត្រូវតែមានការវិភាគ និងការសិក្សាលទ្ធភាពបឋមនូវបទពិសោធន៍ដែលពាក់ព័ន្ធពីប្រទេសដទៃដែលមានលក្ខខណ្ឌប្រហែលគ្នាផងដែរ។ |
| **សូចនាករជោគជ័យ** | • ចំនួនបច្ចេកវិទ្យាដែលអាចប្រើប្រាស់បាន ( ដំណោះស្រាយដែលបញ្ចេញកាបូនតិចចំណាយទាប ដែលផ្តោតលើការលើកកម្ពស់សន្តិសុខ FEW) ត្រូវបានកំណត់អត្តសញ្ញាណ និងបានសាកល្បង<br>• ការវិភាគបច្ចេកវិទ្យានានាសម្រាប់សន្តិសុខ FEW ត្រូវបានរៀបចំឡើង និងចែករំលែក |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋានទទួលខុសត្រូវៈ នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នៃក្រសួងបរិស្ថាន ក្រសួងពាក់ព័ន្ធ គ្រឹះស្ថានស្រាវជ្រាវ និងអ្នកពាក់ព័ន្ធនានាពីមជ្ឈដ្ឋានខាងក្រៅដែលពាក់ព័ន្ធក្នុងការអនុវត្ត (ដូចជា MME, MIH, MPTC, MAFF) |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 635.000 ដុល្លាអាមេរិក |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | FAO, IFAD, GEF, ថវិការដ្ឋ, វិទ្យាស្ថានគ្រប់គ្រងទឹកអន្តរជាតិ (IWMI) |
| **កាលបរិច្ឆេទ** | 2016 – 2018 |

*សកម្មភាព 2: ធ្វើការវាយតម្លៃភាពងាយរងគ្រោះនៅថ្នាក់ជាតិ និងតាមវិស័យ*

| | |
|---|---|
| សកម្មភាព 2 | **ធ្វើការវាយតម្លៃភាពងាយរងគ្រោះនៅថ្នាក់ជាតិ និងតាមវិស័យ** |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 2: កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ** |
| ហេតុផល | ការវាយតម្លៃដំបូងនៅថ្នាក់ជាតិអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះត្រូវបានធ្វើឡើងនៅឆ្នាំ 2001 ដែលទាមទារឱ្យមានការធ្វើបច្ចុប្បន្នភាពជាបន្ទាន់ ដើម្បីផ្តល់នូវការវាយតម្លៃពេញលេញជាងមុនមួយសម្រាប់អ្នកកសាងគោលនយោបាយ និងតម្រង់ទិសអន្តរាគមន៍ខាងផ្នែកអាកាសធាតុ។ នាយកដ្ឋាន DCC ដែលជាលេខាធិការដ្ឋាន NCSD ដែលទទួលខុសត្រូវលើបញ្ហាប្រែប្រួលអាកាសធាតុ មានអាណត្តិផ្តល់ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ការវាយតម្លៃភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ ដល់ស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងក្រុមដទៃទៀត ដើម្បីណែនាំអំពីកិច្ចប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យនៃការប្រែប្រួលអាកាសធាតុនៅទូទាំងប្រទេស។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☑ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☑បន្សាំ ☐កាត់បន្ថយ និងបន្សាំ |
| **សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក** | សកម្មភាពនេះដែលពាក់ព័ន្ធនានាដូចតទៅ៖<br>• វាយតម្លៃទិន្នន័យ/ព័ត៌មានអាកាសធាតុ និងការវាយតម្លៃភាពងាយរងគ្រោះដែលមានស្រាប់នៅថ្នាក់ជាតិ (រួមទាំង ការវាយតម្លៃភាពងាយរងគ្រោះតាមវិស័យ ឬ ការវាយតម្លៃនានាដែលបានធ្វើឡើងសម្រាប់តំបន់ភូមិសាស្ត្រណាមួយ) ដើម្បីប៉ាន់ប្រមាណពីភាពខ្វះចន្លោះដែលត្រូវលើកឡើងនៅក្នុងការវាយតម្លៃភាពងាយរងគ្រោះទៅអនាគត<br>• ធ្វើការវាយតម្លៃភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ (រួមទាំងការបង្រួមមាត្រដ្ឋាន ការធ្វើម៉ូដែល និងការបង្កើតលទ្ធផលនានាជាមួយដំណោះស្រាយសមស្របសម្រាប់ការរៀបចំផែនការនៅមូលដ្ឋាន) និងកំណត់អត្តសញ្ញាណចំណុចក្តៅនៃភាពងាយរងគ្រោះផងដែរ<br>• គាំទ្រដល់វិស័យនានានៅក្នុងការវាយតម្លៃភាពងាយរងគ្រោះជាក់លាក់ និងការកំណត់អត្តសញ្ញាណជម្រើសបន្សាំ (ដែលរួមទាំង ការវិភាគ និងឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេចសម្រាប់ការរៀបចំផែនការបន្សាំនៃគម្រោងវិនិយោគនានា[1])<br>• គាំទ្រវិស័យនានា ក្រោមកិច្ចសហការជាមួយក្រសួងកិច្ចការនារី ក្នុងការធានាថា បញ្ហាយេនឌ័រត្រូវបានរួមបញ្ចូលនៅក្នុងការវាយតម្លៃភាពងាយរងគ្រោះដែលបានអនុវត្ត និង<br>• វិភាគ និងផ្តល់ព័ត៌មាន និងទិន្នន័យគោលអំពីការវាយតម្លៃភាពងាយរងគ្រោះដែលបានធ្វើឡើង (នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ឬ តាមវិស័យ) និងអនុសាសន៍សម្រាប់ការរៀបចំផែនការបន្សាំ។<br>សកម្មភាពនេះនឹងតម្រង់ទិសវិធានការឆ្លើយតបជាក់លាក់ និងការបង្កើតវិធានការបន្សាំ ដោយរំពឹងថានឹងទទួលបានអត្ថប្រយោជន៍ជាច្រើន ខាងកំណើនប្រសិទ្ធភាពនៃការឆ្លើយតបនឹងការ |

[1] SPCR មានគម្រោងវិនិយោគចំនួន 7 ដែលគ្របដណ្តប់វិស័យចំនួនបី ពោលគឺធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងហិរញ្ញប្បទានឥតសំណងចំនួនមួយ។

| | |
|---|---|
| | ប្រែប្រួលអាកាសធាតុ។ |
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | របាយការណ៍វាយតម្លៃភាពងាយរងគ្រោះ នឹងជួយមួយផ្នែកដល់អ្នករៀបចំគោលនយោបាយ និងអ្នករៀបចំផែនការនៅក្នុងការចាត់អាទិភាព និងកំណត់អត្តសញ្ញាណអន្តរាគមន៍ឆ្លើយតបនឹងប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយ និង/ឬទប់ទល់នឹងហានិភ័យខាងអាកាសធាតុនៅតាមទីតាំងជាក់លាក់។ ដូច្នេះ វត្តមានព័ត៌មានពីការវាយតម្លៃភាពងាយរងគ្រោះអាចនាំទៅរកការបញ្ចៀសការបាត់បង់ និងបង្កើនផលិតភាព និងជួយបង្កើតគម្រោងដើម្បីបង្កើនប្រសិទ្ធភាពចំណាយលើអន្តរាគមន៍ឆ្លើយតបនឹងបញ្ហាអាកាសធាតុ។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | ការពិនិត្យ និងប្រមូលផ្តុំទិន្នន័យអាកាសធាតុដែលមាន និងការវាយតម្លៃភាពងាយរងគ្រោះដែលបានធ្វើឡើងដោយក្រសួងពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍន៍ នឹងជួយបង្ហាញឱ្យឃើញពីភាពខ្វះចន្លោះ និងជានាគុណភាពនៃការវាយតម្លៃភាពងាយរងគ្រោះដែលបានធ្វើឡើងនៅថ្នាក់ជាតិ និងតាមវិស័យផងដែរ។<br>ការសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពជាមួយក្រសួងនានា គឺជាលក្ខខណ្ឌសម្រាប់ការវាយតម្លៃភាពងាយរងគ្រោះតាមវិស័យ។<br>សមត្ថភាពបច្ចេកទេសរបស់បុគ្គលិកដើម្បីស្វែងយល់ និងគ្រប់គ្រងទិន្នន័យអាកាសធាតុ (ដែលរួមទាំង លទ្ធផលពីការធ្វើម៉ូដែលអាកាសធាតុ) ការផ្សព្វផ្សាយលទ្ធផលពីការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើឱ្យមានទិន្នន័យសម្រាប់អ្នកប្រើប្រាស់ខុសៗគ្នា។ |
| **សូចនាករជោគជ័យ** | • ទិន្នន័យអាកាសធាតុត្រូវបានធ្វើសុខដុមនីយកម្ម លទ្ធផលពីម៉ូដែលបង្រួមមាត្រដ្ឋាននឹងមាន(នៅក្នុង NCSD និងតាមវេបគតថល) សម្រាប់សាធារណជនប្រើប្រាស់<br>• មានរបាយការណ៍វាយតម្លៃភាពងាយរងគ្រោះនៅថ្នាក់ជាតិជាមួយជម្រើសបន្សាំ និងរបាយការណ៍វាយតម្លៃភាពងាយរងគ្រោះសម្រាប់វិស័យមួយចំនួន<br>• ការវិភាគ និងឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេចត្រូវបានរៀបចំឡើងសម្រាប់ការរៀបចំផែនការបន្សាំ (ផ្តោតយ៉ាងហោចណាស់លើគម្រោងវិនិយោគទាំង7 នៅក្រោម SPCR)<br>• កម្រិតនៃការពាក់ព័ន្ធរបស់ក្រុមអ្នកងាយរងគ្រោះ (ពោលគឺ ស្ត្រី ក្រុមជនភាគជាតិតិច កុមារ) នៅក្នុងការវាយតម្លៃនេះ។ |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រោមកិច្ចសហការជាមួយនាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលជាផ្នែកមួយនៃលេខាធិការដ្ឋាន NCSD នឹងសម្របសម្រួល និងដើរតួនាំមុខ ក្នុងការអនុវត្តសកម្មភាពនេះ ដោយសហការជិតស្និទ្ធជាមួយ MOWRAM។<br><br>MOWRAM គឺជាស្ថាប័នតែមួយនៃរដ្ឋាភិបាល ដែលប្រមូល និងចងក្រងទិន្នន័យឧតុនិយមនៅកម្ពុជា និងមានភារៈទទួលខុសត្រូវក្នុងការផ្តល់ទិន្នន័យអាកាសធាតុជាផ្លូវការសម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃនេះ បន្ថែមលើទិន្នន័យដែលបានពីកម្រិតពិភពលោក។ |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | *ថ្លៃចំណាយ និងមូលនិធិដែលបានកៀគររួចមកហើយដែលត្រូវផ្តល់ដោយ SPCR |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) និងសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA), ADB, CSIRO, UNEP |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 3: ធ្វើការវាយតម្លៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើជីវៈចម្រុះ និងសាកល្បងជម្រើសនានានៃការគ្រប់គ្រងដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ*

| | |
|---|---|
| សកម្មភាព 3 | **ធ្វើការវាយតម្លៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើជីវៈចម្រុះ និងសាកល្បងជម្រើសនានានៃការគ្រប់គ្រងដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 3: លើកកម្ពស់ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌** |
| ហេតុផល | ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារធម្មជាតិ និងតំបន់ប្រើប្រាស់ច្រើនយ៉ាង សរុប 3,2 លានហិកតា ត្រូវបានបង្កើត ដើម្បីអភិរក្សជីវៈចម្រុះរបស់ប្រទេសនេះ ដែលរួមទាំង យ៉ាងហោចណាស់ថនិកសត្វចំនួន 212ប្រភេទ សត្វស្លាប720ប្រភេទ និងរុក្ខជាតិ 2.308ប្រភេទ។ តំបន់ការពារធម្មជាតិ និងសត្វកំពុងរងគ្រោះរបស់កម្ពុជា ដែលបានស្ថិតក្រោមសម្ពាធនៃការបាត់បង់ទីជម្រក ពាណិជ្ជកម្មសត្វព្រៃ និងអាជីវកម្មរ៉ែ ក៏កំពុងស្ថិតក្រោមការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់ទាំងនេះមកលើជីវៈចម្រុះ និងមកលើសមត្ថភាពរបស់ប្រព័ន្ធតំបន់ការពារធម្មជាតិរបស់កម្ពុជា ក្នុងការសម្រេចបានគោលដៅនៃការអភិរក្សរបស់ខ្លួន ក៏នៅត្រូវការឱ្យមានការសិក្សាឡើងវិញផងដែរ។<br><br>សកម្មភាពនេះ នឹងផ្តល់ភស្តុតាងវិទ្យាសាស្ត្រថ្មីៗ ដើម្បីគាំទ្រដល់ការពិចារណាអំពីបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនិងកម្មភាពជីវៈចម្រុះជាតិ (NBSAP) ដែលរួមទាំង ផលប៉ះពាល់ដែលរំពឹងថានឹងកើតមានបណ្តាលពីកំណើននីវ៉ូទឹកសមុទ្រ កំណើនសីតុណ្ហភាព និងការប្រែប្រួលរបបទឹកភ្លៀង មកលើជីវៈចម្រុះ (សមាសភាពនៃប្រភេទ របាយអត្រារស់។ល។) និងផលប៉ះពាល់ នៃវិធានការបន្សាំ និងកាត់បន្ថយ ដែលអាចមានមកលើជីវៈចម្រុះ។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☐ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☑ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☑បន្សាំ ☐កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | • វាយតម្លៃភាពងាយរងគ្រោះនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលផ្សំដោយតំបន់ការពារធម្មជាតិចំនួន 23 នៅក្រោមសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន នៅចំពោះមុខការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុ (ដែលរួមទាំង កំណើនសីតុណ្ហភាព ភ្លើងព្រៃ គ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ) ដោយប្រើប្រាស់សេណារីយ៉ូប្រែប្រួលអាកាសធាតុបង្រួមមាត្រដ្ឋានសម្រាប់តំបន់ការពារធម្មជាតិមួយចំនួន (ផ្សារភ្ជាប់នឹងសន្លឹកព័ត៌មាន 2) និងការសង្កេតនៅតាមមូលដ្ឋាន។<br>• ចាត់ជាអាទិភាពនូវការវិភាគលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើប្រភេទរងគ្រោះថ្នាក់ តាមរយៈដំណើរការពិគ្រោះយោបល់ ជាមួយស្ថាប័នអភិរក្សនានា (ដូចជា, IUCN នៅកម្ពុជា, FFI, WWF, WCS, CI និងអង្គការជីវិតសត្វស្លាបអន្តរជាតិ) ដើម្បីកំណត់អត្តសញ្ញាណប្រភេទទាំងឡាយដែលងាយរងគ្រោះបំផុតនៅចំពោះមុខការប្រែប្រួលអាកាសធាតុ និងប្រភេទសំខាន់ៗសម្រាប់ការអភិរក្ស |

| | |
|---|---|
| | • ធ្វើការអង្កេតជីវៈចម្រុះ និងការពិគ្រោះយោបល់ជាមួយសហគមន៍នានាដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ អំពីប្រភេទនានាដែលចាត់ជាអាទិភាពនៅក្នុងការសិក្សានេះ ដើម្បីស្វែងយល់ពីស្ថានភាពនៃប្រភេទទាំងនោះ និងតម្រូវការអភិរក្ស។<br>• រៀបចំ/កែសម្រួលផែនការគ្រប់គ្រងតំបប់ការពារធម្មជាតិ (ដែលរួមទាំង វាយតម្លៃពីភាពចាំបាច់ឱ្យមានការពង្រីក) ដោយផ្អែកលើការវាយតម្លៃភាពងាយរងគ្រោះនៃតំបន់ការពារធម្មជាតិ និងការសិក្សានានាដែលបានធ្វើឡើងអំពីប្រភេទរងគ្រោះថ្នាក់(មួយចំនួន) ការកំណត់អត្តសញ្ញាណជម្រើសគ្រប់គ្រងជាក់លាក់សម្រាប់ការបន្សុំ។<br>• ធ្វើតេស្តជម្រើសគ្រប់គ្រងដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។<br>• អនុវត្តសកម្មភាពដែលរំពឹងថានឹងកាត់បន្ថយអត្រាបាត់បង់ជីវៈចម្រុះ នៅក្នុងរយៈពេលមធ្យមនិង រយៈពេលវែង តាមរយៈការគ្រប់គ្រងតំបន់ការពារធម្មជាតិទាំង23 កន្លែងឱ្យបានប្រសើរជាងមុន ដែលបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ។ |
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | ថ្លៃចំណាយសម្រាប់ការវាយតម្លៃភាពងាយរងគ្រោះ នៃតំបន់ការពារធម្មជាតិនៅចំពោះមុខការប្រែប្រួលអាកាសធាតុ មួយផ្នែកស្ថិតនៅក្រោមសកម្មភាព 2, ការវាយតម្លៃភាពងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ ដែលបង្កើតសេណារីយ៉ូអាកាសធាតុ និងម៉ូដែលបង្រួមមាត្រដ្ឋាន (ការកែសម្រួលខ្លះៗលើការបង្រួមមាត្រដ្ឋាន អាចជាការចាំបាច់ដើម្បីឱ្យស្របតាមលក្ខខណ្ឌជាក់លាក់នៃតំបន់ការពារធម្មជាតិ)។<br><br>ការគណនាគុណតម្លៃនៃជីវៈចម្រុះ ប្រភេទរងគ្រោះថ្នាក់ នៃប្រព័ន្ធតំបន់ការពារធម្មជាតិរបស់កម្ពុជា នៅពុំទាន់ធ្វើបានពេញលេញនៅឡើយទេ ប៉ុន្តែមានការប៉ុនប៉ងនៅក្នុងប្រទេសខ្លះដើម្បីគណនាជាទឹកប្រាក់នូវសេវាដែលផ្តល់ដោយតំបន់ការពារធម្មជាតិក៏ដោយ។ ប៉ុន្តែ បើទោះជាពាក់ព័ន្ធនឹងបញ្ហាប្រសិទ្ធភាពនៃការចំណាយ ឬ តម្លៃជាក់លាក់ជាសាច់ប្រាក់នៃជីវៈចម្រុះដែលត្រូវប៉ាន់ប្រមាណក៏ដោយ រដ្ឋាភិបាល កម្ពុជាមានការប្តេជ្ញាក្នុងការកំណត់អត្តសញ្ញាណ និងអនុម័តវិធានការចាំបាច់នានាដើម្បីបញ្ឈប់ការបាត់បង់ជីវៈចម្រុះ ដែលរួមទាំង វិធានការបន្សុំដែលត្រូវប្រកាន់យកផងដែរ។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | សេណារីយ៉ូប្រែប្រួលអាកាសធាតុបង្រួមមាត្រដ្ឋាន ដែលបានបង្កើតនៅក្នុងសកម្មភាព 2 នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការវិភាគ និងការកំណត់អត្តសញ្ញាណជម្រើសគ្រប់គ្រងបែបបន្សុំ ដែលត្រូវដាក់បញ្ចូលនៅក្នុងផែនការសម្រាប់តំបន់ការពារធម្មជាតិ។ |
| **សូចនាករជោគជ័យ** | • ចំនួនផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិជាមួយវិធានការបន្សុំ<br>• ចំនួនវិធានការ/សកម្មភាពបន្សុំ ដែលបានអនុវត្តនៅក្នុងតំបន់ការពារធម្មជាតិ ឬ វិធានការដទៃទៀត ដែលមានគោលដៅកាត់បន្ថយការគំរាមកំហែងចំពោះប្រភេទរងគ្រោះថ្នាក់។ |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋានទាំងបី ពោលគឺ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដែនដីគោក អភិរក្សតំបន់ដីសើមនិងទឹកសាប អភិរក្សសមុទ្រនិងតំបន់ឆ្នេរ នៅក្រោមអគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ (GDNCPA) ដែលធ្វើការលើការងារអភិរក្ស ក្រោមកិច្ចសហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាន NCSD (BD និង DCC) លើការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងជាមួយ MAFF និងIUCN លើការសិក្សាអំពីប្រភេទរងគ្រោះថ្នាក់មួយចំនួន។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងដីធ្លីនៅក្នុងតំបន់ការពារធម្មជាតិ។ |

| | |
|---|---|
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 2,3 លានដុល្លាអាមេរិក<br>គួរកត់សំគាល់ថា ថ្លៃចំណាយសម្រាប់ធ្វើការវាយតម្លៃភាពងាយរងគ្រោះនៃតំបន់ការពារធម្មជាតិចំពោះមុខការប្រែប្រួលអាកាសធាតុ មួយផ្នែកស្ថិតក្រោមសកម្មភាព 2 (លទ្ធផលនៃម៉ូដែលបង្រួមមាត្រដ្ឋានដែលគ្របដណ្តប់តំបន់ការពារធម្មជាតិ) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | NGOs ដែលធ្វើការលើការងារអភិរក្ស ដូចជា WWF, WCS, CI, FFI, Wild Aid, BirdLife, IUCN.<br>ADB, UNEP, USAID |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 4: រៀបចំការសិក្សាបឋមដើម្បីបង្កើតគណនេយ្យមូលធនធម្មជាតិ*

| សកម្មភាព 4 | **រៀបចំការសិក្សាបឋមដើម្បីបង្កើតគណនេយ្យមូលធនធម្មជាតិ** |
|---|---|
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 3: លើកកម្ពស់ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌** |
| ហេតុផល | ការឈានទៅសេដ្ឋកិច្ចបៃតង និងការកំណត់ថ្លៃចំណាយកាន់តែសុក្រឹតអំពីជម្រើសវិនិយោគ ទាមទារឱ្យមានប្រព័ន្ធគណនេយ្យកាន់តែទូលំទូលាយជាងមុន ដែលអាចវាស់សេវាកម្មនានាដែលបច្ចុប្បបនេះនៅលំបាកក្នុងការគណនានៅឡើយ(ដែលរួមទាំងសេវាប្រព័ន្ធអេកូឡូស៊ី)។ បច្ចុប្បន្ននេះ ប្រព័ន្ធគណនេយ្យមូលធនធម្មជាតិ (NCA) កំពុងស្ថិតក្រោមការរៀបចំ ដើម្បីឱ្យឆ្លើយតបនឹងតម្រូវការនេះ ដែលអាចជួយនៅក្នុងការធ្វើសេចក្តីសម្រេចឱ្យកាន់តែមានប្រសិទ្ធភាព (ដោយពិចារណាផងដែរនូវការប្រែប្រួលអាកាសធាតុ និងបញ្ហាដទៃទៀត)។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☐ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☑ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | ធ្វើការសិក្សាដើម្បីកំណត់ និងចាត់ជាជំពូកនូវ NCA ដែលមានសក្តានុពល ដែលអាចសមស្របសម្រាប់បរិបទកម្ពុជា ដោយផ្តោតលើមូលធនធម្មជាតិដែលមានជីវិត (ពោលគឺ ជីវៈចម្រុះ និងសេវាប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ) និងផលប៉ះពាល់បរិស្ថានបណ្តាលពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និង NOx។<br><br>ការសិក្សានេះនឹងរួមបញ្ចូលអនុសាសន៍សម្រាប់ប្រព័ន្ធ NCA ទៅអនាគត ដោយរួមបញ្ចូលការប្រែប្រួលអាកាសធាតុ ការបង្កើតឧបករណ៍ដើម្បីជួយធុរកិច្ចនៅក្នុងការគិតបញ្ចូលមូលធនធម្មជាតិ នៅក្នុងការសម្រេចរបស់ពួកគេ (ដូចជាតាមរយៈការប្រើប្រាស់សូចនាករ ឬ គណនីផលចំណេញ និងការបង់ខាតខាងបរិស្ថាន ឬ EP&L) និងការកំណត់ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្ត។ |
| ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ | សកម្មភាពនេះនឹងជួយកំណត់ឡើងវិញនូវវិធានការដែលមានប្រសិទ្ធភាពខាងការចំណាយទៅអនាគត។ |
| លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ | កិច្ចសហការនៃវិស័យនានា និងអ្នកពាក់ព័ន្ធជាច្រើន ជាពិសេស វិស័យឯកជន និងគ្រឹះស្ថានសិក្សាស្រាវជ្រាវ។ |
| សូចនាករជោគជ័យ | • អនុសាសន៍ពីការសិក្សា NCA ត្រូវបានផ្សព្វផ្សាយ ដើម្បីជួយដល់វិស័យឯកជន នៅក្នុងការវាយតម្លៃសេចក្តីសម្រេចលើការវិនិយោគ ឬ ដើម្បីដាក់បញ្ចូលការកែប្រែនានានៅក្នុងគំរូនានានៃធុរកិច្ច<br>• បានពិភាក្សាអំពីផែនទីបង្ហាញផ្លូវ |
| ការចាត់ចែងអនុវត្ត | នាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃ MOE ដែលជាផ្នែកមួយនៃលេខាធិការដ្ឋាន NCSD នឹងដឹកនាំការសិក្សា NCA នេះ ដោយសហការផ្ទាល់ជាមួយ MEF និងការផ្តល់ធាតុចូលពីអ្នកពាក់ព័ន្ធនានា។ |

| | |
|---|---|
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 120.000 ដុល្លាអាមេរិក<br>(សកម្មភាពនេះអាចនឹងពង្រីក ដោយផ្អែកលើវត្តមានមូលនិធិ ដើម្បីរួមបញ្ចូលការបង្កើតកម្មវិធីជាក់លាក់ និងការធ្វើតេស្ត) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | UNEP, UNDP, EU, WB/ADB, WWF |
| **កាលបរិច្ឆេទ** | 2017-2018 |

*សកម្មភាព 5: បង្កើតប្រព័ន្ធសារពើភណ្ឌ ឧស្ម័នផ្ទះកញ្ចក់ ជាតិ និងរៀបចំធាតុចូលសម្រាប់ BURs*

| | |
|---|---|
| សកម្មភាព 5 | បង្កើតប្រព័ន្ធសារពើភណ្ឌ ឧស្ម័នផ្ទះកញ្ចក់ ជាតិ និងរៀបចំធាតុចូលសម្រាប់ BURs |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 4: លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនទាប ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព** |
| ហេតុផល | ការបង្កើតសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ គឺជាជំហានដំបូងសំខាន់មួយឆ្ពោះទៅគ្រប់គ្រងការបញ្ចេញឧស្ម័ននេះ។ ក្នុងឋានៈជាប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសមិនស្ថិតក្នុងឧបសម្ព័ន្ធ I នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ, (UNFCCC) កម្ពុជាពុំជាប់កាតព្វកិច្ចដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នឡើយ។ ទោះជាយ៉ាងណាក៏ដោយ សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ពេញលេញនិងប្រកបដោយតម្លាភាពនៅថ្នាក់ជាតិ គឺជាឧបករណ៍ដ៏សំខាន់ជាសារវន្តមួយសម្រាប់ការស្វែងយល់ពីការបញ្ចេញ និងនិន្នាការ ការធ្វើនិទស្សន៍អំពីការបញ្ចេញទៅអនាគត និងការកំណត់អត្តសញ្ញាណវិស័យនានាសម្រាប់ឱកាសកាត់បន្ថយការបញ្ចេញឧស្ម័នដែលមានប្រសិទ្ធភាពខ្ពស់ខាងការចំណាយ។ សារពើភណ្ឌនៅថ្នាក់ជាតិ ក៏ជាធាតុផ្សំគន្លឹះនៃរបាយការណ៍ជាតិដែលចាំបាច់ត្រូវដាក់ជូនទៅអនុសញ្ញា UNFCCC ផងដែរ ដែលកម្ពុជាគឺជាប្រទេសហត្ថលេខីមួយផងដែរនោះ។ ទោះបីកម្ពុជាបានរៀបចំសារពើភណ្ឌ ឧស្ម័នផ្ទះកញ្ចក់នៅថ្នាក់ជាតិចំនួនពីរលើក ជាទម្រង់បណ្តោះអាសន្នក៏ដោយ កម្ពុជានៅត្រូវបង្កើត អនុម័ត និងដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌស្ថាប័ននូវប្រព័ន្ធសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់មួយនៅថ្នាក់ជាតិ ស្របជាមួយការងារបន្ថែមខាងវិធីសាស្ត្រ (ជាពិសេសដែលទាក់ទងនឹងមេគុណបញ្ចេញឧស្ម័ន) ដើម្បីកម្ពុជាអាចតាមដានវឌ្ឍនភាពរបស់ខ្លួនក្នុងការឈានទៅការអភិវឌ្ឍដែលបញ្ចេញកាបូនតិច។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☑កាត់បន្ថយ ☐បន្សាំ ☐កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | • ការបណ្តុះបណ្តាលដំបូងអំពីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់, MRV, NAMA, BUR<br>• រៀបចំសំណើសម្រាប់ប្រព័ន្ធសារពើភ័ណ្ឌថ្នាក់ជាតិ ជាមួយក្របខ័ណ្ឌបទបញ្ញត្ត នីតិវិធី និងរចនាសម្ព័ន្ធស្ថាប័ន ជាមួយកម្មវិធីការងារដែលត្រូវដឹកនាំដោយ MOE/DCC និង ការកំណត់អត្តសញ្ញាណតម្រូវការសមត្ថភាព។ (ប្រការនេះរាប់បញ្ចូល ការពិនិត្យឡើងវិញនូវកិច្ចប្រឹងប្រែងធ្វើសារពើភណ្ឌកន្លងមក និងរចនាសម្ព័ន្ធដែលបានប្រើប្រាស់ ការវិភាគសំណើដែលមានស្រាប់នៃរចនាសម្ព័ន្ធស្ថាប័នសម្រាប់ MRV, ការវាយតម្លៃអំពីតម្រូវការ MRV, និងការរៀបចំសំណើ)<br>• បង្កើតក្រុមបច្ចេកទេសការងារ(TWG)អចិន្ត្រៃយ៍សម្រាប់វិស័យចំនួន 5 (ថាមពល ឧស្សាហកម្ម កសិកម្ម LULUCF និងសំណល់) ជាមួយការទទួលខុសត្រូវការងារជាក់លាក់ និងការចាត់ចែងឱ្យមានអនុស្សារណៈនៃការយោគយល់ចាំបាច់ជាមួយស្ថាប័នពាក់ព័ន្ធអំពីកិច្ចសហប្រតិបត្តិការ និងការចែករម្លែកទិន្នន័យ<br>• ចាត់តាំងក្រុមបុគ្គលិកពីនាយកដ្ឋាន DCC (ដែលរួមទាំង បុគ្គលិកទទួលខុសត្រូវលើការគ្រប់គ្រងកម្រងទិន្នន័យអាកាសធាតុ) ដើម្បីសម្របសម្រួលធាតុចូលពី TWGs និងជួយនៅក្នុងការរៀបចំសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់<br>• ផ្តល់ការកសាងសមត្ថភាពបច្ចេកទេសរបស់ TWGs និងក្រុមសម្របសម្រួលសារពើភណ្ឌនៃនាយកដ្ឋាន DCC |

| | |
|---|---|
| | • បង្កើតឯកសារណែនាំសម្រាប់សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់នីតិវិធីសម្រាប់វិស័យនីមួយៗ ដោយផ្អែកលើគោលការណ៍ណែនាំរបស់ IPCC ការធានាឱ្យមានកម្មវិធីកុំព្យូទ័រចាំបាច់ផងដែរ<br>• បង្កើតសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់នៅថ្នាក់ជាតិ ការអនុវត្ត QC&QAS និងការធានាថារាល់ទិន្នន័យត្រូវបានចងក្រងសម្រាប់ការរក្សាទុកបានត្រឹមត្រូវ និងចាត់ចែងឱ្យមានការផ្សព្វផ្សាយលទ្ធផលតាមរយៈភគថលចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ |
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | វាជាកាតព្វកិច្ចសម្រាប់កម្ពុជាដែលជាភាគីមួយនៅក្នុងអនុសញ្ញា UNFCCC។<br>លើសពីនេះ សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់នឹងជួយកម្ពុជាក្នុងការគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយប្រសិទ្ធភាព ការផ្តល់ព័ត៌មានដែលមានប្រយោជន៍ដល់អ្នកកសាងគោលនយោបាយអំពីវិស័យដែលមានសក្តានុពលសម្រាប់ការរៀបចំផែនការអភិវឌ្ឍដែលបញ្ចេញកាបូនតិចនៅកម្ពុជា។ វាក៏នឹងជួយកម្ពុជាផងដែរក្នុងការទាក់ទាញមូលនិធិអាកាសធាតុ ដែលត្រូវបានបម្រុងទុកសម្រាប់គម្រោងកាត់បន្ថយនានា ក៏ដូចជា ដើម្បីកៀរគរការគាំទ្រពីប្រទេសជឿនលឿន នូវជំនួយបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យាផងដែរ។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | • ផ្តល់ថវិកាបានទាន់ពេលវេលា<br>• មន្ត្រីដែលមានបទពិសោធន៍ខាងប្រព័ន្ធសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់<br>• កិច្ចសហប្រតិបត្តិការល្អពីស្ថាប័ននានា និងអង្គការដែលពាក់ព័ន្ធ |
| **សូចនាករជោគជ័យ** | • សំណើមួយសម្រាប់ប្រព័ន្ធសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់នៅថ្នាក់ជាតិរៀបចំរួចរាល់នៅឆ្នាំ 2016<br>• វង្វាស់នានាដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានកំណត់អត្តសញ្ញាណ<br>• កម្រិតនៃការចូលរួមរបស់ TWGs នៅក្នុងសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋាន DCC រួមជាមួយក្រសួងពាក់ព័ន្ធនានា និងអ្នកពាក់ព័ន្ធដទៃទៀត |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 450.000 ដុល្លាអាមេរិក<br>ចំណុចនេះរួមបញ្ចូល ការអភិវឌ្ឍសមត្ថភាព ប៉ុន្តែមិនរាប់បញ្ចូលថ្លៃចំណាយលើបុគ្គលិក ឬការសិក្សា/ស្រាវជ្រាវ ដើម្បីកំណត់មេគុណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឡើយ។<br>មូលនិធិដែលបានកៀរគរ៖ 1.825 ដុល្លាអាមេរិក ( ថវិការដ្ឋ ), មូលនិធិបន្ថែមនឹងត្រូវកៀរគរតាមរយៈ USAID (ចំនួនពិតប្រាកដកំពុងស្ថិតក្នុងការពិភាក្សា) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | ថវិការដ្ឋ<br>មូលនិធិពីប្រភពខាងក្រៅ៖ USAID និងម្ចាស់ជំនួយដទៃទៀត |
| **កាលបរិច្ឆេទ** | 2016 - 2017 |

*សកម្មភាព 6: សម្រួលដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមរយៈគម្រោង និងកម្មវិធីយន្តការផែណទានហិរញ្ញវត្ថុកាបូន*

| | |
|---|---|
| សកម្មភាព 6 | **សម្រួលដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមរយៈគម្រោង និងកម្មវិធីយន្តការផែណទានហិរញ្ញវត្ថុកាបូន** |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 4: លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនទាប ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព** |
| ហេតុផល | ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបនៅកម្ពុជាគឺ 221 ជីកាក្រាម នៅឆ្នាំ 2000 ដែលឈានពីកម្រិត អវិជ្ជមាន 5.143 ជីកាក្រាម នៅឆ្នាំ 1994 ដែលការបញ្ចេញភាគច្រើនមកពីវិស័យកសិកម្ម និងថាមពល។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាមានការប្តេជ្ញាក្នុងការអភិវឌ្ឍកំណើនសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច និងកំពុងប្រឹងប្រែងដើម្បីក្បាលនាំនៃការអភិវឌ្ឍដែលធន់នឹងអាកាសធាតុដោយបញ្ចេញកាបូនកម្រិតទាប ដែលជាការអភិវឌ្ឍដោយចីរភាព។<br><br>ដើម្បីលើកកម្ពស់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ កម្ពុជាចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើតលក្ខខណ្ឌអំណោយផល ដែលចាំបាច់សម្រាប់ដំណើរការនៃយន្តការផែណទានទូទាត់កាបូនមួយចំនួនដែលផ្អែកលើទីផ្សារ ដែលបានបង្កើតឡើងនៅក្រោម UNFCCC, ដែលរួមទាំង យន្តការអភិវឌ្ឍន៍ស្អាត (CDM) ដែលបានបង្កើតឡើងជាដំបូងក្រោមពិធីសារក្យូតូ។ យន្តការផែណទានហិរញ្ញវត្ថុកាបូននៅក្រោមគម្រោងនិងកម្មវិធីផ្សេងទៀត រួមមាន យន្តការផែណទានរួមគ្នា (JCM), ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរិលព្រៃឈើ (REDD+), និងសកម្មភាពកាត់បន្ថយសមស្របនៅថ្នាក់ជាតិ (NAMA)។<br><br>នៅកម្ពុជា ក្រសួងបរិស្ថានត្រូវបានតែងតាំងជាស្ថាប័នជាតិយន្តការអភិវឌ្ឍន៍ស្អាត(DNA) សម្រាប់ CDM នៅឆ្នាំ 2003 ហើយមកទល់ពេលនេះ គម្រោងចំនួន11 បានទទួលការអនុម័តពី DNA។ ក្របខ័ណ្ឌច្បាប់សម្រាប់យន្តការដទៃទៀត កំពុងស្ថិតក្នុងដំណាក់កាលខុសៗគ្នានៃការរៀបចំ NAMA, REDD+ ហើយយន្តការ JCM នៅតែជាកិច្ចការថ្មីសម្រាប់កម្ពុជា និងនៅមានកិច្ចការជាច្រើនទៀត ដែលត្រូវធ្វើបង្ហើយ ដើម្បីសម្រួលដល់អ្នកអភិវឌ្ឍន៍គម្រោងនៅក្នុងស្រុកក្នុងការប្រើប្រាស់យន្តការទាំងនេះ។<br><br>សកម្មភាពនេះមានទិសដៅ ជំរុញកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយសម្រួលដល់អ្នកអភិវឌ្ឍន៍គម្រោងនិងកម្មវិធី ក្នុងការប្រើប្រាស់យន្តការផែណទានទូទាត់ទាំងនេះដោយផ្តល់ក្របខ័ណ្ឌច្បាប់ នីតិវិធី និងការចាត់ចែងស្ថាប័ន ជាមួយច្រកចេញចូលតែមួយសម្រាប់យន្តការទាំងអស់នៅក្នុងក្រសួងបរិស្ថាន ដើម្បីជួយដល់វិស័យសាធារណៈ និងឯកជននៅក្នុងការអភិវឌ្ឍដែលបញ្ចេញកាបូនតិច។<br><br>សកម្មភាពនេះគូសបញ្ជាក់ពីការប្តេជ្ញារបស់កម្ពុជា នៅក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័ននៅថ្នាក់ជាតិនិងពិភពលោក នៅក្រោមក្របខ័ណ្ឌនៃអនុសញ្ញា UNFCCC និងរួមចំណែកក្នុងការសម្រេចបាននូវឆន្ទៈជាតិដើម្បីការរួមវិភាគទាន (ដែលត្រូវប្រកាសនៅក្នុងកិច្ចប្រជុំ COP 21 នៃ UNFCCC នៅក្រុងប៉ារីស) និងគោលនយោបាយជាតិអភិវឌ្ឍន៍បៃតង និង ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍបៃតង 2013-2030។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រឹកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☑កាត់បន្ថយ ☐បន្សាំ ☐កាត់បន្ថយ និងបន្សាំ |

| | |
|---|---|
| **សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក** | សកម្មភាពនេះនឹងផ្តោតលើការបង្កើតកន្លែងមួយ (fucility) នៅក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្នុងគោលបំណងនៃការធ្វើឱ្យវិស័យសាធារណៈចូលរួម (នៅថ្នាក់ជាតិ ឬ ថ្នាក់ក្រោមជាតិ) ក៏ដូចជា វិស័យឯកជន និងភ្នាក់ងារនៃNGO នៅក្នុងការប្រើប្រាស់យន្តការឥណទានទូទាត់កាបូន ដើម្បីផ្តល់ហិរញ្ញវត្ថុសម្រាប់គម្រោង និងកម្មវិធីបញ្ចេញឧស្ម័នកម្រិតទាប។<br>សកម្មភាពនេះនឹងរាប់បញ្ចូលៈ<br>• ការបង្កើតក្របខ័ណ្ឌស្ថាប័នសម្រាប់MRV និងការចុះបញ្ជីនូវការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងឥណទានទូទាត់កាបូន<br>• ការវាយតម្លៃពិស្តារអំពីតម្រូវការសមត្ថភាពសម្រាប់យន្តការថ្មីៗ<br>• ការបង្កើតសម្បទា (ជាមួយការចាត់តាំងបុគ្គលិក) នៅឆ្នាំ 2016<br>• ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកសម្បទានេះ និងអង្គភាពជាតិទទួលបន្ទុកកិច្ចការនេះ និងគណៈកម្មាធិការពិនិត្យកែសម្រួល ដែលបានបង្កើតឡើង (ឬត្រូវបង្កើតឡើង) នៅក្រោមយន្តការខុសៗគ្នា ដើម្បីអាចឱ្យ DCC អនុវត្តអាណត្តិរបស់ខ្លួនបានពេញលេញ ការចូលរួមនៅក្នុងការរៀនសូត្រជាប្រចាំ និងការកំណត់អត្តសញ្ញាណជម្រើស និងយន្តការថ្មីៗដើម្បី ជំរុញការកាត់បន្ថយការបញ្ចេញ(ជាពិសេសជម្រើស/យន្តការដែលរួមចំណែកក្នុងការកាត់បន្ថយភាពងាយរងគ្រោះផងដែរ)<br>• បង្កើនការយល់ដឹង និងការចូលរួមពីអ្នកពាក់ព័ន្ធនានាក្នុងការប្រើប្រាស់យន្តការទាំងនេះ<br>• ការបង្កើតការិយាល័យជំនួយ នៅក្នុងកន្លែងមួយ (faciulity) នេះ ដើម្បីផ្តល់ការណែនាំដល់ការរៀបចំ និងការអនុវត្តគម្រោងនិងកម្មវិធី (រំពឹងថានឹងប្រតិបត្តិការពេញលេញនៅឆ្នាំ2017), និង<br>• ការកៀរគរមូលនិធិពីប្រភពអន្តរជាតិ និងជាតិ ដើម្បីគាំទ្រដល់ការអនុវត្តអន្តរាគមន៍នានា ដែលផ្តោតលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ |
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | សកម្មភាពនេះគឺជាផ្នែកមួយនៃការប្តេជ្ញារបស់កម្ពុជានៅក្រោមអនុសញ្ញា UNFCCC ហើយមានការរំពឹងថា វានឹងរួមចំណែកក្នុងការទាក់ទាញមូលនិធិសម្រាប់ការអនុវត្តគម្រោង និងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (ទាំងពីប្រភពក្នុងប្រទេសនិងអន្តរជាតិ) ក៏ដូចជាការគាំទ្រពីប្រទេសជឿនលឿន ពាក់ព័ន្ធនឹងជំនួយបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យា។ ដូច្នេះមានការរំពឹងថា ផលប្រយោជន៍ពីការបង្កើតសម្បទាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នឹងមានទំហំធំជាងយ៉ាងច្រើនធៀបនឹងថ្លៃចំណាយលើការវិនិយោគ។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | ក្របខ័ណ្ឌច្បាប់សម្រាប់ហិរញ្ញវត្ថុកាបូន ដែលបានបង្កើតឡើងក្នុងសកម្មភាព 16។<br><br>ការដឹកនាំ និងការប្តេជ្ញារបស់ NCSD ដើម្បីលើកកម្ពស់ និងសម្រេចបានគោលដៅនៃការអភិវឌ្ឍដែលបញ្ចេញកាបូនតិច ការចាត់ទុកការអនុម័តក្របខ័ណ្ឌច្បាប់សម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបង្កើតប្រព័ន្ធ MRV និងការចុះបញ្ជីប្រកបដោយគុណភាពនៅក្នុងរបៀបវារៈជាអាទិភាពខ្ពស់។<br>លើសពីនេះ សកម្មភាពនេះគួរតែជាការបន្ថែមលើកិច្ចប្រឹងប្រែងកន្លងមកអំពីការបង្កើនការយល់ដឹង ការអភិវឌ្ឍសមត្ថភាព និងការបង្កើតភាពជាដៃគូនៅក្រោមយន្តការ CDM។ |

| | |
|---|---|
| **សូចនាករជោគជ័យ** | • ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ត្រូវបានបញ្ចៀស<br>• ចំនួនគម្រោង ឬ កម្មវិធីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ត្រូវបានរៀបចំឡើង ជាមួយការគាំទ្រពីសម្បទាននេះ និងនៅក្រោមការអនុវត្តរហូតដល់ឆ្នាំ 2018 (ដែលរួមទាំង យ៉ាងហោចណាស់គម្រោង NAMA ចំនួន 2) |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 385.000 ដុល្លាអាមេរិក |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | មូលនិធិ NAMA នៃចក្រភពអង់គ្លេស/អាល្លឺម៉ង់, មូលនិធិបរិស្ថានពិភពលោក, អាល្លឺម៉ង់ (IKI), ចក្រភពអង់គ្លេស (ICF), ដាណឺម៉ាក់ (ក្របខ័ណ្ឌពិភពលោក, GCPF), សហភាពអឺរ៉ុប និងគណៈកម្មការអឺរ៉ុប (GEEREF, LAIF, AIF), អូស្ត្រាលី, បារាំង (AFD, FFEM), NEFCO (NCF, NPI), ស្ថាប័នអភិវឌ្ឍន៍ពហុភាគី (ADB, IDB, ក្រុមWB), មូលនិធិអាកាសធាតុបៃតង, ជប៉ុន |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 7: បង្កើត និងសាកល្បងអភិក្រម និងជម្រើសបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុ សម្រាប់ទីប្រជុំជន*

| | |
|---|---|
| សកម្មភាព 7 | **បង្កើត និងសាកល្បងអភិក្រម និងជម្រើសបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុ សម្រាប់ទីប្រជុំជន** |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 4: លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព** |
| ហេតុផល | សកម្មភាពនេះរួមចំណែកក្នុងការសម្រេចគោលនយោបាយជាតិអភិវឌ្ឍន៍បៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង 2013-2030។<br><br>អត្រានគរូបនីយកម្មនៅកម្ពុជាកំពុងលូតលាស់ឆាប់រហ័សក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ជាពិសេស ក្នុងទីក្រុងធំៗ ដូចជា ភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ ដោយបច្ចុប្បន្ននេះមានប្រជាជន 21,5% រស់នៅតាមតំបន់ទីប្រជុំជននានា។ ជាលទ្ធផល ទីក្រុងនានាប្រឈមបញ្ហាបរិស្ថាន និងសង្គមជាច្រើន ដែលបញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរ ដោយសារផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។<br><br>សកម្មភាពនេះកែលម្អភាពធន់នៃទីក្រុងចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (ការដោះស្រាយបញ្ហានានា ដូចជា កំដៅទីក្រុង និងការបំពុលខ្យល់) ទន្ទឹមនឹងការរួមចំណែកទៅក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅតាមទីប្រជុំជន។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☐ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☑ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | សកម្មភាពនេះគ្របដណ្តប់ការអនុវត្តកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច និងធន់នឹងអាកាសធាតុ ដូចជា កម្មវិធីអភិវឌ្ឍទីក្រុងបៃតង (ជាមួយការគាំទ្រពី GGGI) និងការបង្កើតភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធទីក្រុង តាមរយៈការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី (ជាមួយការគាំទ្រពី UNEP/LCDF)។ សកម្មភាពនានានៅក្រោមកិច្ចផ្តួចផ្តើមទាំងនេះនីមួយៗ រួមមាន៖<br><br>• កម្មវិធីអភិវឌ្ឍន៍ទីក្រុងបៃតង (នៃ GGGI):<br>  - រៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងសម្រាប់ទីក្រុងភ្នំពេញ<br>  - គាំទ្រដល់ចំណាត់អាទិភាពនៃគម្រោងវិនិយោគទីក្រុងបៃតង ដែលរួមទាំង តាមរយៈការវិភាគសេដ្ឋកិច្ច និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដែលជាផ្នែកមួយនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង និង<br>  - រៀបចំផែនការសកម្មភាពវិនិយោគដើម្បីកៀរគរហិរញ្ញវត្ថុសម្រាប់គម្រោងវិនិយោគទីក្រុងបៃតងដែលអាចផ្តល់ផលចំណេញ តាមរយៈវិស័យសាធារណៈ និង/ឬ ឯកជន និងដែលមានសក្តានុពលក្នុងការរៀបចំសំណើគម្រោងជាក់លាក់សម្រាប់មូលនិធិ ពហុភាគី (ដូចជា មូលនិធិអាកាសធាតុបៃតង)<br>• កសាងភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធទីក្រុង តាមរយៈការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី (EbA):<br>  - កំណត់អត្តសញ្ញាណទីក្រុងដើម្បីសាកល្បងសំណើអន្តរាគមន៍EbA ដែលក្នុងនោះនឹងមានការផ្តល់វគ្គបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពស្ថាប័នដល់អាជ្ញាធរ |

| | |
|---|---|
| | គ្រប់គ្រងទីក្រុង ដើម្បីលើកផែនការ និងអនុវត្ត EbA សម្រាប់ទីក្រុង;<br>- ធ្វើការអនុវត្តបង្ហាញអំពីអន្តរាគមន៍ EbA នៅក្នុងទីក្រុងសាកល្បង និង<br>- ផ្សព្វផ្សាយចំណេះដឹង និងបង្កើនការយល់ដឹងជាសាធារណៈអំពី EbA នៅក្នុងទីក្រុងសាកល្បង។<br>• សាកល្បងការទទួលយកនៃដំណោះស្រាយចីរភាពបញ្ចេញកាបូនតិច<br>- ការណែនាំឱ្យប្រើប្រាស់ទោចក្រយានយន្តអេឡិចត្រូនិចនៅក្នុងទីក្រុងដែលជ្រើសរើសចំនួន២ ដើម្បីជំរុញឱ្យប្រើជម្រើសការដឹកជញ្ជូនដោយចីរភាព<br>- រៀបចំ និងសាកល្បងកម្មវិធីសម្រាប់ដាំដើមឈើលើទីសាធារណៈ ក្នុងគោលបំណងដើម្បីពង្រឹងមុខងារនៃហេដ្ឋារចនាសម្ព័ន្ធបៃតងទីក្រុងក្នុងន័យបង្កើនភាពធន់របស់ទីក្រុង (គោលដៅឱ្យមានការចូលរួមរបស់សាលារៀន សាលាក្រុង អ្នកដឹកនាំសាសនា និងវិស័យឯកជន) |
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | លក្ខខណ្ឌប្រសិទ្ធភាពថ្លៃចំណាយគឺជាផ្នែកមួយនៃកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍ទីក្រុងដែលបញ្ចេញកាបូនតិច និងធន់នឹងអាកាសធាតុ។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | ការដឹកនាំមោះមុត និងការចូលរួមនៃទីក្រុងនៅក្រោមគម្រោងសាកល្បង (ភ្នំពេញ និងទីក្រុងក្នុងតំបន់ឆ្នេរ) មានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តសកម្មភាពនេះឱ្យបានជោគជ័យ។ |
| **សូចនាករជោគជ័យ** | • ចំនួនវិធីសាស្រ្តនិងជម្រើសនានាដែលបញ្ចេញកាបូនតិចនិងធន់នឹងអាកាសធាតុ ត្រូវបានកំណត់ឃើញ/លើកស្នើនិងធ្វើតេស្តនៅតាមទីក្រុង(ភ្នំពេញនិងទិក្រុងក្នុងតំបន់ឆ្នេរ)<br>• ចំនួនទីក្រុងដែលមានផែនការអភិវឌ្ឍន៍ ដែលដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ (ដោយរួមបញ្ចូលទាំងវិធានការបន្សាំ និងកាត់បន្ថយ) |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃ NCSD<br>រាជធានីភ្នំពេញ<br>ទីក្រុងក្នុងតំបន់ឆ្នេរ (នឹងបញ្ជាក់តាមក្រោយ) |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 3,8 លានដុល្លាអាមេរិក<br>មូលនិធិដែលបានកៀរគរៈ 1,5 ដុល្លាអាមេរិក ពីកម្មវិធីអភិវឌ្ឍន៍ទីក្រុងបៃតង (GGGI) និង 2,1 លានដុល្លាអាមេរិក (ថវិកាដែលគ្រោងសម្រាប់កម្ពុជានៅក្រោមកម្មវិធីថ្នាក់តំបន់ដែលទទួលមូលនិធិពី LDCF សម្រាប់ ‘កសាងភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធទីក្រុង តាមរយៈការបន្សុាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី’)។ |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | GGGI; GEF/LDCF<br>មូលនិធិបន្ថែមពី GGGI សម្រាប់ការពង្រីកកម្មវិធីអភិវឌ្ឍន៍ទីក្រុងបៃតងនៅកម្ពុជា ក្រោយឆ្នាំ 2016 នៅពុំទាន់បានកំណត់នៅឡើយទេ។ |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 8: បង្កើតប្រព័ន្ធគ្រប់គ្រងចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍបៃតង*

| | |
|---|---|
| សកម្មភាព 8 | **បង្កើតប្រព័ន្ធគ្រប់គ្រងចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍបៃតង** |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 5: ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹង សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ** |
| ហេតុផល | យុទ្ធសាស្ត្រចតុកោណ ដំហានទី III កំណត់អត្តសញ្ញាណកំណែលម្អសមត្ថភាពមនុស្ស និងបច្ចេកវិទ្យា ជាបញ្ហាអភិវឌ្ឍន៍ចំបងមួយសម្រាប់កម្ពុជា ជាមួយតម្រូវការដើម្បីកែលម្អចំណេះដឹង ការអប់រំនិងការយល់ដឹង អំពីកិច្ចគាំពារបរិស្ថាន ការអភិរក្ស និងការប្រែប្រួលអាកាសធាតុ ក៏មានគូសបញ្ជាក់នៅក្នុង NSDPផងដែរ។ ការប្រែប្រួលអាកាសធាតុ ត្រូវបានកំណត់ផងដែរ ថាជាផ្នែកមួយដែលការអភិវឌ្ឍសមត្ថភាពបច្ចេកទេស និងចំណេះដឹង នៅត្រូវការឱ្យមានការវិនិយោគច្រើន ទើបអាចមានការឆ្លើយតបដោយប្រសិទ្ធភាព ជាមួយវត្តមានទិន្នន័យអាកាសធាតុ ឧបករណ៍ និងបច្ចេកវិទ្យាសម្រាប់ការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលនៅតែជាឧបសគ្គដ៏សំខាន់មួយចំពោះការកសាងគោលនយោបាយដែលផ្អែកលើភស្តុតាង។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍបៃតងនឹងត្រូវរាប់បញ្ចូលកិច្ចការនានាដូចតទៅ៖<br>• ការវាយតម្លៃតម្រូវការចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ និងការរៀបចំសំណើសម្រាប់ ប្រព័ន្ធគ្រប់គ្រងចំណេះដឹងដោយផ្អែកលើប្រព័ន្ធ និងធនធានដែលមានស្រាប់ និងការរៀនសូត្រពីការអនុវត្តជាអន្តរជាតិ ដោយផ្តោតលើសមាសភាគចំនួនបួន៖ (ក) ចំណេះដឹងបច្ចេកទេស និងការស្រាវជ្រាវអំពី ការប្រែប្រួលអាកាសធាតុ ដែលរួមទាំងទិន្នន័យអាកាសធាតុ និងកន្លែងតំកល់ទុកបច្ចេកវិទ្យាដែលបានសាកល្បង និងទម្លាប់ល្អ (ខ) ការផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទងចំណេះដឹងអំពី ការប្រែប្រួលអាកាសធាតុ និង GG (គ) ការបង្កើតមូលធនមនុស្ស ដែលរួមទាំង ការបណ្តុះបណ្តាលបច្ចេកទេស និងការអប់រំ (ឃ) ការគាំទ្រ/សេវាណែនាំបច្ចេកទេស<br>• ការពិគ្រោះយោបល់ និងការកែលម្អទម្រង់នៃ ប្រព័ន្ធគ្រប់គ្រងចំណេះដឹង និងយុទ្ធសាស្ត្រហិរញ្ញប្បទាន (ជាមួយកិច្ចព្រមព្រៀងអំពីរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងចំណេះដឹង , មុខងារ, ការចាត់ចែងស្ថាប័ន និងគំរូធុរកិច្ច)<br>• ការបង្កើតផ្នែក ប្រព័ន្ធគ្រប់គ្រងចំណេះដឹងសម្រាប់ ការប្រែប្រួលអាកាសធាតុនៅក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុ ដែលមានភារៈទទួលខុសត្រូវលើការថែទាំប្រព័ន្ធ ការធ្វើបច្ចុប្បន្នភាព និងការអភិវឌ្ឍ ដោយធានាថា មានការគោរពតាមពិធីសារចែករំលែកទិន្នន័យ និងយន្តការធានាគុណភាព<br>• ការរៀបចំពិធីសាររបស់ ប្រព័ន្ធគ្រប់គ្រងចំណេះដឹងសម្រាប់សមាសភាគ ខុសៗគ្នា (ដែលរួមទាំង ពិធីសារចែករំលែកទិន្នន័យ និងយន្តការធានាគុណភាព សម្រាប់ផលិតផលព័ត៌មានដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ) |

| | |
|---|---|
| | • បង្កើតហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងទិន្នន័យអាកាសធាតុ និងគេហទំព័ររបស់ ប្រព័ន្ធគ្រប់គ្រងចំណេះដឹង (ដោយសហការជាមួយ ICT/MPTC)<br>• អភិវឌ្ឍន៍សមត្ថភាពរបស់ផ្នែក KMIS នៅក្នុង DCC<br>• ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកMOEនិងស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលរួមចំណែកក្នុងការបង្កើតព័ត៌មាន/ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ<br>• បង្កើត និងផ្សព្វផ្សាយឧបករណ៍ ដើម្បីពង្រីកលទ្ធភាពរបស់អ្នកប្រើប្រាស់ខុសៗគ្នាក្នុងការទទួលបានធនធានចំណេះដឹងពី ប្រព័ន្ធគ្រប់គ្រងចំណេះដឹង<br>• ប្រកាសចាប់ផ្តើម ប្រព័ន្ធគ្រប់គ្រងចំណេះដឹងនិងបង្កើតភាពជាដៃគូសំខាន់ៗ (ជាមួយស្ថាប័នជាតិ និងអន្តរជាតិ)<br>• ការដាក់ឱ្យប្រតិបត្តិការសមាសភាគខុសៗគ្នានៃប្រព័ន្ធគ្រប់គ្រងចំណេះដឹង។<br><br>ការបង្កើតប្រព័ន្ធគ្រប់គ្រងចំណេះដឹង និងព័ត៌មានស្តីពី ការប្រែប្រួលអាកាសធាតុនិង ការអភិវឌ្ឍបៃតង នឹងជំរុញការបង្កើត និងប្រើប្រាស់ចំណេះដឹងនៅក្នុងផ្នែកទាំងនេះ ដែលអាចនាំឱ្យមានការឆ្លើយតបកាន់តែមានប្រសិទ្ធភាព និងកំណើនការយល់ដឹងក្នុងចំណោមក្រុមគោលដៅខុសៗគ្នា ដែលជាការរួមចំណែកក្នុងការអភិវឌ្ឍមូលធនមនុស្សនិងកំណើនភាពធន់នឹងអាកាសធាតុនៅទូទាំងប្រទេស |
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | ការវិនិយោគលើ ប្រព័ន្ធគ្រប់គ្រងចំណេះដឹងនឹងកាន់តែផ្តល់លទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចដែលផ្អែកលើភស្តុតាង និងការឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុកាន់តែមានប្រសិទ្ធភាពជាងមុន ជាមួយការរំពឹងទុកអំពីកំណើនយ៉ាងច្រើននៃការបាត់បង់ដែលអាចបញ្ចៀសបាន។ វត្តមានកាន់តែច្រើនឡើងនៃព័ត៌មានអាកាសធាតុប្រកបដោយគុណភាពខ្ពស់ និងដែលពាក់ព័ន្ធ ក៏ត្រូវបានរំពឹងថា អាចជួយសម្រួលដល់ការរៀបចំគម្រោងដែលផ្តល់ផលចំណេញ ដូច្នេះនឹងរួមចំណែកក្នុងការកៀរគរហិរញ្ញវត្ថុបន្ថែមផងដែរ។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | ការវាយតម្លៃតម្រូវការបានសមស្របតាំងពីដើមដំបូង និងការព្រមព្រៀង និងកិច្ចសហការពីអ្នកផលិតទិន្នន័យ មានសារៈសំខាន់ជាសារវន្ត ដើម្បីបង្កើនជាអតិបរមានូវសក្តានុពលរបស់ប្រព័ន្ធគ្រប់គ្រងចំណេះដឹង។<br><br>ការដឹកនាំនយោបាយ នឹងមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីធានាឱ្យមានការចូលរួមយ៉ាងសកម្មនៃវិស័យនានានៅក្នុងប្រព័ន្ធគ្រប់គ្រងចំណេះដឹងនិងដើម្បីធានាថា ក្របខ័ណ្ឌច្បាប់ដែលត្រូវការជាចាំបាច់ត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីឱ្យប្រព័ន្ធនេះមានដំណើរការពេញលេញ (ដែលរួមទាំង ពិធីសារចែករំលែកទិន្នន័យ និងយន្តការធានាគុណភាពផងដែរ)។<br><br>កិច្ចសហការរបស់ ICT/MPWT ក្នុងការបង្កើតហេដ្ឋារចនាសម្ព័ន្ធ ICT ដែលផ្តោតលើ CC ដែលរួមទាំង CC-cloud server, បរិក្ខារ ICT និង ICT platform (ដូចមានចែងក្នុង ICT CCAP) |
| **សូចនាករជោគជ័យ** | • ចំនួនដៃគូនៅក្នុងប្រព័ន្ធគ្រប់គ្រងចំណេះដឹង (ជាតិ និងអន្តរជាតិ) ដែលរួមចំណែកទៅក្នុងធនធាននៃ ប្រព័ន្ធគ្រប់គ្រងចំណេះដឹង<br>• ចំនួនទម្លាប់ល្អ ដែលបានបោះពុម្ពផ្សាយ និងចែកចាយតាមរយៈ ប្រព័ន្ធគ្រប់គ្រងចំណេះដឹងក្នុងមួយឆ្នាំៗ<br>• ចំនួនអ្នកប្រើប្រាស់គេហទំព័ររបស់ ប្រព័ន្ធគ្រប់គ្រងចំណេះដឹង<br>• ការដាក់ពិន្ទុដោយអ្នកប្រើប្រាស់អំពីផលប្រយោជន៍នៃប្រព័ន្ធគ្រប់គ្រងចំណេះដឹង(ទៅ |

| | |
|---|---|
| | តាមក្រុមខុសៗគ្នា ដែលរួមមាន អាជ្ញាធរមូលដ្ឋាន, NGOs, ក្រសួងពាក់ព័ន្ធ, វិស័យឯកជន, គ្រឹះស្ថានសិក្សាស្រាវជ្រាវ) |
| **ការចាត់ចែងអនុវត្ត** | *នាយកដ្ឋានទទួលខុសត្រូវ៖* DCC ក្នុងនាមជាលេខាធិការដ្ឋាន NCSD<br>*ស្ថាប័នផ្សេងទៀតនៃរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធពីខាងក្រៅ៖* ICT/MPTC; ឧតុនិយម/MOWRAM, NIS/MOP, និងក្រសួងពាក់ព័ន្ធសំខាន់ៗផ្សេងទៀត និងសកលវិទ្យាល័យ។ |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 615.000 ដុល្លាអាមេរិក<br>ថ្លៃចំណាយដែលបង្ហាញនៅទីនេះ គឺសម្រាប់ការបង្កើតប្រព័ន្ធគ្រប់គ្រងចំណេះដឹងនិងប្រព័ន្ធដែលចាំបាច់ និងបុគ្គលិកសម្រាប់ប្រតិបត្តិការប្រព័ន្ធនេះ (ដែលរួមទាំង ការចំណាយរួមគ្នាលើការតម្លើងហេដ្ឋារចនាសម្ព័ន្ធ ICT ដែលផ្តោតលើ CC ក្រោមកិច្ចសហការជាមួយ ICT CCAP)។ តួលេខនេះមិនគិតបញ្ចូល ការបង្កើតសមាសភាគខុសៗគ្នាពេញលេញនៃប្រព័ន្ធគ្រប់គ្រងចំណេះដឹងឡើយ (ដូចជា ការប្រមូលទិន្នន័យ/ម៉ូដែលអាកាសធាតុ ការបង្កើតទម្លាប់ល្អ ។ល។) ដែលនឹងធ្វើឡើងជាបណ្តើរៗជាមួយវិភាគទានពីដៃគូខុសៗគ្នាជាច្រើន។<br>មូលនិធិដែលបានកៀរគរ៖ 29.000 ដុល្លាអាមេរិក (CCCA); 2.060 ដុល្លាអាមេរិក (SPCR) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | CCCA; SPCR; GGGI<br>ICT/MPTC |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព ៩: ដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅគ្រប់លំដាប់ថ្នាក់*

| សកម្មភាព 9 | **ដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅគ្រប់លំដាប់ថ្នាក់** |
|---|---|
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 5: ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹង សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ** |
| ហេតុផល | ជាផ្នែកមួយនៃកិច្ចប្រឹងប្រែង ដើម្បីបង្កើនសមត្ថភាពប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ( ទិសដៅយុទ្ធសាស្ត្រមួយនៃផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា 2014-2023) នេះជាគន្លឹះសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅគ្រប់លំដាប់ថ្នាក់។ នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា(DCD) នៃក្រសួងអប់រំ យុវជន និងកីឡា មានភារៈទទួលខុសត្រូវលើការរៀបចំ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាជាទូទៅ(ដែលរួមទាំងកម្មវិធីសិក្សា សៀវភៅអំណាន និងសម្ភារៈសិក្សាដទៃទៀត) ត្រូវចូលរួមនៅក្នុងការធ្វើសមាហរណកម្មមុខវិជ្ជាប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សា ការបង្កើតសម្ភារៈសិក្សានិងបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុ និងការបង្កើតយន្តការនានាដើម្បីបង្កើនការយល់ដឹង និងដើម្បីអនុវត្តសកម្មភាពងាយៗនៅតាមសាលារៀនដើម្បីកាត់បន្ថយនិងបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើការគាំទ្រពីស្ថាប័នផ្តល់មូលនិធិនានា។<br>ចំណុចនេះក៏គាំទ្រដល់អាទិភាព និងសកម្មភាពនានា ដែលបានកំណត់នៅក្នុងផែនការសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA, 2006) ផងដែរ ដោយផ្តល់ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងស្ថាប័ន ដល់ DCD អំពីការរៀបចំគម្រោង ការគ្រប់គ្រង ការពិនិត្យតាមដាននិងវាយតម្លៃ និងការរៀបចំសម្ភារៈសិក្សា ដែលរួមទាំង អភិក្រមប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សាដែលកែសម្រួលថ្មី ដែលជាការរួមចំណែកទៅក្នុងការអភិវឌ្ឍស្ថាប័ននៃចេតនាសម្ព័ន្ធរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការរួមបញ្ចូលមុខវិជ្ជា CC ទៅក្នុងកម្មវិធីសិក្សានៅថ្នាក់ជាតិ គឺជាយុទ្ធសាស្ត្ររយៈពេលវែងមួយសម្រាប់បង្កើនការយល់ដឹងអំពី CC និងកសាងជាបណ្តើរៗនូវមូលធនមនុស្សដែលចាំបាច់ដើម្បីដោះស្រាយការប្រឈមនានារយៈពេលវែង ដែលបង្កដោយការប្រែប្រួលអាកាសធាតុ។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | • កិច្ចសហការជាមួយក្រសួងអប់រំយុវជន និងកីឡា ដើម្បីកំណត់ចំណុចចាប់ផ្តើមសម្រាប់ការរៀបចំកម្មវិធីសិក្សានៅគ្រប់លំដាប់ថ្នាក់<br>• បង្កើតសម្ភារៈសិក្សាអំពីការប្រែប្រួលអាកាសធាតុសម្រាប់ថ្នាក់បឋមសិក្សា, មធ្យមសិក្សា និងឧត្តមសិក្សា<br>• សាកល្បងកម្មវិធីសិក្សាដែលបានកែសម្រួលរួចនៅតាមសាលារៀន និងរៀបចំមាតិកាបន្ថែមទៀតនៃសម្ភារៈសិក្សាតាមការចាំបាច់<br>• រួមបញ្ចូលជាផ្លូវការនូវការកែប្រែដែលបានស្នើឡើង និងការកែសម្រួលនានាទៅក្នុងកម្មវិធីសិក្សាជាតិ។ |
| ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ | ចំណេះដឹងអំពីបញ្ហាប្រែប្រួលអាកាសធាតុ និងការឆ្លើយតបសមស្របដែលបានពង្រឹងក្នុងចំណោមយុវជនជំនាន់ថ្មី មានអំណាចក្នុងការបង្កើតការកែប្រែស៊ីជម្រៅ ដែលរួមចំណែកដល់ |

| | |
|---|---|
| | សមត្ថភាពទៅអនាគតរបស់ប្រទេស ដើម្បីទប់ទល់នឹងការប្រឈមនានាដែលបង្កដោយការប្រែប្រួលអាកាសធាតុ និងដើម្បីប្រើប្រាស់ឱកាសដែលកើតចេញពីការកែប្រែគំរូអភិវឌ្ឍ។ ទោះបីគ្មានព័ត៌មានអំពីប្រសិទ្ធភាពនៃថ្លៃចំណាយសម្រាប់សកម្មភាពនេះក៏ដោយ វានឹងមានប្រសិទ្ធភាពនៅក្នុងរយៈពេលវែង(ហួសអំឡុងពេលនៃការអនុវត្តផែនការសកម្មភាពនេះ) និងមានសារៈសំខាន់បំផុតសម្រាប់កិច្ចប្រឹងប្រែងរយៈពេលវែងនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រទេសនេះ។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | មានទិន្នន័យវិទ្យាសាស្ត្ររួចជាស្រេចមកហើយសម្រាប់ការរៀបចំសម្ភារៈសិក្សា ហើយការវាយតម្លៃតម្រូវការបណ្តុះបណ្តាលនិងសមត្ថភាពរបស់គ្រូ ក៏បានអនុវត្ត/ធ្វើបច្ចុប្បន្នភាពហើយដែរ។ |
| **សូចនាករជោគជ័យ** | • សម្ភារៈសិក្សាត្រូវបានរៀបចំ និងសាកល្បងនៅតាមសាលារៀន (យ៉ាងហោចណាស់មានសៀវភៅសម្រាប់អំណានមួយ អំពីរបៀបដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា សម្រាប់កម្រិតសិក្សាមួយ)<br>• ចំនួនគ្រូដែលបានទទួលការបណ្តុះបណ្តាល និងសំណើកម្មវិធីសិក្សា<br>• ការពិនិត្យកម្មវិធីសិក្សា មានការចូលរួមនៃអ្នកពាក់ព័ន្ធច្រើននៅក្នុងការងារនេះ ដោយមានសន្និសីទមួយដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា អំពីតួនាទីរបស់គ្រឹះស្ថានសិក្សា ស្ថាប័នអប់រំនៅគ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំមូលធនមនុស្សដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ |
| **ការចាត់ចែងអនុវត្ត** | DCC ក្រោមកិច្ចសហការជិតស្និទ្ធជាមួយ MoEYS និងសកលវិទ្យាល័យនានា |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 450.000 ដុល្លាអាមេរិក<br>មូលនិធិដែលបានកៀរគរ៖ 7.500 ដុល្លាអាមេរិក (ថវិការដ្ឋដែលបានប៉ាន់ស្មានសម្រាប់ឆ្នាំ 2016-2018, បញ្ជាក់ជាក្រោយ); 350.000 ដុល្លាអាមេរិក (CCCA); 70.000 (SPCR) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | ថវិការដ្ឋ<br>ប្រភពមូលនិធិពីក្រៅប្រទេស៖ CCCA II; SPCR |
| **កាលបរិច្ឆេទ** | 2015-2018 |

*សកម្មភាព 10: ការចូលរួម និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ និងអភិវឌ្ឍន៍បៃតងរួមទាំងការប្រើប្រាស់និងផលិតកម្មដោយចីរភាព ឱ្យដល់ក្រុមគោលដៅផ្សេងៗ*

| | |
|---|---|
| សកម្មភាព 10 | ការចូលរួម និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ និងអភិវឌ្ឍន៍បៃតងរួមទាំងការប្រើប្រាស់និងផលិតកម្មដោយចីរភាពឱ្យដល់ក្រុមគោលដៅផ្សេងៗ |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | ទិសដៅជាយុទ្ធសាស្ត្រ 5: ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹង សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ |
| ហេតុផល | សកម្មភាពនេះមានលក្ខណៈស្របគ្នាជាមួយការប្តេជ្ញា ដែលបានធ្វើឡើងនៅសន្និសីទក្រុងរីយ៉ូ +20 ស្តីពីការអភិវឌ្ឍដោយចីរភាព ដែលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDG) ជាពិសេស SDG 12 ‘ធានាការប្រើប្រាស់ និងការផលិតដោយនិរន្តរភាព’ និង SDG 13 ‘ចាត់វិធានការជាបន្ទាន់ដើម្បីប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា’។<br>សកម្មភាពនេះក៏ឆ្លើយតបដោយផ្ទាល់ទៅនឹងអាណត្តិរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពផងដែរ ដែលរួមចំណែកក្នុងការធ្វើឱ្យសង្គមទាំងមូលចូលរួមនៅក្នុងកិច្ចប្រឹងប្រែងរបស់ប្រទេសដើម្បីបន្តដំណើរលើមាគ៌ាអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិចនិងធន់នឹងអាកាសធាតុ។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | សកម្មភាពនេះផ្សំដោយកិច្ចផ្តួចផ្តើមមួយចំនួន ដែលភាគច្រើនគឺជាផ្នែកមួយនៃកិច្ចប្រឹងប្រែងដែលមានស្រាប់របស់ក្រសួងបរិស្ថាន ដើម្បីចូលរួម និងបង្កើនការយល់ដឹងរបស់ក្រុមគោលដៅខុសៗគ្នាអំពីការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការប្រើប្រាស់និងផលិតដោយនិរន្តរភាព។<br>សកម្មភាពសំខាន់ៗនៅក្នុងផ្នែកនេះរួមមាន៖<br>• ការរៀបចំឱ្យមានការចូលរួម ការបង្កើនការយល់ដឹង និងយុទ្ធសាស្ត្រផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង ការប្រើប្រាស់មេរៀនពីការសិក្សា KAP 1 និង 2<br>• រៀបចំការសិក្សា KAP III (រួមបញ្ចូលអនុសាសន៍នៃយុទ្ធសាស្ត្រពាក់ព័ន្ធអំពី M&E) និង<br>• ការអនុវត្តសកម្មភាពអាទិភាពនៅក្រោមយុទ្ធសាស្ត្រនេះសម្រាប់ឆ្នាំ 2016-2018។<br>សកម្មភាពនានាដូចមានខាងក្រោមនេះ បង្ហាញពីការចូលរួម និងកិច្ចផ្តួចផ្តើមដែលមានស្រាប់ជាច្រើនដើម្បីបង្កើនការយល់ដឹង ដែលនឹងចាត់ជាអាទិភាពក្នុងពេលរៀបចំយុទ្ធសាស្ត្រនេះ។<br>• ការសម្របសម្រួលនិងការអនុវត្តសាលាបៃតង ដោយរួមបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងទីក្រុងនិងខេត្តនានា ដែលរួមទាំង ការបង្កើតក្លឹបបរិស្ថាននៅតាមសាលារៀន<br>• បង្កើនការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុនៅទូទាំងប្រព័ន្ធព័ត៌មាន (ដោយផ្អែកលើអនុសាសន៍នៃការសិក្សា KAP) និងយុទ្ធនាការតស៊ូមតិអំពីការប្រែប្រួលអាកាសធាតុដូចជា ការរៀបចំសាកល្បងកម្មវិធីតាមទូរទស្សន៍ទៅអនាគត‘នាទីបៃតងនៅកម្ពុជា’ជាមួយការបង្កើតភាពជាដៃគូតាមការចាំបាច់<br>• ការចូលរួមរបស់បណ្តាញយុវជនស្ម័គ្រចិត្តនៅក្នុងយុទ្ធនាការបង្កើនការយល់ដឹង និងសកម្មភាពអនុវត្តបង្ហាញ ដោយធ្វើការជាភ្នាក់ងារជំរុញការកែប្រែនៅក្នុងសង្គម<br>• សហការជាមួយក្រសួងទេសចរណ៍និងវិស័យឯកជនដើម្បីលើកកម្ពស់យុទ្ធនាការទេសចរណ៍ (ទេសចរម្នាក់-ឈើមួយដើម, គ្មានថង់ប្លាស្ទិក។ល។) ដែលរួមចំណែកបង្កើន |

| | |
|---|---|
| | ភាពធន់នឹងអាកាសធាតុ ការប្រើប្រាស់ធនធានដោយនិរន្តរភាព និងកិច្ចគាំពារបរិស្ថាន<br>• បង្កើនការយល់ដឹងរបស់វិស័យឯកជនអំពីការគំរាមកំហែង និងឱកាសពីការប្រែប្រួលអាកាសធាតុ និងការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ-ឯកជនដើម្បីការផ្សព្វផ្សាយ<br>• ផលិតនិងសាកល្បងឯកសារ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនិងការប្រើប្រាស់និងការផលិតដែលមាននិរន្តរភាព។<br>ផលប្រយោជន៍រំពឹងទុកខ្លះៗ នឹងកើតចេញពីកំណើនការយល់ដឹងរបស់ក្រុមគោលដៅខុសៗគ្នាអំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការឆ្លើយតបដែលមានសក្តានុពលនិងទម្លាប់ល្អ (នៅតាមសហគមន៍ ធុរកិច្ច ឬ កម្រិតបុគ្គល) និងឱកាសដើម្បីដែលអាចប្រើប្រាស់ជាមួយសក្តានុពលដើម្បីកែប្រែយ៉ាងច្រើននៅក្នុងរយៈពេលមធ្យម និងវែង នូវគំរូនៃការផលិតនិងការប្រើប្រាស់ ការប្រឈមហានិភ័យ និងជម្រើសផ្សេងទៀតរបស់បុគ្គលដែលអាចរួមចំណែកឈានទៅរកសង្គមមួយដែលបញ្ចេញកាបូនតិច និងកាន់តែធន់នឹងអាកាសធាតុ។ |
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | ការចូលរួម និងបង្កើនការយល់ដឹងរបស់ប្រជាជនត្រូវបានចាត់ទុកថាជាសមាសភាគសំខាន់មួយនៃការកែប្រែទស្សនៈ និងឥរិយាបថរបស់ប្រជាជន និងនៅទីបំផុត ការប្រព្រឹត្តដែលមាននិងជម្រើសដែលកាន់តែមាននិរន្តរភាព ដែលរួមចំណែកក្នុងការធ្វើឱ្យមានការប្រែប្រួលទៅរកទម្រង់ដែលកាន់តែមាននិរន្តរភាពនៃការផលិតនិងការប្រើប្រាស់ និងទៅរកសង្គមដែលកាន់តែធន់នឹងអាកាសធាតុ។ទោះជាយ៉ាងណាក៏ដោយ យើងនៅត្រូវការយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពដើម្បីទាញយកប្រយោជន៍ជាអតិបរមាពីការវិនិយោគនានាដែលបានធ្វើឡើង នៅក្នុងកិច្ចផ្តួចផ្តើមបង្កើនការចូលរួមនិងការយល់ដឹង រួមជាមួយកម្មវិធី M&E សម្រាប់រយៈពេលវែងដើម្បីវាយតម្លៃជោគជ័យ និងប្រសិទ្ធភាពនៃការចំណាយលើយុទ្ធសាស្ត្រដែលបានរៀបចំឡើងនិងការអនុវត្តកិច្ចផ្តួចផ្តើមរបស់ខ្លួនដែលបានចាត់ជាអាទិភាព។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | • ការដឹកនាំនិងការចូលរួមនៃអ្នកពាក់ព័ន្ធជាច្រើននៅក្នុងការរៀបចំយុទ្ធសាស្ត្រ ដែលមានប្រសិទ្ធភាពដើម្បីបង្កើនការចូលរួមនិងការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង (ដែលសកម្មភាពដំបូងនឹងត្រូវអនុវត្តនៅក្រោមសកម្មភាពនៃ CCAP)<br>• សមត្ថភាពចរចា ដើម្បីឱ្យមានការផ្លាស់ប្តូរ/ការកែសម្រួលសកម្មភាពនានា ដែលកំពុងអនុវត្តនិងគ្រោងឡើង អនុលោមតាមអនុសាសន៍នៅក្នុងយុទ្ធសាស្ត្រនេះ<br>• សមត្ថភាពរបស់ផ្នែក KMIS នៃនាយកដ្ឋានDCC ដោយសហការជិតស្និទ្ធជាមួយ GED និង DGEKI ដើម្បីសម្របសម្រួល និងតាមដានសកម្មភាពរបស់ភ្នាក់ងារនានាជាច្រើន<br>• វត្តមាននិងនិរន្តរភាពនៃការផ្តល់មូលនិធិ |
| **សូចនាករជោគជ័យ** | • ចំនួនកិច្ចផ្តួចផ្តើមដែលបានចាត់ជាអាទិភាពនៅក្នុងយុទ្ធសាស្ត្រនេះដែលកំពុងអនុវត្ត<br>• ចំនួនកិច្ចផ្តួចផ្តើមសហការកំពុងអនុវត្តដែលដឹកនាំដោយអ្នកពាក់ព័ន្ធនានាក្រោមភាពជាដៃគូជិតស្និទ្ធជាមួយក្រសួងបរិស្ថាន<br>• ការសិក្សា KAP 3 បានធ្វើឡើងជាមួយលទ្ធផលដែលបង្ហាញពីការកែលម្អជារួម |
| **ការចាត់ចែងអនុវត្ត** | *ដឹកនាំដោយ៖* DCC និង GED នៃ MOE ដែលជាផ្នែកមួយនៃលេខាធិការដ្ឋាន NCSD<br>*ក្រោមកិច្ចសហការជាមួយ៖* DGEKI នៃMoE, MoEYS, MME, MIH, ក្រសួងព័ត៌មាន, MoT និងអ្នកពាក់ព័ន្ធជាច្រើន និងដៃគូអភិវឌ្ឍន៍នានា |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 600.000 ដុល្លាអាមេរិក<br><br>មូលនិធិដែលបានកៀរគរ៖ 275.000ដុល្លាអាមេរិក (ថវិការំពឹងថាទទួលបានពីរដ្ឋាភិបាលសម្រាប់រយៈពេល 3ឆ្នាំ); 156.484 ដុល្លាអាមេរិក(បន្ថែមពី CCCA រហូតដល់ឆ្នាំ 2016, |

| | |
|---|---|
| | បញ្ជាក់តាមក្រោយ); 101.900 ដុល្លាអាមេរិក(SPCR) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | ថវិការដ្ឋ មូលនិធិទ្វេភាគីនិងពហុភាគីនិងមូលនិធិបន្សាំ |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 11: លើកកម្ពស់ និងកែលម្អសមត្ថភាពបន្សាំរបស់សហគមន៍ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ*

| | |
|---|---|
| សកម្មភាព 11 | **លើកកម្ពស់ និងកែលម្អសមត្ថភាពបន្សាំរបស់សហគមន៍ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 6: លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត** |
| ហេតុផល | សកម្មភាពនេះមានលក្ខណៈស្របគ្នាជាមួយយុទ្ធសាស្ត្រជាតិគាំពារសង្គមដើម្បីជនក្រីក្រ និងងាយរងគ្រោះ (2011-2015) និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា2014-2023។ លើសពីនេះ សកម្មភាពនេះក៏ផ្សារភ្ជាប់ទៅនឹងប្រកាសរបស់ MoE ស្តីពីប្រតិភូកម្មមុខងារធន់នឹងការប្រែប្រួលអាកាសធាតុទៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ដែលក្នុងនោះមន្ទីរបរិស្ថានខេត្តមានអាណត្តិបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍និងវិនិយោគឃុំ ក៏ដូចជា បង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុផងដែរ។<br>សកម្មភាពនេះមានបំណងកសាងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍ដើម្បីឆ្លើយឱ្យបានប្រសើរជាងមុនទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេស ផ្តោតលើការពង្រឹងសមត្ថភាពបន្សាំរបស់សហគមន៍មូលដ្ឋាន។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | សកម្មភាពចែកចេញជាពីរផ្នែកៈ<br>• កសាងសមត្ថភាពមន្ទីរបរិស្ថានខេត្ត ដើម្បីប្រើប្រាស់ចំណេះដឹងពីអាកាសធាតុ (ទិន្នន័យអាកាសធាតុ និងលទ្ធផលពីម៉ូដែលបង្រួមមាត្រដ្ឋាន ជម្រើសបន្សាំ បច្ចេកវិទ្យា និងមេរៀនទទួលបាន) និងផ្តល់ការគាំទ្រអាជ្ញាធរឃុំក្នុងការដោះស្រាយហានិភ័យអាកាសធាតុ និងបញ្ហានានាដែលទាក់ទងនឹងសន្តិសុខស្បៀង ទឹក និងថាមពល។<br>• ផ្តល់ការគាំទ្រដល់ការអនុវត្តវិធានការបន្សាំដោយសហគមន៍ក្នុងតំបន់ការពារធម្មជាតិ។ សកម្មភាពនេះទទួលការគាំទ្រពីមូលនិធិបន្សាំតាមរយៈគម្រោងកំពុងអនុវត្ត"ពង្រឹងភាពធន់នៃសហគមន៍ជនបទដែលរស់ក្នុងតំបន់ការពារធម្មជាតិនៅកម្ពុជា"។ គម្រោងនេះមានគោលបំណងអនុវត្តអន្តរាគមន៍បន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី (EbA) និងពង្រឹងភាពធន់នឹងអាកាសធាតុនៃសហគមន៍ ដែលរស់នៅក្នុងទីតាំងអន្តរាគមន៍ចំនួនប្រាំ ក្នុងតំបន់ការពារធម្មជាតិ។<br>អត្ថប្រយោជន៍ពីវិធានការបន្សាំដែលបានអនុវត្ត ត្រូវបានរំពឹងថានឹងពង្រីកដល់សហគមន៍នៅតំបន់ខ្សែទឹកខាងក្រោមនៃទីតាំងជ្រើសរើសទាំងនេះ។ លទ្ធផលរំពឹងទុកសំខាន់ៗ រួមបញ្ចូលការកាត់បន្ថយសំណឹកដី និងកំណើនផលិតភាពនិងសន្តិសុខស្បៀង តាមរយៈការស្តារព្រៃឈើឡើងវិញ ការប្រើប្រាស់ប្រភេទដើមឈើដែលផ្តល់ប្រយោជន៍ច្រើនយ៉ាង ពូជស្រូវមួយចំនួនដែលធន់នឹងគ្រោះរាំងស្ងួត និងវិធានការដទៃទៀតដើម្បីបង្កើនប្រពលភាពនិងពិពិធកម្មផលិតភាពនៃដីកសិកម្មរបស់គ្រួសារនានា។ |

| | |
|---|---|
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | សមាសភាគទីមួយបង្កើនជំនួយបច្ចេកទេសដែលផ្តល់ដោយ MoE សម្រាប់ការរៀបចំនិងអនុវត្តដំណើរការរៀបចំផែនការនៅមូលដ្ឋាន ជាមួយថវិកាពីក្រសួងមហាផ្ទៃ (មូលនិធិឃុំ/សង្កាត់នៃរាជរដ្ឋាភិបាលកម្ពុជា) ដែលបម្រុងទុកសម្រាប់ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់។ មូលនិធិនេះច្រើនតែបំពេញបន្ថែមដោយមូលនិធិពី NGOs។<br><br>នៅក្នុងសមាសភាគទីពីរ កំណើនផលិតភាពដែលរំពឹងថាបានពីអន្តរាគមន៍កសិកម្មអភិរក្សជីនៅក្នុងតំបន់ការពារធម្មជាតិ នឹងផ្តល់ឱ្យសហគមន៍ទាំងនោះនូវស្បៀងនិងផលចំណូល និងកាត់បន្ថយសម្ពាធមកលើព្រៃឈើ ការធ្វើឱ្យប្រព័ន្ធសេវាអេកូឡូស៊ីកាន់តែធន់នឹងការប្រែប្រួលអាកាសធាតុ។ អត្ថប្រយោជន៍នៃការគ្រប់គ្រងតំបន់ទេសភាពទាំងនេះក្នុងការពង្រឹងសេវាកម្មប្រព័ន្ធអេកូឡូស៊ីនឹងពង្រីកដល់សហគមន៍ខ្សែផ្សេងៗទៀតហួសទីតាំងជ្រើសរើសទៅទៀត។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | ការអភិវឌ្ឍសមត្ថភាព មានគោលដៅពង្រឹងសមត្ថភាពសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនិងការរៀបចំផែនការបន្សាំ ដែលនឹងផ្តល់ឱ្យមន្ទីរបរិស្ថានខេត្តនិងសហគមន៍។<br><br>ការសម្របសម្រួលដោយប្រសិទ្ធភាពជាមួយក្រសួងមហាផ្ទៃនិងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD) ក៏ដូចជា ការសម្របសម្រួលដោយប្រសិទ្ធភាពរវាងមន្ទីរបរិស្ថានខេត្តនិងក្រុមប្រឹក្សាឃុំ គឺជាគន្លឹះនៃការបញ្ជ្រាបដោយជោគជ័យនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន។<br><br>ការសម្របសម្រួល ក៏ជាតម្រូវការផងដែរ ជាមួយកិច្ចប្រឹងប្រែងអភិរក្សដែលមានស្រាប់ក្នុងតំបន់ការពារធម្មជាតិមួយចំនួន។ |
| **សូចនាករជោគជ័យ** | • ចំនួនមន្ទីរបរិស្ថានខេត្តដែលមានសមត្ថភាពច្រើនជាងមុនដើម្បីសម្របសម្រួលការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងដើម្បីផ្តល់ការគាំទ្រដល់សហគមន៍អំពីការរៀបចំផែនការអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិចនិងធន់នឹងអាកាសធាតុ<br>• ចំនួនសំណើផែនការអភិវឌ្ឍន៍/វិនិយោគឃុំ ជាមួយវិធានការបន្សាំ/កាត់បន្ថយការប្រែប្រួលអាកាសធាតុ<br>• កម្រិតថវិកាពីមូលនិធិឃុំ/សង្កាត់ដែលបានផ្តល់សម្រាប់អន្តរាគមន៍លើផែនការអភិវឌ្ឍន៍/វិនិយោគឃុំ |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋាន DCC នឹងផ្តល់ការគាំទ្របច្ចេកទេសដល់មន្ទីរបរិស្ថានខេត្តអំពីការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍/វិនិយោគឃុំ។<br><br>នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ នៃ DGNCPA<br><br>សកម្មភាពនានានឹងត្រូវអនុវត្តក្រោមកិច្ចសហការជិតស្និទ្ធជាមួយ NCDD។ |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 2,5 លានដុល្លា<br><br>មូលនិធិដែលបានកៀរគរ៖ 2 លានដុល្លាអាមេរិក (ពីមូលនិធិបន្សាំសម្រាប់សកម្មភាពទីពីរ); 62.000 ដុល្លាអាមេរិក (CCCA); មូលនិធិបន្ថែមពីថវិការដ្ឋាភិបាលស្តីពីប្រតិភូកម្មមុខងារដល់ថ្នាក់ខេត្ត (ចំនួននឹងបញ្ជាក់តាមក្រោយ) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | មូលនិធិបន្សាំ |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 12: ប្រកាសឱ្យប្រើប្រាស់និងអនុវត្តប្រព័ន្ធ M&E នៅថ្នាក់ជាតិ និងតាមវិស័យ*

| | |
|---|---|
| **សកម្មភាព 12** | **ប្រកាសឱ្យប្រើប្រាស់និងអនុវត្តប្រព័ន្ធ M&E នៅថ្នាក់ជាតិ និងតាមវិស័យ** |
| **គោលបំណងយុទ្ធសាស្ត្រនៃ CCCSP** | **ទិសដៅជាយុទ្ធសាស្ត្រ 7: ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួលសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ** |
| **ហេតុផល** | ការទទួលស្គាល់ថា ការអភិវឌ្ឍរបស់កម្ពុជាពឹងផ្អែកលើថាតើប្រទេសនេះអាចឆ្លើយតបបានល្អកម្រិតណាទៅនឹងការប្រឈមនានាដែលបង្កដោយការប្រែប្រួលអាកាសធាតុ គឺជាគន្លឹះក្នុងការធានាថា ការអនុវត្តយុទ្ធសាស្ត្រជាតិជារួមសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជា ផែនការ CCAPs តាមវិស័យ មានការសម្របសម្រួល និងតាមដានដោយប្រសិទ្ធភាព ដើម្បីការឆ្លើយតបនានាអាចកែសម្រួលតាមការចាំបាច់ និងសម្រេចគោលបំណងរំពឹងទុក។<br>ក្របខ័ណ្ឌជាតិសម្រាប់តាមដាន និងវាយតម្លៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនឹងសម្រួលឱ្យមានការសម្របសម្រួលនិងការតាមដានប្រសិទ្ធភាពនៃការឆ្លើយតបបច្ចុប្បន្ន ការឃ្លាំមើលផលប៉ះពាល់នៃអន្តរាគមន៍តបនឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍសមត្ថភាពជារួមរបស់ស្ថាប័នជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការជំរុញការអភិវឌ្ឍដែលបញ្ចេញកាបូនតិចនិងធន់នឹងអាកាសធាតុ ការកាត់បន្ថយភាពងាយរងគ្រោះនិងការធានាប្រសិទ្ធភាពក្នុងការធ្វើឱ្យការអភិវឌ្ឍជាតិស្ថិតក្នុងដំណើរត្រឹមត្រូវ។<br>ក្នុងឋានៈជាលេខាធិការដ្ឋានNCSD, DCC គាំទ្រដល់ក្រុមប្រឹក្សានេះក្នុងការសម្របសម្រួលនិងតាមដានប្រកបដោយប្រសិទ្ធភាព នូវប្រសិទ្ធភាពនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ ដើម្បីអាចសម្រេចបានតាមចក្ខុវិស័យដែលកំណត់ដោយ CCCSP។<br>ផែនការ CCCSP ទទួលស្គាល់ពីសារៈសំខាន់នៃការបង្កើតក្របខ័ណ្ឌជាតិសម្រាប់តាមដាននិងវាយតម្លៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជាមួយចក្ខុវិស័យនៃការរួមបញ្ចូលក្របខ័ណ្ឌ M&E ទៅក្នុងដំណើរការរៀបចំផែនការអភវឌ្ឍន៍នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ការរៀបចំ និងការបញ្ជ្រាបក្របខ័ណ្ឌ M&E នៅថ្នាក់ជាតិ គឺជាកិច្ចប្រឹងប្រែងរយៈពេលវែង និងការពាក់ព័ន្ធជាយុទ្ធសាស្ត្រ ដោយសារវានឹងបង្កើតបរិយាកាសអំណោយផលសម្រាប់គណនេយ្យភាពនិងការរៀនសូត្រ។ |
| **ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រែប្រួលអាកាសធាតុ** | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| **ប្រភេទសកម្មភាព** | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| **សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក** | នៅកម្ពុជា ការបង្កើតក្របខ័ណ្ឌM&Eនៅថ្នាក់ជាតិ សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ កំពុងស្ថិតក្រោមការដឹកនាំនៃនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថានក្នុងនាមជាអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។<br>សកម្មភាពនេះរាប់បញ្ចូល៖ (1) ប្រកាសចាប់ផ្តើមប្រព័ន្ធ M&E នៅថ្នាក់ជាតិ (រំពឹងថានឹងធ្វើឡើងនៅចុងឆ្នាំ 2015) និងការដាក់ឱ្យដំណើរការផ្នែក M&E (ដែលស្ថិតនៅក្នុង DCC សម្រាប់រយៈពេលបីឆ្នាំដំបូង ដោយមានការចូលរួមនៃបុគ្គលិកពី MoE) (2) អភិវឌ្ឍន៍សមត្ថភាពនិងប្រព័ន្ធនានា នៅក្នុងស្ថាប័នផលិតទិន្នន័យ និង DCC ដើម្បីធានាឱ្យមានការផលិតនិងការវិភាគជាទៀងទាត់នូវសូចនាករ/សន្ទស្សន៍ដំបូងនៅថ្នាក់ជាតិ (3) ការផ្តល់សុពលភាពនិងការសម្រួល/រៀបចំសូចនាករសម្រាប់ក្របខ័ណ្ឌជាតិ (ដែលរួមទាំងការរៀបចំបន្ថែមទៀត |

| | |
|---|---|
| | នូវកម្រងទិន្នន័យឃុំដើម្បីអាចស្រង់យកបានប្រសើរជាងមុននូវទិដ្ឋភាពនានានៃភាពងាយរងគ្រោះ) (4) ធ្វើការវាយតម្លៃ (5) វិភាគ និងពិភាក្សាមេរៀនដែលទទួលបាន ដើម្បីឱ្យមានការរៀបចំផែនការនិងឆ្លុះបញ្ចាំងប្រសើរជាងមុនអំពីលទ្ធភាពកែសម្រួលCCAPsតាមការចាំបាច់។<br><br>ក្របខ័ណ្ឌM&E ជួយវាស់កម្រិតជោគជ័យនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដោយពិនិត្យមើលថាតើស្ថាប័នជាតិអាចគ្រប់គ្រងហានិភ័យអាកាសធាតុបានល្អកម្រិតណា និងតើសកម្មភាពបន្សាំ បានទទួលជោគជ័យកម្រិតណាក្នុងការកាត់បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុនិងក្នុងការធានាការអភិវឌ្ឍបានសមស្របនៅថ្នាក់ជាតិ ក៏ដូចជា ការអនុញ្ញាតឱ្យមានការអនុវត្តសកម្មភាពប្រហែលគ្នានេះនៅតាមវិស័យនានាផងដែរ។ការពាក់ព័ន្ធនៃវិស័យនានានៅក្នុងការរៀបចំក្របខ័ណ្ឌ M&E នៅក្នុង CCAP តាមវិស័យរៀងៗខ្លួន គឺជាកិច្ចការដែលកំពុងអនុវត្ត និងអាចរួមចំណែកទៅក្នុងកិច្ចប្រឹងប្រែងជារួមនៃការធានាឱ្យការឆ្លើយតបប្រព្រឹត្តទៅក្រោមការសម្របសម្រួល និងមានប្រសិទ្ធភាព។<br><br>បន្ថែមលើប្រសិទ្ធភាពខ្ពស់ជាងមុននៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលរំពឹងទុក (តាមរយៈការកែសម្រួលអន្តរាគមន៍ដែលគ្រោងដើម្បីឆ្លើយតបនឹង CC ជាមួយផលដែលទទួលបានច្រើនជាងមុន ទាក់ទងនឹងការកាត់បន្ថយភាពងាយរងគ្រោះចំពោះ CC និងក្នុងការឈានទៅគំរូអភិវឌ្ឍដែលបញ្ចេញកាបូនតិច) ប្រព័ន្ធ M&E សម្រាប់ CC ដែលមានដំណើរការល្អជាងមុន នឹងគាំទ្រដល់ការកសាងគោលនយោបាយសម្រាប់ការបន្សាំ/ការអភិវឌ្ឍ ដើម្បីផ្តល់គោលនយោបាយដែលកាន់តែមានប្រសិទ្ធភាពខ្ពស់។<br><br>កំណែលម្អគណនេយ្យភាពក៏ត្រូវបានរំពឹងផងដែរ ថានឹងសម្រួលឱ្យមានការទទួលបានហិរញ្ញវត្ថុអាកាសធាតុអន្តរជាតិថ្មីៗ និងការរៀនសូត្រពីការវិនិយោគលើវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើម្បីបង្កើតចំណេះដឹងថ្មីៗដែលសំខាន់សម្រាប់ការរៀបចំគោលនយោបាយទៅអនាគត។ |
| **ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ** | លទ្ធផលពី M&E នឹងជួយដល់ការកែសម្រួលការវិនិយោគលើផ្នែកអាកាសធាតុនៅពេលចាំបាច់ និងទោះបីបច្ចុប្បន្ន នៅពុំទាន់អាចផ្តល់ការប៉ាន់ស្មានអំពីប្រសិទ្ធភាពនៃការចំណាយក្នុងការបង្កើតប្រព័ន្ធ M&E នៅថ្នាក់ជាតិក៏ដោយ យើងរំពឹងថា ផលដែលទទួលបានក្នុងការកែសម្រួលបានទាន់ពេលវេលានូវការវិនិយោគលើ CC នឹងមានទំហំធំជាងយ៉ាងច្រើនធៀបនឹងថ្លៃចំណាយលើការបង្កើត និងរក្សាប្រព័ន្ធ M&E សមស្របសម្រាប់កិច្ចការ CC។<br><br>លើសពីនេះ គួរកត់សំគាល់ផងដែរថា ផ្នែកមួយនៃព័ត៌មានដែលផ្តល់តាមរយៈប្រព័ន្ធ M&E គឺជាផ្នែកមួយនៃការប្តេជ្ញារបស់កម្ពុជានៅក្រោមអនុសញ្ញា UNFCCC ដែលរួមចំណែកក្នុងការកៀរគរហិរញ្ញប្បទានអាកាសធាតុ។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | វត្តមានទិន្នន័យ និងសមត្ថភាពបុគ្គលិកដើម្បីវិភាគទិន្នន័យគឺជាតម្រូវការចាំបាច់។<br><br>ការចូលរួមសកម្មនៃ MoP ជាមួយការផ្តល់បុគ្គលិកបច្ចេកទេសយ៉ាងហោចណាស់មួយរូប មកធ្វើការនៅក្នុងផ្នែក M&E ដែលតាំងនៅក្នុងនាយកដ្ឋាន DCC។<br><br>ប្រភពមូលនិធិសម្រាប់ការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធ M&E នៅថ្នាក់ជាតិនិងតាមវិស័យគឺជាតម្រូវការចាំបាច់។ |
| **សូចនាករជោគជ័យ** | ប្រកាសចាប់ផ្តើម និងអនុវត្តប្រព័ន្ធ M&E នៅថ្នាក់ជាតិ ជាមួយរបាយការណ៍ M&Eចំនួនពីរ។<br><br>ចំនួនរដ្ឋមន្ត្រី/ស្ថាប័ន ឬ វិស័យ ដែលបានបង្កើតប្រព័ន្ធ M&E |

| | |
|---|---|
| **ការចាត់ចែងអនុវត្ត** | *នាយកដ្ឋានទទួលខុសត្រូវ៖* នាយកដ្ឋានប្រែប្រួលអាកាសធាតុ (លេខាធិការដ្ឋាន NCSD), នាយកដ្ឋានផែនការនិងថវិកា (DGAF)<br>នាយកដ្ឋានទទួលបន្ទុកបង្កើតសូចនាករ/សន្ទស្សន៍ M&E នៅថ្នាក់ជាតិនិងតាមវិស័យ។ |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | ថ្លៃចំណាយសរុបសម្រាប់សកម្មភាពនេះ៖ 215.000 ដុល្លាអាមេរិក<br>តួលេខនេះរាប់បញ្ចូលថ្លៃចំណាយប្រតិបត្តិរបស់ផ្នែក M&E នៃ DCC និងការអភិវឌ្ឍសមត្ថភាពរបស់ផ្នែកនេះ (ដែលរួមទាំង ផ្តល់ការគាំទ្រដល់ការងារ M&E តាមវិស័យ)<br>ការគាំទ្រដល់ MoE ក្នុងការរៀបចំ និងដាក់ឱ្យអនុវត្តការងារ M&E តាមវិស័យនៅពុំទាន់បានកំណត់នៅឡើយទេ និងពុំបានរួមបញ្ចូលនៅក្នុងថ្លៃប៉ាន់ស្មាននៅឡើយទេ ទោះបីវានឹងរួមចំណែកក្នុងការពង្រឹងប្រព័ន្ធ M&E នៅថ្នាក់ជាតិក៏ដោយ។ |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | IIED, GIZ និង CCCA |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 13: ការកសាងសមត្ថភាពស្ថាប័នជាតិ សម្របសម្រួលការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ*

| | |
|---|---|
| សកម្មភាព 13 | ការកសាងសមត្ថភាពស្ថាប័នជាតិ សម្របសម្រួលការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | ទិសដៅជាយុទ្ធសាស្ត្រ 7: ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួលសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ |
| ហេតុផល | សកម្មភាពនេះឆ្លើយតបនឹងអាទិភាពគន្លឹះមួយនៃ NSDP - ការពង្រឹងសមត្ថភាពលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដើម្បីសម្របសម្រួលសកម្មភាពអន្តរក្រសួង និងគ្រប់គ្រងមូលនិធិប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ។<br>ក្រុមប្រឹក្សាជាតិដើម្បីការអភិវឌ្ឍដោយចីរភាព (NCSD) ដែលជាស្ថាប័នអន្តរក្រសួង ដែលបានបង្កើតឡើងនៅខែឧសភា ឆ្នាំ2015 ដើម្បីជំនួស NCCC បច្ចុប្បន្ននេះមានអាណត្តិសម្របសម្រួល ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | • ធ្វើការវាយតម្លៃតម្រូវការការកសាងសមត្ថភាព និងបង្កើតកម្មវិធីអភិវឌ្ឍន៍សមត្ថភាពសម្រាប់ឆ្នាំ 2016-2023 ដោយផ្តោតលើរចនាសម្ព័ន្ធស្ថាប័នដែលមានបច្ចុប្បន្នសម្រាប់ការឆ្លើយតបនឹង CC (ដោយផ្តោតលើ NCSD និងលេខាធិការដ្ឋាន, CCTT, ក្រុមការងារតាមវិស័យ)<br>• រៀបចំផែនការការងារសម្រាប់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពរយៈពេលបីឆ្នាំដំបូង (2016-2018) និងអនុវត្តសកម្មនានាដែលផ្តោតលើការអភិវឌ្ឍសមត្ថភាពរបស់ MoE/លេខាធិការដ្ឋាន NCSD (DCC) ដើម្បីផ្តល់ការគាំទ្រដល់ NCSD, CCTT និងក្រុមការងារ ដែលនឹងបង្កើតឡើង ដើម្បីសម្របសម្រួលការអនុវត្តដោយប្រសិទ្ធភាពនូវការឆ្លើយតបនឹង CC នៅថ្នាក់ជាតិ និងចូលរួមនៅក្នុងការចរចាជាអន្តរជាតិ។<br>• អនុវត្តសកម្មភាពអភិវឌ្ឍន៍សមត្ថភាពដែលផ្តោតលើ NCSD, CCTT និងក្រុមការងារដែលត្រូវបង្កើតឡើង (តាមវិស័យ ឬ តាមជំនាញ)។ |
| ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ | សកម្មភាពនេះនឹងពង្រឹងសមត្ថភាពរបស់ស្ថាប័នដែលមានស្រាប់ ដែលទទួលខុសត្រូវលើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងត្រូវបានរំពឹងថានឹងបង្កើតប្រសិទ្ធភាពជារួមនៃការវិនិយោគលើការឆ្លើយតបនឹងប្រែប្រួលអាកាសធាតុទាំងក្នុងរយៈពេលមធ្យម និងពេលវែង។ |
| លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ | • ការចាត់ចែងស្ថាប័នត្រូវបានរៀបចំរួចរាល់ (ដែលរួមទាំង ការតែងតាំងសមាជិក ដើម្បីរួមបញ្ចូលក្រុមប្រឹក្សា និងគណៈកម្មាធិការបច្ចេកទេសជាមួយគ្នា ក៏ដូចជា ក្រុមការងារជាមួយលក្ខខណ្ឌប្រតិបត្តិដែលបានអនុម័តឯកភាព)<br>• សកម្មភាពនេះគួរតែបានសម្របសម្រួលជាមួយការអនុវត្តសកម្មភាព 14 |
| សូចនាករជោគជ័យ | • កម្រិតសមត្ថភាពស្ថាប័នរបស់លេខាធិការដ្ឋាន NCSD (ធនធានមនុស្ស និងប្រព័ន្ធ)<br>• ចំនួនក្រសួងជាមួយការចាត់ចែងស្ថាប័នដើម្បីគ្រប់គ្រងផែនការ CCAP របស់ខ្លួននិងរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាពរបស់ CCTT និងក្រុមការងារជំនាញ |

| | |
|---|---|
| | • ចំនួនក្រុមការងារអន្តរក្រសួងដែលបានបង្កើត (ផ្តោតលើរយៈពេលបីឆ្នាំ ដែលនៅពុំទាន់បានកំណត់ ប៉ុន្តែមានការរំពឹងថា យ៉ាងហោចណាស់មានក្រុមការងារចំនួនប្រាំ ដែលផ្តោតជាពិសេសលើការប្រែប្រួលអាកាសធាតុ ពោលគឺហិរញ្ញវត្ថុអាកាសធាតុ ការបន្សុំ ការកាត់បន្ថយ បច្ចេកវិទ្យា និង M&E)។ |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋាន DCC នឹងដឹកនាំការរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពជារួម ដោយពិគ្រោះយោបល់ជាមួយ NCSD។ |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 5 លានដុល្លាអាមេរិក<br>មូលនិធិដែលបានកៀរគរ៖ 36.000 ដុល្លាអាមេរិក (CCCA, នឹងបញ្ជាក់ជាក្រោយ)<br>មូលនិធិបន្ថែមតាមរយៈ UNDP (នឹងបញ្ជាក់ជាក្រោយ), |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | EU, Sida, UNDP, SPCR |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 14: គាំទ្រដល់ក្រសួងពាក់ព័ន្ធដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងការលើកថវិកា*

| | |
|---|---|
| សកម្មភាព 14 | គាំទ្រដល់ក្រសួងពាក់ព័ន្ធដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងការលើកថវិកា |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | ទិសដៅជាយុទ្ធសាស្ត្រ 7: ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួលសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ |
| ហេតុផល | សកម្មភាពនេះស្របគ្នាជាមួយ NSDP ជាពិសេស ការរួមចំណែកទៅក្នុងសូចនាករមួយអំពីការប្រែប្រួលអាកាសធាតុពោលគឺចំនួនស្ថាប័នរដ្ឋាភិបាលដែលមានផែនការឆ្លើយតបនឹងCC។<br>សកម្មភាពនេះជាផ្នែកមួយនៃមុខងាររបស់ NCSD ពោលគឺ ផ្តល់ការគាំទ្រដល់ស្ថាប័នរដ្ឋាភិបាលក្នុងការរៀបចំផែនការចាំបាច់ដើម្បីសម្រេចបានការអភិវឌ្ឍដោយចីរភាពនៅកម្ពុជា។<br>សកម្មភាពនេះរួមចំណែកទៅក្នុងទាំងកិច្ចប្រឹងប្រែងបន្សាំ និងកាត់បន្ថយ និងតាមរយៈការវិភាគបានច្បាស់លាស់អំពីការវិនិយោគជាអាទិភាព និងផលប៉ះពាល់រំពឹងទុក នៅក្នុងការកសាងភាពធន់ និងកាត់បន្ថយការបញ្ចេញឧស្ម័ន និងការពង្រឹងប្រព័ន្ធផែនការនិងថវិកាជាតិ សមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាលត្រូវបានរំពឹងថានឹងកើនឡើងដើម្បីទាក់ទាញហិរញ្ញប្បទានអាកាសធាតុ ដូច្នេះអាចឱ្យស្ថាប័នទាំងនោះពង្រីកការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | • រៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (CCAPs)<br>• ការអនុវត្តដំណើរការ NAP ដែលទាក់ទងនឹងការរៀបចំផែនការអភិវឌ្ឍន៍និងការលើកថវិកា ដែលរួមទាំង ការប្រកាសដំណើរការអនុវត្ត NAP របស់កម្ពុជា និងការរៀបចំកម្មវិធីត្រៀមលក្ខណៈសម្រាប់ហិរញ្ញវត្ថុអាកាសធាតុ<br>• គាំទ្រដល់ក្រសួង MEF ក្នុងការរៀបចំកូដ សម្រាប់បង្ហាញពីការចំណាយលើការឆ្លើយតបនឹង CC និងធ្វើការពិនិត្យការចំណាយសាធារណៈលើការឆ្លើយតបនឹងCC<br>• គាំទ្រដល់ CDC ក្នុងបង្ហាញការប្រែប្រួលអាកាសធាតុនៅក្នុងជំនួយអភិវឌ្ឍន៍ផ្លូវការ<br>• គាំទ្រដល់វិស័យនានាក្នុងការវិភាគថ្លៃចំណាយ-ផលចំណេញ នៃការវិនិយោគលើការឆ្លើយតបនឹង CC ដែលចាត់ជាអាទិភាពនៅក្នុង CCAP និងការរួមបញ្ចូលទៅក្នុងផែនការវិនិយោគតាមវិស័យ និងថវិកាប្រចាំឆ្នាំតាមវិស័យ<br>• បង្កើតមូលនិធិជំនួយឥតសំណងសម្រាប់សាកល្បងសកម្មភាពឆ្លើយតបនឹង CC ដោយក្រសួងពាក់ព័ន្ធ និងជំរុញការស្រាវជ្រាវបែបច្នៃប្រឌិតអំពី CC ដោយផ្អែកលើបទពិសោធន៍របស់ DCC ជាមួយយន្តការផ្តល់ជំនួយរបស់ CCCA។ |
| ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ | កំណើនសមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាលលើការរៀបចំផែនការ និងការលើកថវិកានឹងបង្កើនប្រសិទ្ធភាពនៃការចំណាយនៅក្នុងការវិនិយោគតាមវិស័យ និងនៅថ្នាក់ជាតិ លើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ជាមួយកំណើនប្រសិទ្ធភាពនៃការចំណាយ ត្រូវបានរំពឹងផងដែរសម្រាប់ការវិនិយោគលើការអភិវឌ្ឍផ្សេងទៀត)។ លើសពីនេះ គម្រោងបានអនុវត្តបង្ហាញ |

| | |
|---|---|
| | ខ្លះៗ ដែលបានចាត់ជាអាទិភាពនៅក្នុង CCAPs នឹងបង្ហាញពីប្រសិទ្ធភាពនៃការចំណាយនៃការវិនិយោគជាក់លាក់លើ CC ដោយផ្តល់ភស្តុតាងអំពីផលប៉ះពាល់វិជ្ជមានដែលអាចគណនាបាន ដែលត្រូវបានរំពឹងថានឹងជួយបង្កើនចំណាប់អារម្មណ៍ពីវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និង NGOs ដែលរួមចំណែកក្នុងការកៀរគរហិរញ្ញវត្ថុបន្ថែម។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | • សកម្មភាពនេះគួរតែបានអនុវត្តជាមួយសកម្មភាព 13<br>• កិច្ចព្រមព្រៀងរវាង MoE និងក្រសួងពាក់ព័ន្ធសម្រាប់ការរៀបចំ CCAP<br>• យន្តការសម្របសម្រួលយ៉ាងរឹងមាំជាមួយក្រសួងពាក់ព័ន្ធ គឺជាតម្រូវការចាំបាច់ដើម្បីធានាការអនុវត្តសកម្មភាពនេះឱ្យមានជោគជ័យ<br>• បុគ្គលិកបច្ចេកទេសក្នុងក្រសួងនានាដែលពាក់ព័ន្ធក្នុងសកម្មភាពនេះ រួមបញ្ចូលបុគ្គលិកដែលមានមុខងាររៀបចំផែនការ និងលើកថវិកា ដែលអាចយល់ដឹងអំពីសញ្ញាណនៃ CC និងការពាក់ព័ន្ធសម្រាប់វិស័យរបស់ពួកគេ។ |
| **សូចនាករជោគជ័យ** | • ចំនួនផែនការ CCAPs ដែលបានរៀបចំ និងរបាយការណ៍ពីការអនុវត្តផែនការទាំងនោះ<br>• កម្រិតនៃការអនុវត្តដំណើរការ NAP<br>• កម្រិតនៃការដឹកនាំរបស់ MEF លើការរៀបចំកូដ និង CPEIR និងរបស់ CDC លើការបង្ហាញពីការប្រែប្រួលអាកាសធាតុនៅក្នុងជំនួយអភិវឌ្ឍន៍ផ្លូវការ<br>• ចំនួនអ្នកទទួលជំនួយដែលបានទទួលការគាំទ្រហិរញ្ញវត្ថុសម្រាប់សាកល្បង CCAPs<br>• ចំនួនក្រសួងពាក់ព័ន្ធដែលដាក់ឱ្យប្រើប្រាស់លក្ខណៈវិនិច្ឆ័យCCសមស្របសម្រាប់ជ្រើសរើសគម្រោងវិនិយោគ<br>• ចំនួនដែលបានវិភាជន៍ប្រចាំឆ្នាំសម្រាប់វិនិយោគតាមវិស័យលើសកម្មភាពក្នុងCCAP។ |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋាន DCC នឹងដឹកនាំការរៀបចំ និងអនុវត្តសកម្មភាពនេះ ដោយពិគ្រោះយោបល់ជាមួយ NCSD និងសម្របសម្រួលជាមួយ MEF និង CDC និងសហការជាមួយនាយកដ្ឋានវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា និងនាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុនៃក្រសួងបរិស្ថាន។<br><br>កិច្ចសហការជាមួយក្រសួងពាក់ព័ន្ធក្នុងការរៀបចំនិងអនុវត្ត CCAPs។ |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | ៨ លានដុល្លាអាមេរិក<br><br>មូលនិធិដែលបានកៀរគរៈ 1,5 លានដុល្លាអាមេរិក (CCCA); មានមូលនិធិបន្ថែម តាមរយៈដំណើរការ NAP (បញ្ជាក់តាមក្រោយ) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | EU, Sida, UNDP, GIZ |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 15: ពង្រឹងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តនានាសម្រាប់ការអភិវឌ្ឍកាបូនតិចធន់នឹងអាកាសធាតុ*

| | |
|---|---|
| សកម្មភាព 15 | **ពង្រឹងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តនានាសម្រាប់ការអភិវឌ្ឍកាបូនតិចធន់នឹងអាកាសធាតុ** |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 7: ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួលសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ** |
| ហេតុផល | សកម្មភាពនេះមានភាពស្របគ្នាជាមួយគោលដៅនៃ NSDP និង CCCSP ដែលសង្កត់ធ្ងន់លើតម្រូវការឱ្យមានក្របខ័ណ្ឌច្បាប់ពេញលេញអំពីការប្រែប្រួលអាកាសធាតុ ដែលចែងពិស្តារអំពីរចនាសម្ព័ន្ធស្ថាប័ន និងហិរញ្ញប្បទាន និងការកំណត់លក្ខខណ្ឌសម្រាប់បញ្ជ្រាបCC នៅទូទាំងក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងបទបញ្ញត្តនៅថ្នាក់ជាតិ និងតាមវិស័យ (ដូចជា ច្បាប់ស្តីពី EIA ដែលចែងច្បាស់អំពី CCCSP)។<br><br>សកម្មភាពនេះមានឥទ្ធិពលមកលើកិច្ចប្រឹងប្រែង ដែលមានស្រាប់សម្រាប់ការពង្រឹងលិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួងពាក់ព័ន្ធ ដោយផ្តល់ការគាំទ្រដល់ MoE ក្នុងការធានាថា ការប្រែប្រួលអាកាសធាតុ ត្រូវបានគិតគូរនៅក្នុងករណីដែលពាក់ព័ន្ធ។<br><br>ការពិភាក្សាបច្ចុប្បន្នអំពីការរៀបចំក្រមបរិស្ថាន អាចចែងពិស្តារបន្ថែមអំពីការងារនៅក្រោមសកម្មភាពនេះ ក៏ដូចជា កម្រិតមូលនិធិដែលនឹងមានផងដែរ។ នៅដំណាក់កាលនេះ MoE នឹងកំណត់អត្តសញ្ញាណ និងផ្តល់ការគាំទ្រដល់ការពិនិត្យសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិសំខាន់ៗដែលត្រូវអនុម័តនៅក្នុងរយៈពេលខ្លីខាងមុខ។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | នៅក្នុងដំណាក់កាលដើមដំបូងនៃសកម្មភាពនេះ ការយកចិត្តទុកដាក់នឹងផ្តោតលើ៖<br>• សមាហរណកម្មបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងសេចក្តីព្រាងច្បាប់ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ជាមួយធាតុចូលពី DCC ដើម្បីធានាថា បទបញ្ញត្តនានាទៅអនាគតអំពី EIA បានគិតគូរពេញលេញអំពី CC ទាំងក្នុងបរិបទនៃច្បាប់ស្តីពី EIA ឬជំពូកពាក់ព័ន្ធនានានៅក្នុងក្រមបរិស្ថាន)។<br>• កំណត់អត្តសញ្ញាណ និងចាត់ជាអាទិភាពនូវសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ បទបញ្ញត្តិ និងស្តង់ដារនានាដែលមានបច្ចុប្បន្ន និងដែលគ្រោងអនុម័តនៅក្នុងរយៈពេលខ្លីខាងមុខ (ផ្អែកលើការសិក្សាឆ្នាំ 2013 ស្តីពីការពិនិត្យលិខិតបទដ្ឋានគតិយុត្តិអំពីCC និងពិគ្រោះយោបល់ជាមួយ CCTT) និងផ្តល់អនុសាសន៍ដើម្បីពង្រឹងការពិចារណាអំពី CC នៅក្នុងករណីដែលពាក់ព័ន្ធ។ |
| ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ | សកម្មភាពនេះនឹងពង្រឹងបរិយាកាសអំណោយផលសម្រាប់ការឆ្លើយតបនឹង CC ជាមួយអត្ថប្រយោជន៍ដែលរំពឹងទុកសម្រាប់រយៈពេលមធ្យម ដល់រយៈពេលវែង អំពីប្រសិទ្ធភាពនៃការចំណាយនៃការវិនិយោគលើការអភិវឌ្ឍ។ |
| លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ | ការដឹកនាំរបស់NCSD និងកិច្ចសហការរឹងមាំនៃCCTT និងក្រសួងពាក់ព័ន្ធ<br><br>ការសម្របសម្រួលជាមួយក្រុមការងាររបស់ MoE លើការរៀបចំក្រមបរិស្ថាន។ |

| | |
|---|---|
| **សូចនាករជោគជ័យ** | • ចំនួនសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិដែលបានពិនិត្យ និងពិគ្រោះយោបល់ (ជាមួយចំនុចដៅសម្រាប់ឆ្នាំ 2016 អំពីការពិនិត្យបានពេញលេញនូវសេចក្តីព្រាងច្បាប់ស្តីពី EIA ដើម្បីឱ្យក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តនានាទៅអនាគតសម្រាប់ EIA ចែងបានពេញលេញអំពីហានិភ័យ និងឱកាសនៃCC និងរួមបញ្ចូលយន្តការនិយ័តកម្ម ដែលឆ្លើយតបបានសមស្របទៅនឹងការរំពឹងទុកលើការប្រឈមក្នុងការអនុវត្តផងដែរ)<br>• ចំនួនក្រសួងពាក់ព័ន្ធដែលសហការជាមួយ DCC/MoE ក្នុងការកំណត់អត្តសញ្ញាណ និងពិនិត្យសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ ដើម្បីដោះស្រាយបានប្រសើរជាងមុននូវការប្រឈម និងឱកាសនៃការប្រែប្រួលអាកាសធាតុ។ |
| **ការចាត់ចែងអនុវត្ត** | នាយកដ្ឋាន DCC ដឹកនាំ ដោយពិគ្រោះយោបល់ជាមួយក្រុមដែលដឹកនាំការងាររៀបចំក្រមបរិស្ថាន និងដោយសហការជាមួយ CCTT និងក្រសួងពាក់ព័ន្ធ។ |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 100.000 ដុល្លាអាមេរិក<br>មូលនិធិដែលបានកៀរគរ៖ 21.000 ដុល្លាអាមេរិក (CCCA) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | CCCA |
| **កាលបរិច្ឆេទ** | 2016-2018 |

*សកម្មភាព 16: បង្កើតក្របខ័ណ្ឌជាតិហិរញ្ញវត្ថុកាបូន*

| | |
|---|---|
| សកម្មភាព 16 | បង្កើតក្របខ័ណ្ឌជាតិហិរញ្ញវត្ថុកាបូន |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 7: ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួលសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ** |
| ហេតុផល | ក្នុងឋានៈជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលងាយរងគ្រោះជាខ្លាំងចំពោះមុខ CC កម្ពុជាត្រូវការនូវការគាំទ្រជាច្រើន (ទាំងជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស) ដើម្បីអនុវត្តការឆ្លើយតបនឹងCC ឱ្យមានប្រសិទ្ធភាព។ UNFCCC ទទួលស្គាល់អំពីតម្រូវការគាំទ្រកម្រិតខ្ពស់ ជាពិសេស ការគាំទ្រដែលចាំបាច់សម្រាប់អនុវត្តវិធានការឆ្លើយតបនឹងCC ដោយប្រទេសកំពុងអភិវឌ្ឍន៍ និងកំពុងរៀបចំយន្តការដើម្បីបង្កើនកម្រិតហិរញ្ញវត្ថុ CC ដែលមាន។ ប៉ុន្តែ ប្រទេសនានាចាំបាច់ត្រូវមានសមត្ថភាព និងប្រព័ន្ធក្នុងកម្រិតអប្បបរមា ទើបអាចទទួលបានមូលនិធិអាកាសធាតុដោយផ្ទាល់។ ធាតុសំខាន់បំផុតមួយគឺថា ប្រទេសនានាត្រូវមានក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តច្បាស់លាស់ ដែលចែងអំពីបញ្ហាហិរញ្ញវត្ថុអាកាសធាតុ។ ទោះបីមូលនិធិពីប្រភពខុសគ្នាអាចមានលក្ខខណ្ឌខុសគ្នាក៏ដោយ ពាក់ព័ន្ធនឹងការចាត់ចែងស្ថាប័ន និង/ឬ យន្តការនៅនឹងកន្លែងក៏ដោយ កម្ពុជាត្រូវមានក្របខ័ណ្ឌជារួមដែលកំណត់ពី "គោលការណ៍អនុវត្ត" សម្រាប់ហិរញ្ញប្បទាន CC ។<br><br>សកម្មភាពនេះផ្តោតលើការពង្រីកការងារដែលមានបច្ចុប្បន្នរបស់ DCC លើការរៀបចំក្របខ័ណ្ឌបែបនេះ និងដាក់ឱ្យប្រតិបត្តិការនូវរចនាសម្ព័ន្ធស្ថាប័នដែលចាំបាច់ទាំងនោះ។<br><br>សកម្មភាពនេះត្រូវបានរំពឹងថា មិនត្រឹមតែរួមចំណែកក្នុងការទាក់ទាញហិរញ្ញវត្ថុកាន់តែច្រើនសម្រាប់ការឆ្លើយតបនឹងCC ប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងមានផលប៉ះពាល់យ៉ាងច្រើនមកលើការកសាងភាពធន់របស់សហគមន៍ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☐ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☑ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | • បង្កើតក្របខ័ណ្ឌច្បាប់សម្រាប់ហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ<br>• អនុម័តលើរចនាសម្ព័ន្ធស្ថាប័ន ដាក់ឱ្យអនុវត្តយន្តការ និងនីតិវិធីចាំបាច់សម្រាប់ការអនុម័ត និងការតាមដាន គម្រោងហិរញ្ញវត្ថុកាបូន និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកក្នុងស្ថាប័នពាក់ព័ន្ធ<br>• រៀបចំបង្កើយដំណើរការទទួលស្គាល់គុណភាពសម្រាប់ AF និង GCF<br>• អភិវឌ្ឍន៍សមត្ថភាពរបស់ NCSD និង NIE(s)<br>• ផ្តល់ការគាំទ្រដល់វិស័យនានាដើម្បីកំណត់អត្តសញ្ញាណប្រភពហិរញ្ញវត្ថុ និងដើម្បីកំណត់អត្តសញ្ញាណ និងរៀបចំសំណើគម្រោងដែលអាចផ្តល់ផលចំណេញ |
| ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ | ក្របខ័ណ្ឌច្បាប់សម្រាប់ហិរញ្ញវត្ថុកាបូន នឹងសម្រួលដល់កម្ពុជាក្នុងការទទួលបានហិរញ្ញវត្ថុអាកាសធាតុកាន់តែច្រើនឡើងសម្រាប់វិធានការកាត់បន្ថយ និងបន្សាំ។<br><br>លើសពីនេះ មានការរំពឹងថា នឹងមានការបង្កើតអត្ថប្រយោជន៍បន្ថែមលើការអភិវឌ្ឍដោយចីរភាពពីហិរញ្ញប្បទានកាបូន ឬ ការវិនិយោគផ្សេងទៀតពីមូលនិធិអាកាសធាតុ ដោយមានឥទ្ធិពលវិជ្ជមានសម្រាប់សហគមន៍មូលដ្ឋាន ជាពិសេស ដូចក្នុងករណីហិរញ្ញប្បទាន CDM ឬ |

| | |
|---|---|
| | ជាមួយកម្មវិធី REDD+ ទៅអនាគត។ |
| **លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ** | ការដឹកនាំមោះមុតរបស់ NCSD និង MoE ក្នុងការឃ្លាំមើលបានឆាប់រហ័សនូវ ការពិនិត្យនិងការអនុម័តក្របខ័ណ្ឌច្បាប់សម្រាប់ហិរញ្ញវត្ថុអាកាសធាតុ (នៅមុនកិច្ចប្រឹងប្រែងពេញលេញដទៃទៀត ដូចជា ការរៀបចំក្រមបរិស្ថាន)។<br>កិច្ចសហប្រតិបត្តិការល្អជាមួយក្រសួងពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ។ |
| **សូចនាករជោគជ័យ** | • ដំណើរការនៃការទទួលស្គាល់ ត្រូវបានបញ្ចប់ ដោយកម្ពុជាអាចទទួលបានមូលនិធិ AF, GCF និងមូលនិធិពីប្រភពដទៃទៀតដោយផ្ទាល់។<br>• ចំនួនសំណើពេញលេញដែលបានដាក់ជូនទៅប្រភពមូលនិធិខុសៗគ្នា |
| **ការចាត់ចែងអនុវត្ត** | DCC និងក្រសួងពាក់ព័ន្ធ (ជាពិសេស MAFF, MIH, MME និង MEF) |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 1 លានដុល្លាអាមេរិក<br>មូលនិធិដែលបានកៀរគរ៖ 300.000ដុល្លាអាមេរិក (GCF); 500.000ដុល្លាអាមេរិក (GIZ, បញ្ជាក់តាមក្រោយ); 30.000 ដុល្លាអាមេរិក(UNEP អំពីការទទួលស្គាល់ពី AF); 8.000ដុល្លាអាមេរិក (CCCA)។មូលនិធិបន្ថែមសម្រាប់ JCM ពីជប៉ុន (បញ្ជាក់តាមក្រោយ) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | CCCA ជំណាក់កាលទី II, UNEP, GIZ និង USAID (ក្នុងបរិបទនៃដំណើរការ NAP) |
| **កាលបរិច្ឆេទ** | 2016-2018 |

### *សកម្មភាព 17: ការរៀបចំរបាយការណ៍សម្រាប់ UNFCCC ទៅក្នុងក្របខ័ណ្ឌស្ថាប័ន*

| | |
|---|---|
| សកម្មភាព 17 | **ការរៀបចំរបាយការណ៍សម្រាប់ UNFCCC ទៅក្នុងក្របខ័ណ្ឌស្ថាប័ន** |
| គោលបំណងយុទ្ធសាស្ត្រនៃ CCCSP | **ទិសដៅជាយុទ្ធសាស្ត្រ 8: ពង្រឹងកិច្ចសហការ និងការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់និងពិភពលោក** |
| ហេតុផល | ជាហត្ថលេខីនៃUNFCCC កម្ពុជាជាប់កាតព្វកិច្ចបំពេញលក្ខខណ្ឌរាយការណ៍មួយចំនួន។ របាយការណ៍ទាំងនោះមានជាអាទិ៍ របាយការណ៍ជាតិ (NCs), របាយការណ៍នៃការចូលរួមចំណែករបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញា UNFCCC (INDCs), របាយការណ៍បច្ចុប្បន្នភាពប្រចាំពីរឆ្នាំ (BURs) ស្តីពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់, សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលសមស្របនៅថ្នាក់ជាតិ (NAMAs), ដំណើរការផែនការបន្សាំនៅថ្នាក់ជាតិ (NAP), និង REDD+។ លក្ខខណ្ឌរាយការណ៍ទាំងនេះពង្រឹងព័ត៌មាន ដែលមានស្តីពីការឆ្លើយតបនឹង CC ដែលអាចឱ្យកម្ពុជារៀនសូត្រពីកិច្ចប្រឹងប្រែងដែលបានអនុវត្ត និងដើម្បីអាចលើកផែនការ និងសម្របសម្រួលការឆ្លើយតបនឹង CC បានប្រសើរជាងមុន។ |
| ជំពូកនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | ☑ជំពូក 1 – ពង្រីកជាបន្ត ☐ជំពូក 2 – កែសម្រួល ☐ជំពូក 3 – ផ្តោតលើអាកាសធាតុ |
| ប្រភេទសកម្មភាព | ☐កាត់បន្ថយ ☐បន្សាំ ☑កាត់បន្ថយ និងបន្សាំ |
| សេចក្តីអធិប្បាយសង្ខេបអំពីសកម្មភាពលទ្ធផល និងផលប្រយោជន៍រំពឹងទុក | • បង្កើតក្រុមស្នូលរៀបចំរបាយការណ៍ (ដែលធ្វើការជាមួយផ្នែក M&E និងបុគ្គលិកគ្រប់គ្រងទិន្នន័យអាកាសធាតុ)ដែលទទួលខុសត្រូវសម្របសម្រួលជាតុចូល ការរៀបចំ និងដាក់ជូន ដើម្បីសុំការអនុម័តលើរបាយការណ៍ចាំបាច់នានានៅក្រោម UNFCCC<br>• អភិវឌ្ឍន៍សមត្ថភាពនៃក្រុមស្នូលរៀបចំរបាយការណ៍ និងរួមចំណែកក្នុងក្រុមពហុវិស័យ ដើម្បីធានាឱ្យមានរបាយការណ៍ទៅUNFCCCបានទាន់ពេលវេលាប្រកបដោយគុណភាព<br>• រៀបចំរបាយការណ៍ជាតិលើកទីបី<br>• ការរៀបចំរបាយការណ៍ 2 BURs<br>• ការរៀបចំ INDC<br>• របាយការណ៍ស្តីពីដំណើរការ NAP និង REDD+<br>• របាយការណ៍អំពីការអនុវត្ត NAMAs |
| ប្រសិទ្ធភាពខាងការចំណាយនៃសកម្មភាពនេះ | កម្ពុជាជាប់កាតព្វកិច្ចដាក់ជូនរបាយការណ៍ទាំងនេះ ក្នុងនាមជាហត្ថលេខីនៃ UNFCCC។ របាយការណ៍ទាំងនេះនឹងផ្តល់ឱ្យអ្នករៀបចំគោលនយោបាយនូវព័ត៌មានដើម្បីអាចធ្វើសកម្មភាពកាន់តែមានប្រសិទ្ធភាព និងការវិនិយោគដែលមានប្រសិទ្ធភាពកាន់តែខ្ពស់ខាងការចំណាយ។ ការរៀបចំរបាយការណ៍បានទាន់ពេលវេលាប្រកបដោយគុណភាពនឹងបង្ហាញផងដែរពីវត្តមានយន្តការគណនេយ្យភាព ដូច្នេះអាចរួមចំណែកក្នុងការទាក់ទាញហិរញ្ញប្បទានកាន់តែច្រើនជាងមុននិងធនធានផ្សេងទៀត(ដូចជា ជំនួយបច្ចេកទេសនិងបច្ចេកវិទ្យា) ដែលគាំទ្រដល់ការអភិវឌ្ឍកម្ពុជាទៅកេសង្គមមួយដែលបញ្ចេញកាបូនតិចនិងធន់នឹងអាកាសធាតុ។ |
| លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តឱ្យមានជោគជ័យ | • សកម្មភាពនេះគួតែបានសម្របសម្រួលជាមួយការអនុវត្តសកម្មភាព 5 និង 6<br>• កិច្ចសហប្រតិបត្តិការល្អជាមួយក្រសួងពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាល ជាមួយការយល់ដឹងច្បាស់លាស់អំពីតម្លៃបន្ថែមនៃរបាយការណ៍ទាន់ពេលនិងគុណភាពខ្ពស់ |
| សូចនាករជោគជ័យ | • ក្រុមរៀបចំរបាយការណ៍ត្រូវបានបង្កើតជាមួយ TORs ច្បាស់លាស់ដែលបានអនុម័តនិងការទទួលបានជំនួយបច្ចេកទេសដើម្បីបង្កើនសមត្ថភាព |

| | |
|---|---|
| | • បានរៀបចំរបាយការណ៍ INDC និងដាក់ជូនទៅ UNFCCC<br>• របាយការណ៍ជាតិលើកទីបី និងរបាយការណ៍ BUR ដំបូង បានដាក់ជូនទៅ UNFCCC<br>• ការរាយការណ៍ជាលក្ខណៈប្រព័ន្ធអំពីដំណើរការ NAP និង REDD+ |
| **ការចាត់ចែងអនុវត្ត** | MOE, DCC និងក្រសួងពាក់ព័ន្ធ |
| **ថ្លៃចំណាយប៉ាន់ស្មានសរុប** | 1,5 លានដុល្លាអាមេរិក<br>មូលនិធិដែលបានកៀរគរ៖ 140.000 ដុល្លាអាមេរិក (UKAID; UNEP បានគ្រោងសម្រាប់ INDC); 500.000 ដុល្លាអាមេរិក (UNFCCC; ផ្សេងទៀត នឹងបញ្ជាក់តាមក្រោយ,ដែលបានគ្រោងសម្រាប់ TNC); 352.000ដុល្លាអាមេរិក (GEF TF បម្រុងសម្រាប់ BUR)<br>មូលនិធិបន្ថែមសម្រាប់រាយការណ៍អំពី NAP និង REDD+ (បញ្ជាក់តាមក្រោយ) |
| **ប្រភពមូលនិធិដែលមានសក្តានុពល** | UNFCCC |
| **កាលបរិច្ឆេទ** | 2016-2018 |

# ឧបសម្ព័ន្ធ 3: បញ្ជីច្បាប់និងលិខិតបទដ្ឋានក្រោមក្រសួងបរិស្ថាន

បណ្តាបទបញ្ញត្តដែលរាជរដ្ឋាភិបាលបានរៀបចំ ដើម្បីធានាដល់ការគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះ ការគ្រប់គ្រងបឹងទន្លេសាប ការគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរនិងសមុទ្រ គុណភាពបរិស្ថាន និង សុខភាពមនុស្ស ការគ្រប់គ្រងសំណល់អោយមានប្រសិទ្ធភាព និងដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្ម ភាពការប្រែប្រួលអាកាសធាតុក្នុងវិស័យបរិស្ថាន២០១៤-២០១៨ រួមមាន៖

១ ព្រះរាជក្រឹត្យ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
២ ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងបបនីយជីវមណ្ឌលបឹងទន្លេសាប ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១
៣ ច្បាប់ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤
៤ ច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៤
៥ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ឆ្នាំ១៩៩៦
៦ ច្បាប់ស្តីពី កិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦
៧ ច្បាប់ស្តីពី ការគ្រប់គ្រងឱសថ ឆ្នាំ១៩៩៦
៨ ច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ឆ្នាំ២០០០
៩ ច្បាប់ស្តីពីអគ្គីសនីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០០
១០ ច្បាប់ភូមិបាល (ឆ្នាំ១៩៩២ និងឆ្នាំ២០០១)
១១ ច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ ២០០១
១២ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០០១
១៣ ច្បាប់ស្តីពី ជលផលចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០២
១៤ ច្បាប់ស្តីពី ព្រៃឈើ ២០០២
១៥ ព្រះរាជក្រឹត្យ ស្តីពីការបង្កើតសហគមន៍នេសាទ ២០០៥
១៦ ច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ សិប្បកម្ម (២៣.៦.២០០៦)
១៧ ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា (២០០៧)
១៨ ច្បាប់ស្តីពី សម្បទាន (ខែមេសា ២០០៨)
១៩ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក (២២.៥.២០០៨)
២០ ច្បាប់ស្តីពី ទេសចរណ៍ (១០.៦.២០០៩)
២១ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
២២ ច្បាប់ស្តីពីជីវសុវត្ថិភាព ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨
២៣ ការឱ្យសច្ចាប័នចូលជាសមាជិកនៃអនុសញ្ញា ស្តីពីការប្រែប្រួលអាកាសធាតុ ខែធ្នូ ឆ្នាំ១៩៩៥
២៤ ចូលជាសមាជិកនៃអនុសញ្ញាស្តីពីការត្រួតពិនិត្យ ការដឹកជញ្ជូន និងការបោះសំណល់ប្រកបដោយគ្រោះថ្នាក់ឆ្លងដែន ឬអនុសញ្ញាបាសែល
២៥ ចូលជាសមាជិកនៃអនុសញ្ញា វីយ៉ែន និងពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូសូន
២៦ ចូលជាសមាជិកនៃអនុសញ្ញាស្តុកខូម ស្តីពីសារជាតុបំពុលសរីរាង្គមិនងាយបំបែកជាតុនៅថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០១
២៧ ចូលជាសមាជិកនៃពិធីសារកាតាហ្សេណា។

ក្រសួងបរិស្ថានក៏មានភារៈកិច្ចអនុវត្តន៍នូវលិខិតបទដ្ឋានក្រោមច្បាប់ជាច្រើនទៀតដូចជា៖

- អនុក្រឹត្យលេខ២៧ អនក្រ បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ៣៦ អនក្រ បក ស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ៤២ អនក្រ បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសម្លេង ទឹកចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០
- អនុក្រឹត្យលេខ៤៧ អនក្រ បក ស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ២៧ អនក្រ បក ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អនុក្រឹត្យស្តីពីការតម្លើងអធិការដ្ឋានរបស់ក្រសួងបរិស្ថានទៅជាអគ្គាធិការដ្ឋាន
- អនុក្រឹត្យលេខ៥៧ អនក្រ បក ស្តីពីការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧
- អនុក្រឹត្យលេខ៧២ អនក្រ បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩
- ប្រកាសស្តីពីការប្រមូល និងដឹកជញ្ជូនសំណល់រឹងឧស្សាហកម្មក្នុងរាជធានីភ្នំពេញ
- ប្រកាសរួមស្តីពីការដាក់ឱ្យប្រើប្រាស់គំរូសំណុំលិខិតដោះស្រាយបទល្មើសបរិស្ថានដល់មន្ត្រីនគរបាលយុត្តិធម៌
- ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅខេត្ត ក្រុងក្នុងព្រះរាជណាចក្រកម្ពុជា
- សេចក្តីណែនាំស្តពីការគ្រប់គ្រងសំណល់រឹងតាមបណ្តារោងចក្រ សហគ្រាស និងក្រុមហ៊ុន
- សេចក្តីជូនដំណឹងស្តីពីការបញ្ឈប់ការលក់ ឬផ្តល់ និងការដុតសំណល់រឹងឧស្សាហកម្ម។